ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# របាយការណ៍
# ស្តីអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
# ឆ្នាំ ២០០៤ និង ២០០៥

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា

(ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)

ខែ កុម្ភៈ ឆ្នាំ ២០០៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍
# ស្តីអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
# ឆ្នាំ ២០០៤ និង ២០០៥

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា

(ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)

ខែ កុម្ភៈ ឆ្នាំ ២០០៦

# អារម្ភកថា

ជារៀងរាល់ឆ្នាំ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា (កអក/គជនា) បានរៀបចំរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការសំរាប់កិច្ចអភិវឌ្ឍន៍ (Development Cooperation Report-DCR) ដែលជាផ្នែកមួយនៃភារកិច្ចស្នូលរបស់ខ្លួន ។ គោលដៅចំបងនៃការរៀបចំរបាយការណ៍នេះ គឺការបង្ហាញជូននូវពតិមានសង្ខេបស្តីពីការប្រើប្រាស់ជំនួយផ្លូវការសំរាប់អភិវឌ្ឍន៍ទាំងអស់(Official Development Assistance-ODA) ដែលដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍បានផ្តល់មកកម្ពុជា ។ របាយការណ៍នេះបានគូសបញ្ជាក់អំពីការប្រើប្រាស់ជំនួយ នាពេល បច្ចុប្បន្ន ក៏ដូចជាការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការកន្លងមក ដែលកម្ពុជាបានទទួលពីដៃគូអភិវឌ្ឍន៍ទ្វេ និងពហុភាគីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ព្រមទាំងពីអង្គការមិនមែនរដ្ឋាភិបាលនានា ។

របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍លើកទី១សំរាប់កម្ពុជាត្រូវបានរៀបចំ និងបោះពុម្ពផ្សាយដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) នៅចុងឆ្នាំ ១៩៩៤ ដើម្បីពិនិត្យ និងវាយតំលៃការប្រើប្រាស់ជំនួយបរទេសឆ្នាំ១៩៩២-១៩៩៣ សំរាប់អភិវឌ្ឍកម្ពុជា ។ ចាប់ពីឆ្នាំ១៩៩៥មក កអក/គជនា បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍នេះជារៀងរាល់ឆ្នាំ ។ ពតិមានទាំងឡាយដែលបានបង្ហាញក្នុងរបាយការណ៍នេះ បានផ្អែកលើតួលេខស្តីពីការផ្តល់ជំនួយជាក់ស្តែង និងផែនការផ្តល់ជំនួយនាឆ្នាំខាងមុខ ដែល កអក/គជនា បានខិតខំប្រមូលជារៀងរាល់ឆ្នាំពីដៃគូអភីវឌ្ឍន៍ ។ ទោះបីបានខិតខំធ្វើសុពលភាពតួលេខតាមប្រភពពតិមានផ្សេងៗទៀតក៏ដោយ ក៏សុពលភាពនិងភាពប្រាកដប្រជានៃពតិមានដែលបានបង្ហាញក្នុងរបាយការណ៍នេះ នៅតែពឹងផ្អែកភាគច្រើនលើគុណភាពនៃពតិមាន ដែលដៃគូអភិវឌ្ឍន៍បានផ្តល់ កអក/គជនា ។ ទន្ទឹមនេះ ក៏គួរកត់សំគាល់ដែរថា ជំនួយសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលដៃគូអភិវឌ្ឍន៍មួយចំនួនបានរាយការណ៍ មានរាប់បញ្ចូលទាំងចំណាយដែលបានប្រើប្រាស់នៅក្រៅប្រទេសផងដែរ ។

របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ គឺជាឯកសារមួយក្នុងបណ្តាឯកសារ ដែលរាជរដ្ឋាភិបាលត្រូវបង្ហាញក្នុងកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំ ។ របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក៏ជាប្រភពពតិមានយ៉ាងសំខាន់សំរាប់ឱ្យរាជរដ្ឋាភិបាលធ្វើសេចក្តីសំរេចនានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ជំនួយបរទេស និងសំរាប់រៀបចំយុទ្ធសាស្ត្រនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនេះ ក្នុងគោលដៅសំរេចឱ្យបាននូវបណ្តាអាទិភាពនៃកិច្ចអភិវឌ្ឍន៍កម្ពុជា ។ របាយកាណ៍នេះបានបង្ហាញអំពីទិន្នន័យនៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ដៃគូអភិវឌ្ឍន៍ ក្នុងអំឡុងឆ្នាំ២០០៤-២០០៥ ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមសំដែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ទាំងអស់ ដែលបានផ្តល់ពតិមាន សំរាប់រៀបចំរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការសំរាប់កិច្ចអភិវឌ្ឍន៍នេះ ។ លើសពីនេះ ខ្ញុំក៏សូមសំដែងអំណរគុណចំពោះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ដែលបានផ្តល់ជំនួយបច្ចេកទេសដល់ កអក/គជនា ។ ជំនួយ

ដ៏សារៈសំខាន់នេះបានជួយដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំគោលនយោបាយ និងការពង្រឹងស្ថាប័នសំរាប់គ្រប់គ្រងជំនួយអភិវឌ្ឍន៍ផ្លូវការ ដើម្បីលើកកំពស់គុណភាពនៃការប្រើប្រាស់ធនធានទាំងនេះសំរាប់ជាគុណប្រយោជន៍របស់ប្រជាជនកម្ពុជា ក៏ដូចជាការពង្រឹងភាពជាដៃគូ ជាមួយដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ឱ្យបានកាន់តែប្រសើរថែមទៀត ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៦

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# មាតិកា


**អារម្ភកថា** ទំព័រ

**១ . សេចក្តីផ្តើម** ១

**២ . សមិទ្ធផលសេដ្ឋកិច្ច** ៣

**៣ . ជំនួយក្រៅប្រទេសសំរាប់កិច្ចអភិវឌ្ឍន៍** ៨

៣.១ ការសន្យាផ្តល់ និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ៨

៣.២ ការប្រើប្រាស់ជំនួយតាមប្រភពអ្នកផ្តល់ជំនួយ ១៣

៣.៣ ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌនៃជំនួយ ១៦

៣.៤ ការប្រើប្រាស់ជំនួយតាមប្រភេទ និងតាមលក្ខខ័ណ្ឌ ១៩

៣.៥ ការប្រើប្រាស់ជំនួយតាមវិស័យ ២៦

៣.៦ ការប្រើប្រាស់ជំនួយតាមវិស័យ និងតាមប្រភពអ្នកផ្តល់ជំនួយ ៣០

៣.៧ ការប្រើប្រាស់ជំនួយតាមបណ្តាខេត្ត/ក្រុង ៣៨

**៤ . សេចក្តីសន្និដ្ឋាន** ៤១

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី ១ : និយមន័យនៃពាក្យដែលបានប្រើក្នុងសំណួរអង្កេត ៤៥

ឧបសម្ព័ន្ធទី ២ : ការប្រើប្រាស់ជំនួយតាមប្រភពអ្នកផ្តល់ជំនួយសំខាន់ៗ និងតាមឆ្នាំ: ១៩៩២ - ២០០៥ ៥៣

ឧបសម្ព័ន្ធទី ៣ : ការប្រើប្រាស់ជំនួយតាមប្រភេទ លក្ខខ័ណ្ឌនៃជំនួយ និងតាមឆ្នាំ: ១៩៩២ - ២០០៥ ៥៥

ឧបសម្ព័ន្ធទី ៤ : ការប្រើប្រាស់ជំនួយតាមវិស័យ និងតាមឆ្នាំ: ១៩៩២ - ២០០៥ ៥៦

ឧបសម្ព័ន្ធទី ៥ : ការប្រើប្រាស់ជំនួយតាមបណ្តាខេត្ត/ក្រុង: ឆ្នាំ២០០៤ និង ២០០៥ ៥៧

**ក្រាហ្វិក**

ក្រាហ្វិកទី ១: ការសន្យាផ្តល់និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ ឆ្នាំ ១៩៩២-២០០៥ ១០

ក្រាហ្វិកទី ២: ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌ ឆ្នាំ ១៩៩២-២០០៥ ១៦

ក្រាហ្វិកទី ៣: ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌនៃជំនួយ និងតាមប្រភពជំនួយ ឆ្នាំ ២០០១-២០០៥ ១៨

ក្រាហ្វិកទី ៤: ការប្រើប្រាស់ជំនួយតាមប្រភេទ និងតាមលក្ខខ័ណ្ឌ ២២

ក្រាហ្វិកទី ៥: ការប្រើប្រាស់ជំនួយតាមប្រភេទ តាមលក្ខខ័ណ្ឌ និងតាមឆ្នាំ ១៩៩២-២០០៥ ២៥

ក្រាហ្វិកទី ៦: ការប្រើប្រាស់ជំនួយតាមវិស័យ ២៩

ក្រាហ្វិកទី៧ : ភាគរយនៃការប្រើប្រាស់ជំនួយតាមខេត្ត/ក្រុង-២០០៥ ៤០

# ១. សេចក្តីផ្តើម

១- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ (ក.អ.ក/គ.ជ.នា) បានរៀបចំរបាយការណ៍ស្តីអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (Development Cooperation Report-DCR) ដែលជាផ្នែកមួយនៃភារកិច្ចស្នូលរបស់ខ្លួន ដើម្បីបង្ហាញជូននូវពត៌មានស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ (Official Development Assistance-ODA) ដែលដៃគូអភិវឌ្ឍន៍អន្តរជាតិបានផ្តល់មកកម្ពុជា ។ របាយការណ៍នេះបានរៀបចំឡើងដោយផ្អែកលើទិន្នន័យស្តីពីការប្រើប្រាស់ជំនួយជាក់ស្តែង និងផែនការប្រើប្រាស់ជំនួយនៅកម្ពុជាដែល ក.អ.ក/គ.ជ.នា ប្រមូលបានពីដៃគូផ្តល់ជំនួយទ្វេភាគី និងពហុភាគីទាំងអស់ ព្រមទាំងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ។

២- របាយការណ៍ស្តីអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ បានបង្ហាញពីការប៉ាន់ស្មានបឋមនៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការសំរាប់ឆ្នាំ២០០៥ និងទិន្នន័យស្តីពីការប្រើប្រាស់ជំនួយជាក់ស្តែង ដែលដៃគូអភិវឌ្ឍន៍បរទេសបានរាយការណ៍សំរាប់ឆ្នាំ២០០៤ ។ ដូចគ្នានឹងរបាយការណ៍មុនៗដែរ ទិន្នន័យស្តីពីការប្រើប្រាស់ជំនួយត្រូវបានសង្ខេបតាមប្រភេទនិងលក្ខខ័ណ្ឌនៃជំនួយ តាមវិស័យ និងតាមប្រទេស/ស្ថាប័នផ្តល់ជំនួយសំខាន់ៗ ។ លើសពីនេះទៀត របាយការណ៍សំរាប់ឆ្នាំ២០០៤-២០០៥ នេះ ក៏បានរៀបចំជាតារាងផងដែរនូវពត៌មានសង្ខេបនៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមប្រទេស/ស្ថាប័នផ្តល់ជំនួយ តាមវិស័យ និងតាមបណ្តាខេត្ត/ក្រុងនានា ។

៣- ទិន្នន័យសំខាន់ៗសំរាប់រៀបចំរបាយការណ៍ស្តីអំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រចាំឆ្នាំ ត្រូវបានប្រមូលតាមរយៈសំណួរអង្កេត ។ ក.អ.ក/គ.ជ.នា បានរៀបចំប្រព័ន្ធ Website សំរាប់ប្រមូលពត៌មានស្តីពីការប្រើប្រាស់ជំនួយ ពីដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីទាំងអស់ ។ នេះជាលើកទីមួយ ដែលដៃគូអភិវឌ្ឍន៍ទាំងអស់បានផ្តល់ពត៌មានអំពីការប្រើប្រាស់ជំនួយតាមរយៈ Website (CDC.KHMER.BIZ) ។ ជាការចាប់ផ្តើម ក.អ.ក/គ.ជ.នា បានបញ្ចូលពត៌មានស្តីពីការប្រើប្រាស់ ដែលដៃគូអភិវឌ្ឍន៍បានផ្ញើមកពីឆ្នាំមុន ទៅក្នុង Website ដើម្បីឱ្យពួកគេផ្តល់ផ្តល់សុពលភាពទៅលើតួលេខទាំងនោះ ព្រមទាំងធ្វើបច្ចុប្បន្នភាពពត៌មានសំរាប់ឆ្នាំ២០០៤-២០០៥ ។ ដូចនេះ ពត៌មានទាំងនេះ អាចចែករំលែកជូនជាសាធារណៈបាន ។

៤- ក.អ.ក/គ.ជ.នា បានខិតខំប្រមូលពត៌មានស្តីពីជំនួយសំរាប់គំរោង/កម្មវិធីកំពុងអនុវត្ត និងគំរោងដែលគ្រោងអនុវត្ត ពីដៃគូអភិវឌ្ឍន៍ទាំងអស់ ។ ប៉ុន្តែ ប្រការដែលគួរអោយសោកស្តាយគឺដៃគូអភិវឌ្ឍន៍បរទេសមួយចំនួន ពុំបានផ្តល់ពត៌មានលំអិតនៃការប្រើប្រាស់ជំនួយតាមកម្មវិធី/គំរោងនោះទេ ដែលធ្វើឱ្យកិច្ចរៀបចំរបាយការណ៍ប្រើប្រាស់ជំនួយតាមប្រភេទ តាមលក្ខខ័ណ្ឌ តាមវិស័យ និងតាមទិសដៅភូមិសាស្ត្រនៃការផ្តល់ជំនួយជួបប្រទះការលំបាកខ្លះៗ ។ លើសពីនេះទៅទៀត យើងសង្កេតឃើញថាដៃគូ

អភិវឌ្ឍន៍មួយចំនួនពុំបានឆ្លើយតបទាន់ពេលវេលា សំរាប់រៀបចំរបាយការណ៍នេះឡើយ ។ ដោយផ្អែកលើប្រភពពតិមាននិងឯកសារមួយចំនួនដែលអាចទុកចិត្តបាន យើងក៏បានបញ្ចូលក្នុងរបាយការណ៍នេះនូវការប៉ាន់ស្មានសំរាប់តួលេខដែលខ្វះចន្លោះមួយចំនួនដែរ ។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលវិញ ការប្រើប្រាស់ជំនួយត្រូវបានរៀបចំឡើង ដោយប្រើប្រាស់ទិន្នន័យនានា របស់នាយកដ្ឋានគ្រប់គ្រងជំនួយអង្គការមិនមែនរដ្ឋាភិបាលនៃ ក.អ.ក/ គ.ជ.នា ។ របាយការណ៍ត្រូវបានរៀបចំ ដោយផ្អែកតាមពតិមានដែល ក.អ.ក/ គ.ជ.នា មាន រហូតមកដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦ នេះ ។

៥- លក្ខខ័ណ្ឌបែងចែកជំនួយអភិវឌ្ឍន៍ផ្លូវការតាមប្រភេទ តាមលក្ខខ័ណ្ឌ និងតាមវិស័យត្រូវបានប្រើវិធីសាស្ត្របែងចែកតាមស្តង់ដាររបស់អង្គការសហប្រជាជាតិ និង OECD ។ តាមប្រព័ន្ធនេះជំនួយត្រូវបានបែងចែកតាមប្រភេទដូចតទៅ៖ កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ កិច្ចសហប្រតិបត្តិការបច្ចេកទេសសំរាប់វិនិយោគ ជំនួយសំរាប់គំរោងវិនិយោគ ជំនួយទ្រទ្រង់ថវិកានិងជញ្ជីងទូទាត់ ជំនួយម្ហូបអាហារ មនុស្សធម៌ និងសង្គ្រោះបន្ទាន់ ។ និយមន័យស្តីពីប្រភេទ និងលក្ខខ័ណ្ឌនៃជំនួយមានចែងក្នុងឧបសម្ព័ន្ធទី ២ ។

៦- ដៃគូអភិវឌ្ឍន៍ភាគច្រើនបានអនុវត្តកម្មវិធី/គំរោងរបស់ខ្លួនទាំងស្រុង ឬមួយផ្នែក តាមរយៈទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ និង/ឬតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ។ ម៉្យាងទៀត យើងក៏សង្កេតឃើញមានកិច្ចព្រមព្រៀងសហហិរញ្ញប្បទានមួយចំនួន ដែលបានធ្វើឡើងដោយទីភ្នាក់ងារផ្តល់ជំនួយទ្វេភាគីដើម្បីផ្តល់មូលនិធិដល់ភ្នាក់ងារពហុភាគី និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិសំរាប់អនុវត្តគំរោងរបស់ខ្លួន ។ ដើម្បីចៀសវាង «*ការគណនាត្រួតគ្នា*» ក្រោយឆ្នាំ ២០០០ ការប្រើប្រាស់ជំនួយរបស់បណ្តាទីភ្នាក់ងារនៃអង្គការសហប្រជាជាតិត្រូវបានបែងចែកជា ២ ប្រភេទ ។ ប្រភេទទី ១ បានឆ្លុះបញ្ចាំងអំពីជំនួយសរុបទាំងអស់សំរាប់កិច្ចប្រតិបត្តិការរបស់បណ្តាទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ ដោយមិនគិតពីប្រភពហិរញ្ញប្បទានឡើយ ។ ប្រភេទទី ២ បង្ហាញតែពីការប៉ាន់ស្មាននៃការប្រើប្រាស់ «ប្រភពធនធានផ្ទាល់» របស់ទីភ្នាក់ងារសហប្រជាជាតិទាំងនោះ សំរាប់អនុវត្តគំរោងនិងកម្មវិធីរបស់ខ្លួនប៉ុណ្ណោះ ។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលវិញ យើងបានកត់ត្រាតែប្រភពហិរញ្ញប្បទានផ្ទាល់តែប៉ុណ្ណោះ (ប្រភពមូលនិធិពី ឯកជន អង្គការសាសនា អង្គការមនុស្សធម៌ និងមូលនិធិអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត) ។ ពតិមានស្តីពីការប្រើប្រាស់ជំនួយដែលអ្នកផ្តល់ជំនួយបានផ្តល់ជារូបិយប័ណ្ណរបស់ប្រទេសនីមួយៗ ត្រូវបានកត់ត្រាជាដុល្លារអាមេរិកដោយផ្អែកលើអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំផ្លូវការរបស់អង្គការសហប្រជាជាតិ ។

៧- ផ្នែកដំបូងនៃរបាយការណ៍នេះ បានវិភាគអំពីសមិទ្ធិផលសេដ្ឋកិច្ចឆ្នាំ២០០៤-២០០៥ ។ ផ្នែកបន្ទាប់បានរៀបរាប់អំពីការសន្យាផ្តល់ និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការពីឆ្នាំ ១៩៩២ មក ។ ពតិមានស្តីពីការប្រើប្រាស់ជំនួយបានលើកយកមក បង្ហាញតាមប្រភេទនិងលក្ខខ័ណ្ឌ តាមវិស័យ និងតាមប្រភពជំនួយ ។ លើសពីនេះទៀត តារាងទិន្នន័យនៃការប្រើប្រាស់ជំនួយតាមវិស័យ និងតាមដៃគូអភិវឌ្ឍន៍ ព្រមជាមួយតារាងស្តីពីការប្រើប្រាស់ជំនួយតាមខេត្ត/ក្រុង ក៏បានរៀបចំនៅក្នុងរបាយការណ៍ឆ្នាំ២០០៤និង២០០៥ដែរ ។

## ២. សមិទ្ធិផលសេដ្ឋកិច្ច

៨- ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តន៍កំណែទំរង់សារពើពន្ធបានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ច ឆ្នាំ២០០៤-២០០៥ មានភាពរឹងមាំ ទោះបីជាមានកត្តាអវិជ្ជមានក្រៅប្រទេសខ្លះក៏ដោយ (ដូចជា ការកើនឡើងនៃតំលៃប្រេង ជំងឺសារស៍ ការរាតត្បាតនៃជំងឺគ្រុនផ្តាសាយបក្សី និងលក្ខខ័ណ្ឌអាកាសធាតុមិនអនុគ្រោះនៅក្នុងឆ្នាំ២០០៤) ។ នៅក្នុងឆ្នាំ២០០៤ កំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស) គិតតាមតំលៃស្ថេរ បានកើនដល់ ៧,៧% ធៀបនឹងកំណើន ផ.ស.ស ៧,០% ក្នុងឆ្នាំ២០០៣ និង ៥,២%ក្នុងឆ្នាំ២០០២ ។ តាមការប៉ាន់ស្មានបឋម សេដ្ឋកិច្ចក្នុងឆ្នាំ២០០៥ បានកើន ៧% ដោយសារកំណើនយ៉ាងខ្លាំងក្លានៅក្នុងវិស័យកសិកម្ម ការបន្តពង្រីកសកម្មភាពនាំចេញ ទេសចរណ៍ និង សំណង់ ។ ផ.ស.ស សរុបក្នុងឆ្នាំ២០០៤ មាន ១៩.៦៣០ពាន់លានរៀល (ប្រហាក់ប្រហែលនឹង ៤,៩ពាន់លានដុល្លារអាមេរិក) និងឆ្នាំ២០០៥ មាន ២២.០៨៦ពាន់លានរៀល (ប្រហាក់ប្រហែល នឹង ៥,៤ពាន់លានដុល្លារអាមេរិក) ។ អត្រាអតិផរណាបានកើនរហូតដល់ ៥,៦% ក្នុងឆ្នាំ ២០០៤ ដោយសារកម្រិតដ៏ខ្ពស់នៃថ្លៃប្រេង ថ្លៃអង្ករ និងការឡើងថ្លៃជាទូទៅលើផ្សារអន្តរជាតិ ។ ក្នុងឆ្នាំ២០០៥ ការបន្តឡើងថ្លៃប្រេងដែលបានជះឥទ្ធិពល ដល់គ្រប់វិស័យ រួមទាំងអ្នកប្រើប្រាស់ អ្នកផលិត និងរាជរដ្ឋាភិបាល ហើយបានជំរុញឱ្យអតិផរណាកើនដល់ប្រហែល ៦% ។ ទុនបម្រុងអន្តរជាតិបានស្ថិតក្នុងចន្លោះ ២,៥-២,៧ខែនៃការនាំចូល ។ ស្របពេលជាមួយគ្នានេះដែរ ការប្រែប្រួលយ៉ាងខ្លាំងនៃទីផ្សាររូបិយប័ណ្ណសកលលោកក៏មានផលប៉ះពាល់ ទៅលើទីផ្សាររូបិយប័ណ្ណក្នុងស្រុកដែរ ក្នុងខណៈដែលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក បានធ្លាក់ចុះបន្តិចក្នុងឆ្នាំ២០០៥ ធៀបនឹងឆ្នាំមុន ។ ប្រាក់រៀលបានធ្លាក់ចុះប្រមាណ២% ក្នុងខែធ្នូ ឆ្នាំ២០០៥ ធៀបនឹងការធ្លាក់ចុះប្រមាណ១%ក្នុងរយៈពេលដូចគ្នានៃឆ្នាំ មុន ។ ប៉ុន្តែ បម្រែបម្រួលនេះស្ថិតក្នុងចន្លោះមួយ ដែលអាចគ្រប់គ្រងបាននៅឡើយ ។

៩- វិស័យសេដ្ឋកិច្ចសំខាន់ៗនៃ ផ.ស.ស គិតតាមតំលៃចរន្ត រួមមាន ÷ វិស័យកសិកម្ម នេសាទ និងរុក្ខាប្រមាញ់ ក្នុងឆ្នាំ២០០៤ ស្មើនឹង៣១,១% នៃ ផ.ស.ស ធៀបនឹង ៤៥,១% ក្នុងឆ្នាំ១៩៩៣ ។ វិស័យឧស្សាហកម្មបន្តកើនឡើងច្រើនជាង២ដង ពោលគឺ បានកើនពី១២,៧%ក្នុងឆ្នាំ១៩៩៣ដល់២៧,៥% ក្នុងឆ្នាំ ២០០៤ ដោយសារការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់និងស្បែកជើង ជាមួយនឹងការកើនឡើងនៃការសាងសង់ ។ ទោះបីជាមានកំណើនគួរឱ្យកត់សំគាល់នៅក្នុងវិស័យសេវាកម្មដែលបំរើវិស័យទេសចរណ៍ក៏ដោយ ប៉ុន្តែ ដោយសារការរីកចំរើនយ៉ាងឆាប់រហ័សក្នុងវិស័យឧស្សាហកម្ម វិស័យសេវាកម្មបានថយចុះពី៣៩,៥% នៃ ផ.ស.ស ក្នុងឆ្នាំ១៩៩៣ មកត្រឹម ៣៥,៨% ក្នុងឆ្នាំ២០០៤ វិញ ។

១០- គ្រោះរាំងស្ងួត ទឹកជំនន់ និងការធ្លាក់ចុះនៃផលិតផលព្រៃឈើ បានធ្វើឱ្យវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្លាក់ចុះ២,០%នៅក្នុងឆ្នាំ២០០៤ ធៀបនឹងកំណើន១២,២%ក្នុងឆ្នាំ២០០៣ ។ តំលៃបន្ថែម នៃ

វិស័យកសិផលបានធ្លាក់ចុះ ៣,៤% ហើយផលនេសាទបានធ្លាក់ចុះ ៣,៣% ។ ចំណែកតំលៃបន្ថែម នៃផលនេសាទទឹកសាបនិងសមុទ្របន្តធ្លាក់ចុះ៤,៦% និង៧,៨% ក្នុងឆ្នាំ ២០០៤ដែរ ។ ការចិញ្ចឹមសត្វនិងបសុបក្សីបានកើនឡើង៤,៣% ។ តំលៃបន្ថែមកើនឡើង០,២%នៅក្នុងវិស័យព្រៃឈើ ដោយសារការកើនឡើងនៃតំរូវការប្រើប្រាស់និងការសាងសង់ក្នុងស្រុក និងផលិតកម្មគ្រឿងសង្ហារឹម ព្រមទាំងការថយចុះនៃការនាំចេញ។ ផលិតផលកសិកម្មបានកើន៤,៥%ក្នុងឆ្នាំ២០០៥ ក្នុងនោះផលិតផលស្រូវកើនឡើង ២០%។

១១- វិស័យឧស្សាហកម្មបានកើនឡើង១៦,១%ក្នុងឆ្នាំ២០០៤ ធៀបនឹងកំណើន១១,៩%ក្នុងឆ្នាំ២០០៣ ។ វិស័យនេះបានកើនឡើងខ្ពស់ ដោយសារការកើនឡើងនៃឧស្សាហកម្មកម្មន្តសាល (៧៥,៤%) និងសំណង់ (២២,០%) ។ ផលិតកម្មវាយនភ័ណ្ឌសំលៀកបំពាក់និងស្បែកជើង បានបង្កើនតំលៃបន្ថែម ២៤,៩% នៅក្នុងឆ្នាំ២០០៤ បន្ទាប់ពីបានកើនចំនួន១៦,៩% នាឆ្នាំ២០០២ និង២១,២% ក្នុងឆ្នាំ២០០៣មក ។ ការនាំចេញផលិតផលភាគច្រើនក្នុងប្រព័ន្ធអនុគ្រោះទូទៅ ដែលជាផលិតផលសំលៀកបំពាក់ បានកើនឡើងពី ៨២,៦% នៃទំនិញនាំចេញសរុបក្នុងឆ្នាំ២០០៣ ដល់៨៨,៨%នៅឆ្នាំ២០០៤ ។ តំលៃបន្ថែមនៃវិស័យសំណង់ក៏បានចូលរួមក្នុងកំណើនក្នុងឆ្នាំ២០០៤ យ៉ាងខ្លាំងក្លាដែរ គឺកើនចំនួន១៣,២% ធៀបនឹង១១,១% នៅឆ្នាំ ២០០២ និង២៧,១%នៅឆ្នាំ២០០៣ ។ ក្នុងឆ្នាំ២០០៥ វិស័យឧស្សាហកម្មកើនឡើង១០,៧% ដោយសារការបន្តពង្រឹងផ្នែកកម្មន្តសាលដែលបានកើនឡើង១០,២% និងផ្នែកសំណង់កើនឡើង១៣% ។ តំលៃបន្ថែមនៃការនាំចេញសំលៀកបំពាក់បានកើនឡើង ពី១,៩៨ពាន់លានដុល្លារអាមេរិក នាឆ្នាំ២០០៤ ដល់ ២,១៧ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ ។

១២- វិស័យសេវាកម្មបានកើនឡើង៩,២% នៅឆ្នាំ២០០៤ ធៀបនឹង ០,២% នៅក្នុងឆ្នាំ២០០៣ ។ ទេសចរណ៍នៅតែជាវិស័យដែលបានចូលរួមចំបងសំរាប់កំណើនក្នុងវិស័យសេវាកម្ម ។ ភ្ញៀវទេសចរណ៍បរទេសបានកើនឡើងចំនួន ៥០,៤% ក្នុងឆ្នាំ២០០៤ ។ ភ្ញៀវទេសចរណ៍បរទេសបានរួមចំណែកដល់កំណើនក្នុងផ្នែកសណ្ឋាគារ និងភោជនីយដ្ឋាន (២៣,៦%) ឧស្សាហកម្មដឹកជញ្ជូន និងទូរគមនាគមន៍ (៦,២%) និងសេវាកម្មផ្សេងៗទៀត (១៨,៥%) ។ នៅក្នុងឆ្នាំ២០០៥ វិស័យសេវាកម្មកើនឡើង៦,២% គិតតាម តំលៃស្ថេរ ក្នុងនោះ តំលៃបន្ថែមផ្នែកសណ្ឋាគារនិងភោជនីយដ្ឋាន បានកើនឡើងចំនួន ១៥% ។

១៣- ផ.ស.ស សំរាប់មនុស្សម្នាក់ក្នុងឆ្នាំ២០០៤មាន ១,៤៣៥លានរៀល ពោលគឺកើនឡើង ១១,២% ធៀបនឹង ឆ្នាំ ២០០៣ ។ ផ.ស.ស នេះបានកើនឡើងក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៦,៧% ក្នុងរយៈ ៤ ឆ្នាំកន្លងមក ។ កំណើនប្រជាជនមធ្យមក្នុងរយៈពេលដូចគ្នានេះ មាន ១,៩% ក្នុងមួយឆ្នាំ ។ ដោយគិតតាមតំលៃស្ថេរ ផ.ស.ស សរុបប្រចាំឆ្នាំសំរាប់ប្រជាជនម្នាក់មាន ១,៣១៩លានរៀលនៅឆ្នាំ២០០៤ កើនឡើង ៥,៦% ធៀបនឹងឆ្នាំ ២០០៣ ។ កំណើនជាមធ្យមនៃ ផ.ស.ស សរុប តាមតំលៃស្ថេរ សំរាប់ប្រជាជនម្នាក់ៗមានប្រហែល ៤,៤% ក្នុងរយៈពេល៤ឆ្នាំ កន្លងមកនេះ ។ ផ.ស.ស សំរាប់ប្រជាជនម្នាក់ គិតជាប្រាក់ដុល្លារអាមេរិក បានកើនប្រចាំឆ្នាំ ៤,៦% នៅឆ្នាំ២០០៤ ពោលគឺ បានកើនដល់៣២៨ដុល្លារអាមេរិក ធៀបនឹង

កំណើន ៣,៦%នៅឆ្នាំ២០០៣ និង៣,៩% នៅឆ្នាំ២០០២ ។ ផ.ស.ស សំរាប់ប្រជាជនម្នាក់ៗបានកើនឡើងពី ៣២៥ដុល្លារអាមេរិក នៅឆ្នាំ២០០៣ ដល់៣៥៧ដុល្លារអាមេរិក នៅឆ្នាំ២០០៤ ។

**ផ.ស.ស តាមវិស័យសេដ្ឋកិច្ចសំខាន់ៗ តាមថ្លៃចរន្ត**




១៤- សមិទ្ធិផលនៃការអនុវត្តន៍កំណែទំរង់សារពើពន្ធ ពិសេស ក្នុងការគ្រប់គ្រងចំណូលនិងចំណាយសាធារណៈ បានផ្តល់នូវលទ្ធផលគួរជាទីគាប់ចិត្ត ។ ចំណូលក្នុងស្រុកសរុបបានកើនឡើងពី១០,២%នៃ ផ.ស.ស ក្នុងឆ្នាំ២០០៣ទៅ១១,៣%នៅឆ្នាំ២០០៤ និង ១១,៧%នៅឆ្នាំ២០០៥ ។ ចំណូលពន្ធបានកើនពី៨,៤%ក្នុងឆ្នាំ២០០៤ ដល់ ៨,៧% នៃ ផ.ស.ស ក្នុងឆ្នាំ ២០០៥ ។ កំណើនចំណូលបានឆ្លុះបញ្ចាំងនូវប្រសិទ្ធភាពនៃវិធានការនានាសំរាប់ប្រមូលចំណូល ដែលបានដាក់ឱ្យអនុវត្តក្នុងត្រីមាសទី៤ឆ្នាំ២០០៣និងដើមឆ្នាំ ២០០៤ ។ វិធានការទាំងនេះគឺជាវិធានការដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្ត សំរាប់បន្តប្រឹងប្រែងប្រមូលចំណូលពីប្រៃសណីយ៍ ពីទូរស័ព្ទ និងពីទូរគមនាគមន៍ ការប្រមូលចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងវិធានការបន្ថែមផ្សេងៗទៀត ដូចជាការបន្តពង្រីកមូលដ្ឋានយកពន្ធ ការបង្កើនការប្រមូលថ្លៃទិដ្ឋាការ និងចំណូលពីទេសចរណ៍ជាដើម ។

១៥- ចំណូលក្នុងស្រុកសរុបបានកើនពី ១.៧៧៦ពាន់លានរៀល ស្មើនឹង ៤៤៦,៧លានដុល្លារអាមេរិក នាឆ្នាំ២០០៣ ដល់២.២១២ពាន់លានរៀល ក្នុងឆ្នាំ២០០៤ ស្មើនឹង៥៥០,៧លានដុល្លារអាមេរិក ហើយបានបន្តកើនរហូតដល់ ២.៥៩១ពាន់លានរៀល ស្មើនឹងប្រមាណ៦២៩,២លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ នេះ ។ ក្នុងឆ្នាំ២០០៥ នេះ ចំណូលក្នុងស្រុកដែលប្រមូលបាន រួមមាន ÷ ចំណូលពន្ធដារចំនួន ១.៩២៩ពាន់លានរៀល ចំណូលមិនមែនពន្ធ ចំនួន៥៥៥ពាន់លានរៀល និងចំណូលជាមូលធន ដែលបានមកពីការធ្វើឯកជនភាវូបនីយកម្ម និងប្រភពផ្សេងៗ ចំនួន ១០៦ពាន់លានរៀល ។

១៦- ចំណូលក្នុងស្រុកសរុបនាឆ្នាំ២០០៤រួមមាន ÷ ចំណូលពន្ធដារ ១.៦៤៨ពាន់លានរៀល ចំណូលមិនមែនពន្ធ ៥៤៤ពាន់លានរៀល និងចំណូលមូលធន ១៩ពាន់លានរៀល ដែលបានមកពីការធ្វើឯកជនភាវូបនីយកម្ម និងពីប្រភពផ្សេងៗទៀត ។

១៧- ពិនិត្យជារួម នៅក្នុងឆ្នាំ២០០៤ និងឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានប្រឹងប្រែងកំរិតចំណាយឱ្យនៅក្រោមគោលដៅ ដែលអាចជួយកាត់បន្ថយការធ្វើហិរញ្ញប្បទានពីប្រភពក្នុងស្រុក ។ ក្នុងកំឡុងពេល២ឆ្នាំនេះ ចំណាយចរន្តសរុបមានកំរិតទាបជាងចំណូលដែលប្រមូលបាន គិតទាំងន័យនាមករណ៍ និងជាភាគរយ នៃ ផ.ស.ស ។ ចំណាយចរន្តសរុបបានធ្លាក់ចុះពី១០,៦% នៃ ផ.ស.ស នៅក្នុងឆ្នាំ២០០៣ ដល់៩,៥% ក្នុងឆ្នាំ២០០៤ និង៩,៣% ក្នុងឆ្នាំ២០០៥ (តាមការប៉ាន់ស្មានបឋម) ។

១៨- នៅឆ្នាំ២០០៤ ចំណាយទូទាត់តាមរតនាគារមានចំនួនសរុប ២.០៧៨,៨ពាន់លានរៀល ស្មើនឹង ៥១៥,៧ លានដុល្លារអាមេរិក ។ ចំណាយទាំងនេះរួមមាន ចំណាយចរន្តចំនួន១.៧៤៥,៧ពាន់លានរៀល ស្មើនឹង ៤៣៣,១លានដុល្លារអាមេរិក ចំណាយមូលធននិងការអភិវឌ្ឍន៍ចំនួន៣៣៣,១ពាន់លានរៀល ស្មើនឹង ៨២,៦លានដុល្លារអាមេរិក ។ រីឯចំណាយមូលធនសរុបនៅក្នុងឆ្នាំ២០០៤ ដែលមានប្រភពមកពីក្នុងស្រុក និងក្រៅប្រទេស មានប្រមាណ ១.២៦០,៦ពាន់លានរៀល ឬ ៣១២,៧លានដុល្លារអាមេរិក ។

១៩- នៅឆ្នាំ២០០៤ ចំណាយចរន្តសរុបមានចំនួន ១.៧៤៥,៦ពាន់លានរៀល ដែលក្នុងនោះរួមមាន ÷

- ចំណាយរដ្ឋបាលស៊ីវិលមាន១.២៧៤,២ពាន់លានរៀល ស្មើនឹង៣១៦,១លានដុល្លារអាមេរិក ត្រូវជា ៧៣% នៃចំណាយចរន្តសរុប ក្នុងនោះ ចំណាយលើប្រាក់បៀវត្សមាន ៣៤៣,៦ពាន់លានរៀល ស្មើនឹង ៨៥,២លានដុល្លារអាមេរិក ត្រូវជា ២៧% នៃចំណាយរដ្ឋបាលស៊ីវិលសរុប ។
- ចំណាយយោធានិងសន្តិសុខ មានចំនួន៤២២,៨ពាន់លានរៀល ស្មើនឹង១០៤,៩លានដុល្លារអាមេរិក គឺស្មើនឹង២៤,២% នៃចំណាយចរន្តសរុប ក្នុងនោះ ចំណាយប្រាក់បៀវត្សមានចំនួន ២៩៦,១ពាន់លានរៀល ស្មើនឹង ៧៣,៥លានដុល្លារអាមេរិក ត្រូវជា៧០%នៃចំណាយយោធានិងសន្តិសុខ ។
- ចំណាយការប្រាក់លើប្រាក់កម្ចីមាន៤៨,៦ពាន់លានរៀល ស្មើនឹង១២,១លានដុល្លារអាមេរិក ស្មើនឹង ២,៨% នៃចំណាយចរន្តសរុប ។

២០- តួរលេខបឋមស្តីពីចំណាយក្នុងរយៈពេល១១ខែដើមឆ្នាំ២០០៥ បានបង្ហាញថា ចំណាយដែលឆ្លងកាត់ប្រព័ន្ធរតនាគារជាតិ មានចំនួន ១.៧៨៩,៨ពាន់លានរៀល ។ ក្នុងនោះ ចំណាយចរន្តស្រូបយក១.៤៧៥,៨ពាន់លានរៀល និងចំណាយមូលធនមាន៣១៤ពាន់លានរៀល ដែលត្រូវធ្វើហិរញ្ញប្បទានដោយធនធានក្នុងស្រុកតាមរយៈប្រព័ន្ធរតនាគារជាតិ ។ ចំណាយមូលធនសរុប រួមទាំងធនធានក្នុងស្រុក និងធនធានពីបរទេស មានចំនួន៩៥០ពាន់លាន់រៀល ។

២១- ចំណាយសរុបដែលឆ្លងកាត់ប្រព័ន្ធរតនាគារជាតិក្នុងរយៈពេល១១ខែដើមឆ្នាំ២០០៥ ចំនួន១.៤៧៥,៨ពាន់លានរៀល ត្រូវបានប្រើប្រាស់សំរាប់រដ្ឋបាលស៊ីវិល ការពារប្រទេស និងសន្តិសុខ ព្រមទាំងចំណាយសំរាប់សងការប្រាក់លើបំណុលផងដែរ ។ ជាក់ស្តែងគឺ ÷

- ចំណាយសំរាប់រដ្ឋបាលស៊ីវិលមាន១.០៩២,៧ពាន់លានរៀល ស្មើនឹង៧៤,១% នៃចំណាយចរន្តសុរប ក្នុងនោះ ចំណាយសំរាប់ប្រាក់បៀវត្សមាន៣២៤,១ពាន់លានរៀល ស្មើនឹង២៩,៧%នៃចំណាយសំរាប់រដ្ឋបាលស៊ីវិល ។
- ចំណាយការពារប្រទេសនិងសន្តិសុខ មានចំនួន៣៣៦,៨ពាន់លានរៀល ស្មើនឹង២២,៨% នៃចំណាយចរន្តសុរប ក្នុងនោះ ចំណាយសំរាប់ប្រាក់បៀវត្សមានចំនួន២៥៥,៨ពាន់លានរៀល ស្មើនឹង៧៦%នៃ ចំណាយការពារប្រទេសនិងសន្តិសុខ ។
- ចំណាយសំរាប់សងការប្រាក់លើបំណុលមានចំនួន៤៦, ៣ពាន់លានរៀល ស្មើនឹង៣, ១%នៃចំណាយចរន្ត ។

២២- ចាប់ពីឆ្នាំ១៩៩៣មក សភាពការណ៍សេដ្ឋកិច្ចទូទៅមានដំណើរការល្អគួរឱ្យកត់សំគាល់ ។ នៅចន្លោះឆ្នាំ ១៩៩៣-២០០៤ ផ.ស.ស (គិតតាមតំលៃឆ្នាំ២០០០) បានកើនឡើងជាមធ្យមចំនួន៧,១% ហើយតាមការប៉ាន់ស្មានបឋម ផ.ស.ស ក្នុងឆ្នាំ២០០៥ អាចកើនឡើងរហូតដល់៧,០% ។ ទន្ទឹមនឹងនេះ កំរិតនៃភាពក្រីក្រក៏បានថយចុះគួរអោយកត់សំគាល់ផងដែរ ។ ផ្អែកតាមលទ្ធផលនៃការធ្វើអង្កេតសេដ្ឋកិច្ច និងសង្គម កិច្ចឆ្នាំ២០០៤ បានបង្ហាញថា ក្នុង៥៦%នៃភូមិនៅជនបទ ដែលតំណាងអោយ៦៥%នៃប្រជាជនជនបទនិង ទីក្រុង ហើយដែលបានធ្វើអង្កេតក្នុងឆ្នាំ១៩៩៣ និង២០០៤ ចំនួនប្រជាជនកំពុងរស់នៅក្រោមបន្ទាត់ភាព ក្រីក្របានថយចុះពី ៣៩%មក ២៨% ឬថយចុះច្រើនជាង២៨% ។ អង្កេតក្នុងឆ្នាំ១៩៩៣ ពុំបានគ្របដណ្តប់តំបន់មួយចំនួន ដែលមិនទាន់មានសុវត្ថិភាពពេញលេញឡើយ ។

២៣- កន្លងមកថ្មីៗនេះ ធនាគារពិភពលោកបានធ្វើការសិក្សាមួយស្តីពី «ការវាយតំលៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៥» ដើម្បីប៉ាន់ស្មានកំរិតនៃភាពក្រីក្រនៅឆ្នាំ១៩៩៣សំរាប់ទូទាំងប្រទេសឡើងវិញ ។ ការសិក្សានេះបានធ្វើការប៉ាន់ស្មានឡើងវិញ ដោយផ្អែកលើទិន្នន័យឆ្នាំ១៩៩៣ និងអង្កេតបន្តបន្ទាប់មកទៀត ។ ផ្អែកតាមការគណនាឡើងវិញនេះ ការសិក្សាបានប៉ាន់ស្មានឃើញថា សមាមាត្រនៃប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ នាឆ្នាំ១៩៩៣ មាន៤៧% ។ ផ្អែកតាមការប៉ាន់ស្មានកំរិតនៃភាពក្រីក្រក្នុងឆ្នាំ១៩៩៣នេះ ការសិក្សាបានសន្និដ្ឋានថា ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ បានថយចុះពី ៤៧%នៅឆ្នាំ ១៩៩៣ មកត្រឹមតែ ៣៥% នៅឆ្នាំ២០០៤ ។ ការសិក្សាបានរកឃើញទៀតថា «តំរូវការប្រើប្រាស់ក្នុងគ្រួសារជាមធ្យម» បានកើនឡើង ហើយបច្ចុប្បន្ន ប្រជាជនមានទ្រព្យផលិតកម្ម សំភារៈប្រើប្រាស់យូរអង្វែងកាន់តែប្រសើរជាងមុន រីឯស្ថានភាពរស់នៅក៏បានល្អប្រសើរជាងមុនផងដែរ ។ កំរិតជីវភាពរស់នៅរបស់ប្រជាជន ក៏បានកែលំអឱ្យប្រសើរឡើង ចំពោះក្រុមប្រជាជនក្រីក្របំផុត ដែលមានប្រមាណ២០%

នៃប្រជាជន ក៏ដូចជាក្រុមប្រជាជន មានបំផុត ២០% ផងដែរ ទោះបីជានៅមានគម្លាតខុសពីគ្នារវាងក្រុមទាំង ២ នេះ ក៏ដោយ ។ ដូចគ្នានេះដែរ ភាពក្រីក្របានថយចុះទាំងនៅតំបន់ជនបទ ក៏ដូចជានៅតំបន់ទីក្រុង។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ភាពក្រីក្រនៅតំបន់ទីក្រុងបានថយចុះច្រើនជាង ធៀបនឹងនៅតំបន់ជនបទ ក៏ដោយ ។

# ៣. ជំនួយក្រៅប្រទេសសំរាប់កិច្ចអភិវឌ្ឍន៍

## ៣.១ ការសន្យាផ្តល់ និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ

២៤ - ចាប់តាំងពីឆ្នាំ១៩៩២មក សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិបានសន្យាផ្តល់ជំនួយអភិវឌ្ឍន៍ សរុបចំនួន ជាង ៦,០៤ពាន់លានដុល្លារអាមេរិក សំរាប់កម្ពុជា តាមរយៈកិច្ចប្រជុំ ICORC នាឆ្នាំ១៩៩៣ ឆ្នាំ១៩៩៤ និងឆ្នាំ១៩៩៥ និងកិច្ចប្រជុំពិគ្រោះយោបល់ទាំង៧លើកកន្លងមក ដែលចាប់ផ្តើមពីឆ្នាំ ១៩៩៦ មក ។ រីឯក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៧ នាចុងឆ្នាំ២០០៤ ដៃគូអភិវឌ្ឍន៍បានប្រកាសផ្តល់ជំនួយសំរាប់ឆ្នាំ២០០៥ ។ ដូចនេះ កិច្ចប្រជុំពិគ្រោះយោបល់ពុំបានប្រារព្ធ នៅឆ្នាំ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ២០០៤ ហើយក៏គ្មានការសន្យាពីដៃគូអភិវឌ្ឍន៍ឡើយ ។ ប៉ុន្តែ ទោះបីជាគ្មានការសន្យាក៏ដោយ ក៏ដៃគូអភិវឌ្ឍន៍បានផ្តល់ជំនួយជាក់ស្តែងសំរាប់អភិវឌ្ឍកម្ពុជាចំនួន ៤៣៣,៣លានដុល្លារអាមេរិកក្នុងឆ្នាំ១៩៩៨ ចំនួន ៥៣៩,៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៣ និង៥៥៥,៤លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៤ ។ គិតមកដល់ត្រឹមដំណាច់ឆ្នាំ២០០៥ ជំនួយអភិវឌ្ឍន៍ដែលបានមកកម្ពុជា មានចំនួន ៦,២៧ ពាន់លានដុល្លារអាមេរិក ដោយរួមទាំងជំនួយក្នុងឆ្នាំ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ២០០៤ ផងដែរ ។

២៥ - ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅឯសន្និសីទថ្នាក់រដ្ឋមន្ត្រីស្តីពីការស្តារនិងកសាងប្រទេសកម្ពុជាឡើងវិញ ដែលបានប្រារព្ធឡើងនាខែមិថុនា ឆ្នាំ១៩៩២ នៅទីក្រុង តូក្យូ សហគមន៍អ្នកផ្តល់ជំនួយបានសន្យាផ្តល់ជំនួយចំនួន ៨៨០លានដុល្លារអាមេរិក ។ នៅក្នុងកិច្ចប្រជុំលើកទីមួយនៃគណៈកម្មាធិការអន្តរជាតិសំរាប់ការស្តារនិងកសាងប្រទេសកម្ពុជាឡើងវិញ (ICORC) ដែលបានប្រារព្ធឡើងនៅខែកញ្ញា ឆ្នាំ១៩៩៣ នាទីក្រុងប៉ារីស សហគមន៍អ្នកផ្តល់ជំនួយបានបង្កើនការសន្យាផ្តល់ជំនួយសំរាប់ឆ្នាំ១៩៩២ និង១៩៩៣ រហូតដល់ ១.០០០លានដុល្លារអាមេរិក ។ ចំណែកឯនៅក្នុងកិច្ចប្រជុំ ICORC លើកទី២ ដែលបានប្រារព្ធឡើងនៅទីក្រុងតូក្យូ នាខែមិនា ឆ្នាំ១៩៩៤ ដៃគូអភិវឌ្ឍន៍បានសន្យាផ្តល់ចំនួន ៧៧០លានដុល្លារអាមេរិក និងលើកទី៣ នៅទីក្រុងប៉ារីស នាខែមិនាឆ្នាំ១៩៩៥ ចំនួន ៥២០លានដុល្លារអាមេរិក ។ នាកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ដែលបានប្រារព្ធនៅឆ្នាំ១៩៩៦ ដៃគូអភិវឌ្ឍន៍សំខាន់ៗរបស់កម្ពុជាបានសន្យាផ្តល់ជំនួយចំនួន ៥០១លានដុល្លារអាមេរិក ហើយអង្គការមិនមែនរដ្ឋាភិបាលបានសន្យាផ្តល់ចំនួន ១៨លានដុល្លារអាមេរិក ។ នៅកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ១៩៩៧ ឆ្នាំ ១៩៩៩ ឆ្នាំ២០០០ ឆ្នាំ២០០១ ឆ្នាំ២០០២ និងឆ្នាំ២០០៤ ដៃគូអភិវឌ្ឍន៍បានសន្យាផ្តល់ជំនួយចំនួន ៤៥០លាន

ចំនួន៤៧១លាន ចំនួន៥៤៨លាន ចំនួន៥៥៦លាន ចំនួន៦៣៥លាន និង៥០៤,២លានដុល្លារអាមេរិក សំរាប់ឆ្នាំនីមួយៗជាបន្តបន្ទាប់ ដែលចំនួនទាំងនេះមិនបានគិតបញ្ចូលការសន្យារបស់អង្គការមិនមែនរដ្ឋាភិបាលឡើយ ។

**តារាងទី ១ : ការសន្យាផ្តល់ និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ: ឆ្នាំ ១៩៩២ - ២០០៣**

(លានដុល្លារអាមេរិក)

| | ១៩៩២-១៩៩៣ | ១៩៩៤-១៩៩៨ | ១៩៩៩-២០០៣ | ២០០៤ | ២០០៥ (តួលេខបឋម) | សរុប ១៩៩២-២០០៥ |
|---|---|---|---|---|---|---|
| ការសន្យាផ្តល់ជំនួយ | ១.០០០ | ២.២៨៤,២[ក] | ២.២៥៥,២[ខ] | | ៥០៤,២[គ] | ៦.០៤៣,៦[ឃ] |
| ការប្រើប្រាស់ជំនួយ | ៥៧២,១ | ២.២០៥,៩ | ២.៤០៨,៨ | ៥៥៥,៤ | ៥២៤,៩[ង] | ៦.២៦៧,០ |
| ការប្រើប្រាស់ជំនួយគិតជា % ធៀបនឹងការសន្យាផ្តល់ជំនួយ | ៥៧,២% | ៧៧,៦%[ច] | ៨២,៩%[ឆ] | | ៨២,៩%[ជ] | ៨៧,៦%[ឈ] |

[ក] មិនបានគិតបញ្ចូលទិន្នន័យឆ្នាំ ១៩៩៨ ដោយពុំមានការសន្យាផ្តល់ជំនួយ ព្រោះកិច្ចប្រជុំ CG ពុំបានប្រារព្ធធ្វើ

[ខ] មិនបានគិតបញ្ចូលទិន្នន័យឆ្នាំ ២០០៣ ដោយពុំមានការសន្យាផ្តល់ជំនួយ ព្រោះកិច្ចប្រជុំ CG ពុំបានប្រារព្ធធ្វើ

[គ] មិនបានគិតបញ្ចូលទិន្នន័យនៃការសន្យាផ្តល់ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល

[ឃ] មិនបានគិតបញ្ចូលការសន្យាផ្តល់ជំនួយក្នុងឆ្នាំ ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ២០០៤ និងការសន្យាផ្តល់ជំនួយរបស់ NGO ដោយសារគ្មានការប្រកាសសន្យា

[ង] គិតបញ្ចូលទិន្នន័យនៃការសន្យាផ្តល់ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល

[ច] មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយក្នុងឆ្នាំ ១៩៩៨ ដោយពុំមានការសន្យាផ្តល់ជំនួយ

[ឆ] មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយក្នុងឆ្នាំ ២០០៣ ដោយពុំមានការសន្យាផ្តល់ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល

[ជ] មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយឆ្នាំ១៩៩៨ និងការប្រើប្រាស់ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០០២ ដោយសារគ្មានការសន្យា

[ឈ] មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយក្នុង ក្នុងឆ្នាំ ១៩៩៨ ឆ្នាំ២០០៣ និងឆ្នាំ២០០៤ ដោយពុំមានការសន្យាផ្តល់ជំនួយ

២៦ - រាជរដ្ឋាភិបាលក៏បានកត់សំគាល់ផងដែរថា ការសន្យាផ្តល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍កម្ពុជាទ្វេភាគី និងពហុភាគីមួយចំនួនក៏បានគណនាត្រួតគ្នាដែរ ។ ការសន្យាផ្តល់ជំនួយដែលធ្វើឡើងដោយទីភ្នាក់ងារពហុភាគី ពិសេស ទីភ្នាក់ងារនៃប្រព័ន្ធអង្គការសហប្រជាជាតិ បានបង្ហាញពីធនធានសរុបដែលគេត្រូវការសំរាប់កិច្ចប្រតិបត្តិការទាំងអស់នៃកម្មវិធីនានា ដោយមិនគិតដល់ប្រភពហិរញ្ញប្បទានឡើយ ដែលក្នុងនោះកម្មវិធីខ្លះបានទទួលប្រភពទុនពីកិច្ចប្រតិបត្តិការក្នុងប្រទេសរបស់ដៃគូអភិវឌ្ឍន៍ទ្វេភាគី ។ ការសន្យាផ្តល់ជំនួយរបស់ទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគីក៏បានរាប់បញ្ចូលផងដែរ នូវមូលនិធិដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ទ្វេភាគី ដែលជាបច្ច័យនាំអោយមានការគណនាត្រួតគ្នា ។ ស្ថានភាពស្រដៀងគ្នានេះ ក៏អាចកើតមានចំពោះការផ្តល់ហិរញ្ញប្បទានសំរាប់សកម្មភាពអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរ ។

២៧ - បញ្ហាគណនាត្រួតគ្នា ក៏អាចកើតមានឡើងចំពោះទិន្នន័យនៃការប្រើប្រាស់ជំនួយដែលរាយការណ៍ដោយអ្នកផ្តល់ជំនួយទ្វេ- ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលដែរ ។ ក្នុងករណីនេះ ក.អ.ក បានព្យាយាមដោះស្រាយដោយបែងចែកទិន្នន័យនៃការប្រើប្រាស់ជំនួយរបស់ទីភ្នាក់ងារពហុភាគី ជាពីរផ្នែក គឺ ÷

- ការប្រើប្រាស់ជំនួយតាម «ការបែងចែកធនធានតាមកម្មវិធី» ដោយរាប់បញ្ចូលតំលៃសរុបនៃកម្មវិធីដែលជាធនធានផ្ទាល់របស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងធនធានដែលបានកៀងគរពីប្រភពក្នុងប្រទេសដទៃទៀត ។
- ការប្រើប្រាស់ជំនួយតាម «ធនធានផ្ទាល់» តែប៉ុណ្ណោះ ។

២៨- ចំពោះការប្រើប្រាស់ជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល(NGO)វិញ ការប៉ាន់ប្រមាណលើការប្រើប្រាស់ជំនួយដែលជា «មូលនិធិផ្ទាល់» របស់អង្គការទាំងនេះបានរៀបចំឡើងដោយពឹងផ្អែកទៅលើ ទិន្នន័យ ដែល NGO បានផ្តល់មកនាយកដ្ឋានសំរបសំរួលអង្គការមិនមែនរដ្ឋាភិបាលរបស់ ក.អ.ក/ គ.ជ.នា ។ ការប៉ាន់ស្មាននេះគឺពឹងផ្អែកលើការវិភាគទិន្នន័យនៃប្រភពមូលនិធិរបស់ NGO នីមួយៗដោយមិនរាប់បញ្ចូលវិភាគទានដែល NGO ទាំងនោះទទួលបានពីប្រភពទីភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងពហុភាគីក្នុងប្រទេសឡើយ ។

### ក្រាហ្វិកទី១ : ការសន្យាផ្តល់និងការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការ




a. មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយក្នុងឆ្នាំ១៩៩៨ (៤៣៣,៣ លានដុល្លារអាមេរិក) ដោយពុំមានការសន្យាផ្តល់ជំនួយ

b. មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយក្នុងឆ្នាំ២០០៣ (៥៣៩,៥ លានដុល្លារអាមេរិក) និងការប្រើប្រាស់ជំនួយរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងឆ្នាំ២០០២ ដោយពុំមានការសន្យាផ្តល់ជំនួយ

c. មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងឆ្នាំ២០០៥ ដោយពុំមានការសន្យាផ្តល់ជំនួយ

២៩- ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាខែធ្នូ ឆ្នាំ២០០៥ កន្លងមកនេះ ធនាគារពិភពលោកបានកែសំរួលការគណនាត្រួតគ្នាក្នុងពេលប្រកាសផ្តល់ជំនួយ ។ តួលេខកែសំរួលក្នុងតារាងទី ២ ដែលបានផ្តល់ដោយការិយាល័យធនាគារពិភពលោកប្រចាំនៅភ្នំពេញ បានបង្ហាញឱ្យឃើញអំពីការប្រកាសផ្តល់ជំនួយក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៦ សំរាប់ឆ្នាំ២០០២ និងតួលេខដែលបានកែសំរួលរួច ។ ការប្រែប្រួលតួលេខស្តីពីការប្រកាសផ្តល់ជំនួយឆ្នាំ២០០២ បានឆ្លុះបញ្ចាំងពីវិធីសាស្រ្ត ដែលត្រូវបានប្រើប្រាស់សំរាប់ការប្រកាសផ្តល់ជំនួយឆ្នាំ២០០៥ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាខែធ្នូ ឆ្នាំ២០០៤ ។ ផ្អែកតាមនិយមន័យថ្មីស្តីពីជំនួយ ដៃគូអភិវឌ្ឍន៍បានប្រកាសផ្តល់ជំនួយ ចំនួន ៥០៤,២លានដុល្លារអាមេរិក ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នា ខែធ្នូ ឆ្នាំ២០០៤ ។ ដោយផ្អែកតាមនិយមន័យថ្មីនៃជំនួយ របាយការណ៍បានបញ្ជាក់ថា ការប្រកាសផ្តល់ជំនួយសំរាប់ឆ្នាំ២០០២ បានថយចុះពី ៦៣៥លានដុល្លារអាមេរិក មកត្រឹមតែ ៥១៣,៨ លានដុល្លារអាមេរិក ប៉ុណ្ណោះ ។

**<u>តារាងទី ២</u> : ការកែតំរូវរបស់ធនាគារពិភពលោក ស្តីពីការប្រកាសជំនួយឆ្នាំ ២០០២ និង ២០០៥**

(<u>លានដុល្លារអាមេរិក</u>)

| | ការសន្យាផ្តល់ជំនួយដែលបានរាយការណ៍នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ ២០០២ | ការកែប្រែការសន្យាផ្តល់ជំនួយដោយផ្អែកលើការឯកភាពគ្នានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ ២០០៤ | ការសន្យាផ្តល់ជំនួយនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤សំរាប់ឆ្នាំ២០០៥ |
|---|---|---|---|
| **ចំនួនសន្យាសរុប** | **៦៣៥,០** | **៥១៣,៨** | **៥០៤,២** |
| • អ្នកផ្តល់ជំនួយទ្វេភាគី | ២៩៩,៧ | ២៩៩,៧ | ៣៣៥,១ |
| • ប្រទេសជាសមាជិកសហគមន៍អឺរ៉ុប | ២២,៩ | ៣២,៩ | ៤០,៤ |
| • អ្នកផ្តល់ជំនួយពហុភាគី | ៣០២,៤ | ១៨១,២ | ១២៨,៧ |
| - ធនាគារអភិវឌ្ឍន៍អាស៊ី | ១១៧,០ | ៦៤,០ | ៤៦,៦ |
| - ស្ថាប័នរូបិយវត្ថុអន្តរជាតិ | ២២,៦ | ០,០ | ០,០ |
| - ប្រព័ន្ធអង្គការសហប្រជាជាតិ | ៨៧,៨ | ៤២,២ | ៣៧,១ |
| - ធនាគារពិភពលោក | ៧៥,០ | ៧៥,០ | ៤៥,០ |

<u>ប្រភព</u>: ការិយាល័យធនាគារពិភពលោក-ភ្នំពេញ

៣០- ក្នុងរយៈពេល ៥ ឆ្នាំ ២០០១-២០០៥ ការប្រើប្រាស់ជំនួយបានកើនឡើងពី ៤៧២លានដុល្លាអាមេរិក ក្នុងឆ្នាំ ២០០១ ដល់ ៥៥៥លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៤ ហើយតាមតួលេខបឋម ការប្រើប្រាស់ជំនួយក្នុងឆ្នាំ ២០០៥ មានប្រមាណ ៥២៥លានដុល្លារអាមេរិក ។ ក្នុងរយៈពេល ៥ ឆ្នាំ ២០០១-២០០៥ អត្រាប្រើប្រាស់ជំនួយធៀបនឹងការប្រកាសផ្តល់ជំនួយបានកើនឡើង ការប្រើប្រាស់ជំនួយបានចុះថយបន្តិចពី ៧៧,៣% នាឆ្នាំ២០០១ ដល់៧៦,៤% នាឆ្នាំ២០០២ ។ អត្រាប្រើប្រាស់ជំនួយសម្រាប់ឆ្នាំ ២០០២ នឹងកើនដល់ ៩៤,៤% បើគណនាតាមតួលេខកែសម្រួលរបស់ធនាគារពិភពលោក ។ អត្រាប្រើប្រាស់ជំនួយកើនដល់

## **<u>តារាងទី ៣</u> : ការសន្យា និងការប្រើប្រាស់ជំនួយ: ឆ្នាំ ២០០១-២០០៥**

(លានដុល្លារអាមេរិក)

| ការសន្យា និងការប្រើប្រាស់ជំនួយ | ២០០១ ជាក់ស្តែង | ២០០២ ជាក់ស្តែង | ២០០៣ ជាក់ស្តែង | ២០០៤ ជាក់ស្តែង | ២០០៥[ក] បណ្តោះអាសន្ន | សរុប ឆ្នាំ ២០០១-២០០៥ ដុល្លារអាមេរិក | សរុប ឆ្នាំ ២០០១-២០០៥ ការបែងចែកជា % |
|---|---|---|---|---|---|---|---|
| **ការសន្យាផ្តល់ជំនួយនៃភាគីផ្តល់ជំនួយ** | | | | | | | |
| • ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៧៥,៦ | ៨៧,៨ | ..... | ..... | ៣៧,១ | ១៥៤,៩ | ៩,៥% |
| • ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ | ១៩៥,០ | ២១៤,៦ | ..... | ..... | ៩១,៦ | ៤២៥,៦ | ២៦,១% |
| • ប្រទេសជាសមាជិកសហគមន៍អឺរ៉ុប និងគណៈកម្មការអឺរ៉ុប | ៥២,៩ | ១១៩,២ | ..... | ..... | ១៤៣,៨ | ៣១៥,៩ | ១៩,៤% |
| • អ្នកផ្តល់ជំនួយទ្វេភាគីដោយពុំរាប់បញ្ចូលប្រទេសជាសមាជិកសហគមន៍អឺរ៉ុប | ២៣២,២ | ២១៣,៤ | ..... | ..... | ២៣១,៧ | ៦៧៧,៣ | ៤១,៦% |
| • អង្គការមិនមែនរដ្ឋាភិបាល | ៥៥,០ | (ខ) | | | (ខ) | ៥៥,០ | ៣,៤% |
| **សរុប** | **៦១០,៧** | **៦៣៥,០**[គ] | | | **៥០៤,២**[គ] | ១.៦២៨,៧[ឃ] | **១០០,០%** |
| **ការប្រើប្រាស់ជំនួយ** | | | | | | | |
| • ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៩០,៨ | ៨១,៨ | ៨៨,៣ | ៧៣,៨ | ៧១,៥ | ៤០៦,២ | ១៥,៥ |
| -ការបែងចែកតាមកម្មវិធី | ៤៤,៩ | ៤២,២ | ៤៤,២ | ៣៦,៣ | ៣៥,៦ | ២០៣,៣ | ៧,៨% |
| -ការប្រើប្រាស់ធនធានផ្ទាល់ | ១១៤,៧ | ១៤៩,២ | ១៤៩,២ | ១២៨,៥ | ១២០,៨ | ៦៦២,៤ | ២៥,៣% |
| • ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ | ១០០,៦ | ១១១,៦ | ១១៧,៤ | ១១០,៥ | ១១៣,៧ | ៥៥៣,៩ | ២១,១% |
| • ប្រទេសជាសមាជិកសហគមន៍អឺរ៉ុប និងគណៈកម្មការអឺរ៉ុប | ១៦៨,០ | ១៨២,៣ | ១៨១,៤ | ២៣០,៧ | ២១០,០ | ៩៧២,៥ | ៣៧,១% |
| • អ្នកផ្តល់ជំនួយទ្វេភាគីដោយពុំរាប់បញ្ចូលប្រទេសជាសមាជិកសហគមន៍អឺរ៉ុប | | | | | | | |
| • អង្គការមិនមែនរដ្ឋាភិបាល | ៤៣,៦ | ៤៥,៦ | ៤៧,២ | ៤៩,៤ | ៤៤,៧ | ២៣០,៥ | ៨,៨% |
| **សរុប**[ង] | **៤៧១,៨** | **៥៣០,៩** | **៥៣៩,៥** | **៥៥៥,៤** | **៥២៤,៩** | **២.៦២២,៥** | **១០០,០%** |
| **ការប្រើប្រាស់ជំនួយគិតជាភាគរយធៀបនឹងការសន្យាផ្តល់ជំនួយ** | **៧៧,៣%** | **៧៦,៤%** | | | **៩៥,២%**[ច] | **៨៨,២**[ឆ] | |

[ក] ដោយកិច្ចប្រជុំ CG មិនបានប្រារព្ធធ្វើនៅក្នុងឆ្នាំ ១៩៩៨និង២០០៣ ការសន្យាផ្តល់ជំនួយក៏ពុំមានដែរ ។ ក្នុងកិច្ចប្រជុំពិគ្រោះ យោបល់ ឆ្នាំ២០០៤ ការប្រកាសសន្យាផ្តល់ជំនួយសំរាប់ឆ្នាំ២០០៥ ផ្អែកលើការកែប្រែដែលបានឯកភាពគ្នា ។ ដូច្នេះ គ្មានការប្រកាសសន្យាផ្តល់ជំនួយសំរាប់ឆ្នាំ២០០៤ ។

[ខ] ការសន្យាផ្តល់ជំនួយពុំបានប្រកាសក្នុងកិច្ចប្រជុំ CG ឡើយ

[គ] មិនបានគិតបញ្ចូលអង្គការមិនមែនរដ្ឋាភិបាលទេ

[ឃ] មិនបានគិតបញ្ចូលទិន្នន័យក្នុងឆ្នាំ ២០០៣និង២០០៤ ឡើយ

[ង] គិតបញ្ចូលតែទិន្នន័យនៃការប្រើប្រាស់ «ធនធានផ្ទាល់» របស់ទីភ្នាក់ងារផ្តល់ជំនួយពហុភាគីប៉ុណ្ណោះ

[ច] មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងឆ្នាំ ២០០៣ទេ ដោយពុំមានការសន្យាផ្តល់ជំនួយ

[ឆ] មិនបានគិតបញ្ចូលទិន្នន័យនៃការប្រើប្រាស់ជំនួយសំរាប់ឆ្នាំ ២០០៣និង២០០៤ទេ ដោយពុំមានការសន្យាផ្តល់ជំនួយ និងការប្រើប្រាស់ជំនួយរបស់អង្គការក្រៅរដ្ឋាភិបាលសំរាប់ឆ្នាំ ២០០២ និង ២០០៥ ។

៩៥,២% នាឆ្នាំ២០០៥នេះ ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះការចតាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ហើយជឿជាក់ថា ដៃគូអភិវឌ្ឍក៏នឹងបន្តផ្តល់ការគាំទ្រថែមទៀត សំរាប់ឱ្យរាជរដ្ឋាភិបាលអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ ២០០៦-២០១០ ។

## ៣.២ ការប្រើប្រាស់ជំនួយតាមប្រភពអ្នកផ្តល់ជំនួយ

៣១- គិតចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៥ សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិបានផ្តល់ដល់កម្ពុជានូវទឹកប្រាក់សរុបប្រមាណ ៦,៣ពាន់លានដុល្លារអាមេរិក (តារាងទី៤) ។ ទឹកប្រាក់ទាំងនេះជាជំនួយរបស់:

- ប្រទេសមិនមែនជាសមាជិកនៃសហគមន៍អឺរ៉ុបចំនួន ២.៣៩២,៥លានដុល្លារអាមេរិក ឬស្មើនឹង ៣៨,២% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។
- ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិចំនួន ១.៧៧១,៦លានដុល្លារអាមេរិក ឬស្មើនឹង ២៨,៣% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។
- ប្រទេសដែលជាសមាជិកសហគមន៍អឺរ៉ុប និងគណៈកម្មការអឺរ៉ុបចំនួន ១.៥៧៨,៤លានដុល្លារអាមេរិក ឬស្មើនឹង ២៥,២% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។
- អង្គការមិនមែនរដ្ឋាភិបាលចំនួន ៥២៤,៦លានដុល្លារអាមេរិក ឬស្មើនឹង ៨,៤%នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។

៣២- ជប៉ុនគឺជាប្រទេសផ្តល់ជំនួយធំជាងគេបំផុតរបស់កម្ពុជា ។ ក្នុងចន្លោះឆ្នាំ១៩៩២-២០០៥ ប្រទេសជប៉ុនបានផ្តល់ជំនួយ២១,០% នៃជំនួយសរុប ។ ដៃគូអភិវឌ្ឍន៍ធំផ្សេងៗទៀតរួមមាន ÷

- ប្រព័ន្ធសហប្រជាជាតិបានផ្តល់ជំនួយ៥៤១,៩លានដុល្លារអាមេរិក ស្មើនឹង៨,៦%នៃជំនួយសរុប
- សហរដ្ឋអាមេរិកបានផ្តល់ជំនួយប្រមាណ ៤៤៤លានដុល្លារអាមេរិក ។ គួរកត់សំគាល់ផងដែរថា ប៉ុន្មានឆ្នាំចុងក្រោយនេះ សហរដ្ឋអាមេរិកបានផ្តល់ជំនួយអភិវឌ្ឍន៍មកប្រទេសកម្ពុជា តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ។
- ប្រទេសបារាំងបានផ្តល់ជំនួយ ៤១២,៧លានដុល្លារអាមេរិក
- គណៈកម្មការអឺរ៉ុបបានផ្តល់ជំនួយ ៤១០,១លានដុល្លារអាមេរិក
- ប្រទេសអូស្ត្រាលីបានផ្តល់ជំនួយ ២៨៦លានដុល្លារអាមេរិក
- ប្រទេសស៊ុយអែតបានផ្តល់ជំនួយ ២១០,៤លានដុល្លារអាមេរិក ។

៣៣- ក្នុងបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ) ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ឥណទានច្រើនជាងគេ ។ គិតចាប់ពីឆ្នាំ១៩៩២-២០០៥ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ឥណទានចំនួន ៦០៦,៣លានដុល្លារអាមេរិក ស្មើនឹង៩,៧%នៃជំនួយសុរប ។ រីឯការប្រើប្រាស់ជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងចន្លោះឆ្នាំ២០០១-២០០៥ បានកើនឡើងពី ៤៨,៧លាន

**តារាង ៤ : ការប្រើប្រាស់ជំនួយតាមប្រភពដៃគូអភិវឌ្ឍន៍សំខាន់ៗ** (លានដុល្លារអាមេរិក)

| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ១៩៩៩-២០០៣ | | ២០០៤ | | ២០០៥ | | សរុប ១៩៩២-២០០៥ | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារ អាមេរិក | ការបែងចែក ជាភាគរយ | ដុល្លារ អាមេរិក | ការបែងចែក ជាភាគរយ | ដុល្លារ អាមេរិក | ការបែងចែក ជាភាគរយ | ដុល្លារ អាមេរិក | ការបែងចែក ជាភាគរយ |
| **ភ្នាក់ងារអង្គការសហប្រជាជាតិ** | | | | | | | | |
| - ការបែងចែកតាមកម្មវិធីៈ សរុប | ៨៣៧,៦ | ១៨,២% | ៧៣,៨ | ១៣,៥% | ៧១,៥ | ១៣,៦% | ……… | |
| - ការប្រើប្រាស់ធនធានផ្ទាល់ | ២២៦,១ | ៩,៤% | ៣៦,៦ | ៦,៥% | ៣៥,៦ | ៦,៨ % | ៥៤១,៩ | ៨,៦% |
| **ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ** | | | | | | | | |
| -IBRD / ធនាគារពិភពលោក | ២១៣,៤ | ៨,៩% | ៤៩,៥ | ៨,៩% | ៣៦,២ | ៦,៩% | ៤៦៦,៥ | ៧,៤% |
| -មូលនិធិរូបិយវត្ថុអន្តរជាតិ | ៨១,៧ | ៣,៤% | ២,៤ | ០,៤% | ០,០ | | ១៥៦,៨ | ២,៥% |
| - ធនាគារអភិវឌ្ឍន៍អាស៊ី | ២៧៨,៤ | ១១,៦% | ៧៦,៧ | ១៣,៨% | ៨៤,៦ | ១៦,១% | ៦០៦,៣ | ៩,៧% |
| **សរុបៈ** | **៧៩៩,៦** | **៣៣,២%** | **១៦៤,៨** | **២៩,៧%** | **១៥៦,៤** | **២៩,៨%** | **១ ៧៧១,៦** | **២៨,៣%** |
| **សហគមន៍អឺរ៉ុប** | | | | | | | | |
| គណៈកម្មការ អឺរ៉ុប | ១៣៧,៥ | ៥,៧% | ១៥ | ២,៧% | ២៤,៦ | ៤,៧% | ៤១០,១ | ៦,៥% |
| បែលហ្ស៊ិក | ១៤,៦ | ០,៦% | ៥,២ | ០,៩% | ៧,២ | ១,៤% | ៤១,៧ | ០,៧% |
| ដាណឺម៉ាក | ១៨,១ | ០,៨% | ៥,៨ | ១,០% | ៤,៨ | ០,៩% | ៧៩,៩ | ១,៣% |
| ហ្វាំងឡង់ | ៦,០ | ០,៣% | ៣,៣ | ០,៦% | ៣,២ | ០,៦% | ១៥,៩ | ០,៣% |
| បារាំង | ១៣៦,៧ | ៥,៧% | ២៣,០ | ៤,១% | ២៤,២ | ៤,៦% | ៤១២,៧ | ៦,៦% |
| អាល្លឺម៉ង់ | ៦៩,៤ | ២,៩% | ១៤,១ | ២,៥% | ១៣,១ | ២,៥% | ១៤៨,៥ | ២,៤% |
| ហូឡង់ | ២១,១ | ០,៩% | ១,៦ | ០,៣% | | | ៨៤,៩ | ១,៤% |
| ន័រវែស | ៩,៦ | ០,៤% | ៣,៤ | ០,៦% | | | ៣០,៣ | ០,៥% |
| ស៊ុយអែត | ៦៤,០ | ២,៧% | ២២,០ | ៤,០% | ១៣,៦ | ២,៦% | ២១០,៤ | ៣,៤% |
| ចក្រភពអង់គ្លេស | ៥៨,១ | ២,៤% | ១៧,០ | ៣,១% | ២២,៨ | ៤,៤% | ១៤៤,១ | ២,៣% |
| **សរុបៈ** | **៥៣៥,១** | **២២,២%** | **១១០,៥** | **១៩,៩%** | **១១៣,៧** | **២១,៧%** | **១ ៥៧៨,៤** | **២៥,២%** |
| **ដៃគូអភិវឌ្ឍន៍ទ្វេភាគីសំខាន់ៗ** | | | | | | | | |
| អូស្ត្រាលី | ១០៨,២ | ៤,៥% | ២៤,៣ | ៤,៤% | ២០,១ | ៣,៨% | ២៨៦,០ | ៤,៦% |
| កាណាដា | ១៤,៧ | ០,៦% | ១,៥ | ០,៣% | ៥,៥ | ១,០% | ៥៤,៩ | ០,៩% |
| ចិន | ៣៣,២ | ១,៤ % | ៣២,៥ | ៥,៨% | ២៨,៣ | ៥,៤% | ១៤០,៧ | ២,២% |
| ជប៉ុន | ៥០០,៨ | ២០,៨% | ១០១,៨ | ១៨,៣% | ៩៥,៥ | ១៨,២% | ១ ៣១៧,២ | ២១,០% |
| ណូវែលសឺឡង់ | ៥,៧ | ០,២% | ២,៤ | ០,៤% | | | ៩,៩ | ០,២% |
| សាធារណរដ្ឋកូរ៉េ | ៣៥,៨ | ១,៥% | ២៤,១ | ៤,៣ % | ១១,៣ | ២,១% | ៧១,៥ | ១,១% |
| សហពន្ធ័រុស្ស៊ី | ២,៣ | ០,១% | ០,៤ | ០,១% | | | ១៥,៤ | ០,២% |
| ស្វីស | ៥,៤ | ០,២% | ៣,២ | ០,៦% | ២,៥ | ០,៥% | ១១,១ | ០,២% |
| សហរដ្ឋអាមេរិក | ១២០,៨ | ៥,០% | ៤០,៦ | ៧,៣% | ៤៦,៧ | ៨,៩% | ៤៤៤,០ | ៧,១% |
| ដៃគូអភិវឌ្ឍន៍ទ្វេភាគីផ្សេងទៀត | ៤,១ | ០,២% | | | | | ៤១,៧ | ០,៧% |
| **សរុប** | **៨៣០,៩** | **៣៤,៥%** | **២៣០,៧** | **៤១,៥%** | **២១០,០** | **៤០,០%** | **២ ៣៩២,៥** | **៣៨,២%** |
| **អង្គការក្រៅរដ្ឋាភិបាល** (ធនធានផ្ទាល់) | **២៤៣,២** | **១០,១%** | **៤៩,៤** | **៨,៩%** | **៤៤,៧** | **៨,៥%** | **៥២៤,៦** | **៨,៤%** |
| **ការប្រើប្រាស់ជំនួយសរុប** | **២ ៤០៨,៨** | **១០០%** | **៥៥៥,៤** | **១០០%** | **៥២៤,៩** | **១០០%** | **៦ ២៦៧,០** | **១០០%** |

## <u>តារាង ៥</u> : ការប្រើប្រាស់ជំនួយតាមប្រភពដៃគូអភិវឌ្ឍន៍សំខាន់ៗ ២០០១-២០០៥

(លានដុល្លារអាមេរិក)

| ដៃគូអភិវឌ្ឍន៍សំខាន់ៗ | ២០០១ ជាក់ស្តែង | | ២០០២ ជាក់ស្តែង | | ២០០៣ ជាក់ស្តែង | | ២០០៤ ជាក់ស្តែង | | ២០០៥ បណ្តោះអាសន្ន | | សរុបការប្រើប្រាស់ជំនួយ ២០០១-២០០៥ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % | ដុល្លារអាមេរិក | % |
| **<u>ភ្នាក់ងារអង្គការសហប្រជាជាតិ</u>** | | | | | | | | | | | | |
| - ការបែងចែកតាមកម្មវិធីៈ សរុប | ៩០,៨ | ១៩,២% | ៨១,៨ | ១៥,៤% | ៨៨,៣ | ១៦,៤% | ៧៣,៨ | ១៣,៣% | ៧១,៥ | ១៤,១% | ,,,, | |
| - ការប្រើប្រាស់ធនធានផ្ទាល់ | ៤៤,៩ | ៩,៥% | ៤២,២ | ៨,០% | ៤៤,២ | ៨,២% | ៣៦,៣ | ៦,៥% | ៣៥,៦ | ៦,៨% | ២០៣,៣ | ៧,៨% |
| **<u>ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ</u>** | | | | | | | | | | | | |
| -IBRD / ធនាគារពិភពលោក | ៤៣,១ | ៩,១% | ៤៧,២ | ៨,៩% | ៦៣,៧ | ១១,៨% | ៤៩,៥ | ៨,៩% | ៣៦,២ | ៦,៩% | ២៣៩,៦ | ៩,១% |
| -មូលនិធិរូបិយវត្ថុអន្តរជាតិ | ២៣,០ | ៤,៩% | ២៣,៥ | ៤,៤% | ១២,៣ | ២,៣% | ២,៤ | ០,៤% | ០,០ | ០,០% | ៦១,១ | ២,៣% |
| - ធនាគារអភិវឌ្ឍន៍អាស៊ី | ៤៨,៧ | ១០,៣% | ៧៨,៥ | ១៤,៨% | ៧៣,៣ | ១៣,៦% | ៧៦,៧ | ១៣,៨% | ៨៤,៦ | ១៦,១% | ៣៦១,៧ | ១៣,៨% |
| **សរុបៈ** | **១៥៩,៦** | **៣៣,៨%** | **១៩១,៤** | **៣៦,១%** | **១៩៣,៤** | **៣៥,៩%** | **១៦៤,៨** | **២៩,៧%** | **១៥៦,៤** | **២៩,៨%** | **៨៦៥,៧** | **៣៣,០%** |
| **<u>សហគមន៍អឺរ៉ុប</u>** | | | | | | | | | | | | |
| គណៈកម្មការ អឺរ៉ុប | ២២,៧ | ៤,៨% | ២៥,៨ | ៤,៩% | ៣២,៧ | ៦,១% | ១៥,០ | ២,៧% | ២៤,៦ | ៤,៧% | ១២០,៩ | ៤,៦% |
| បែលហ្ស៊ិក | ១,៣ | ០,៣% | ២,២ | ០,៤% | ៣,៧ | ០,៧% | ៥,២ | ០,៩% | ៧,២ | ១,៤% | ១៩,៦ | ០,៧% |
| ដាណឺម៉ាក | ២,៨ | ០,៦% | ៤,៨ | ០,៩% | ៤,៣ | ០,៨% | ៥,៨ | ១,០% | ៤,៨ | ០,៩% | ២២,៥ | ០,៩% |
| ហ្វាំងឡង់ | ១,២ | ០,៣% | ០,៩ | ០,២% | ០,០ | ០,០% | ៣,៣ | ០,៦% | ៣,២ | ០,៦ | ៨,៦ | ០,៣% |
| បារាំង | ៣៦,០ | ៧,៦% | ២៨,៣ | ៥,៣% | ២៥,៩ | ៤,៨% | ២៣,០ | ៤,១% | ២៤,២ | ៤,៦% | ១៣៧,៦ | ៥,២% |
| អាល្លឺម៉ង | ១០,០ | ២,១% | ១៧,២ | ៣,២% | ១៧,៦ | ៣,៣% | ១៤,១ | ២,៥% | ១៣,១ | ២,៥% | ៧២,០ | ២,៧% |
| ហូឡង់ | ៣,៦ | ០,៨% | ៣,៧ | ០,៧% | ២,៨ | ០,៥% | ១,៦ | ០,៣% | ,,, | ,,, | ១១,៧ | ០,៤% |
| ន័រវេស | ១,២ | ០,២% | ៣,៤ | ០,៦% | ២,៧ | ០,៥% | ៣,៤ | ០,៦% | ,,, | ,,, | ១០,៦ | ០,៤% |
| ស៊ុយអែត | ១៣,១ | ២,៨% | ១៣,៦ | ២,៦% | ១២,៤ | ២,៣% | ២២,៤ | ៤,០% | ១៣,៦ | ២,៦% | ៧៤,៧ | ២,៨% |
| ចក្រភពអង់គ្លេស | ៨,៧ | ១,៨% | ១១,៦ | ២,២% | ១៥,៤ | ២,៨% | ១៧,០ | ៣,១% | ២២,៨ | ៤,៤% | ៧៥,៦ | ២,៩% |
| សមាជិក សហគមន៍អឺរ៉ុបដ៏ទៃទៀត | ០ | ,,, | ០ | ,,, | ០ | ,,, | ០ | ,,, | ០ | ,,, | ០ | ,,, |
| **សរុបៈ** | **១០០,៦** | **២១,៣%** | **១១១,៦** | **២១,០%** | **១១៧,៤** | **២១,៨%** | **១១០,៥** | **១៩,៩%** | **១១៣,៧** | **២១,៧%** | **៥៥៣,៧** | **២១,១%** |
| **ដៃគូអភិវឌ្ឍន៍ទ្វេភាគីសំខាន់ៗ** | | | | | | | | | | | | |
| អូស្ត្រាលី | ១៩,៩ | ៤,២% | ១៧,៨ | ៣,៤% | ២២,៧ | ៤,២% | ២៤,៣ | ៤,៤% | ២០,១ | ៣,៨% | ១០៤,៨ | ៤,០% |
| កាណាដា | ៥,២ | ១,១% | ៣,៤ | ០,៦% | ២,៦ | ០,៥% | ១,៥ | ០,៣% | ៥,៥ | ១,០% | ១៨,២ | ០,៧% |
| ចិន | ១៦,៣ | ៣,៥% | ៥,៧ | ១,១% | ៥,៦ | ១,០% | ៣២,៥ | ៥,៨% | ២៨,៣ | ៥,៤% | ៨៨,៤ | ៣,៤% |
| ជប៉ុន | ១០០,០ | ២១,២% | ១០៥,៦ | ១៩,៩% | ១០១,២ | ១៨,៨% | ១០១,៨ | ១៨,៣% | ៩៥,៥ | ១៨,២% | ៥០៤,០ | ១៩,២% |
| ណូវែលសឺឡង់ | ០,៧ | ០,២% | ១,៣ | ០,២% | ១,៩ | ០,៤% | ២,៤ | ០,៤% | ,,, | ,,, | ៦,៤ | ០,២% |
| សាធារណរដ្ឋកូរ៉េ | ១,២ | ០,៣% | ២២,៥ | ៤,២% | ១០,៣ | ១,៩% | ២៤,១ | ៤,៣% | ១១,៣ | ២,១% | ៦៩,៤ | ២,៦% |
| សហពន្ធ័រុស្ស៊ី | ០,៣ | ០,១% | ០,៣ | ០,១% | ០,៤ | ០,១% | ០,៤ | ០,១% | ,,, | ,,, | ១,៤ | ០,១% |
| ស្វីស | ០ | ,,, | ២,៩ | ០,៦% | ២,៥ | ០,៥% | ៣,២ | ០,៦% | ២,៥ | ០,៥% | ១១,១ | ០,៤% |
| សហរដ្ឋអាមេរិច | ២៣,៨ | ៥,១% | ២២,១ | ៤,២% | ៣៤,៣ | ៦,៤% | ៤០,៦ | ៧,៣% | ៤៦,៧ | ៨,៩% | ១៦៧,៦ | ៦,៤% |
| ដៃគូអភិវឌ្ឍន៍ទ្វេភាគីផ្សេងទៀត | ០,៤ | ០,១% | ០,៧ | ០,១% | ,,, | ,,, | ,,, | ,,, | ,,, | ,,, | ៤១,៧ | ០,០% |
| **<u>សរុប</u>** | **១៦៨,០** | **៣៥,៦%** | **១៨២,៣** | **៣៤,៣%** | **១៨១,៤** | **៣៣,៦%** | **២៣០,៧** | **៤១,៥%** | **២១០,០** | **៤០,០%** | **៩៧២,៥** | **៣៧,១%** |
| **<u>អង្គការក្រៅរដ្ឋាភិបាល (</u>ធនធានផ្ទាល់)** | **៤៣,៦** | **៩,២%** | **៤៥,៦** | **៨,៦%** | **៤៧,២** | **៨,៨%** | **៤៩,៤** | **៨,៩%** | **៤៤,៧** | **៨,៥%** | **២៣០,៥** | **៨,៨%** |
| **<u>ការប្រើប្រាស់ជំនួយសរុប</u>** | **៤៧១,៨** | **១០០%** | **៥៣០,៩** | **១០០%** | **៥៣៩,៥** | **១០០%** | **៥៥៥,៤** | **១០០%** | **៥២៤,៩** | **១០០%** | **២,៦២២,៥** | **១០០%** |

ដុល្លារអាមេរិកនាឆ្នាំ២០០១ ដល់៧៦,៧លានដុល្លារអាមេរិកនាឆ្នាំ២០០៥ (តារាងទី៥) ។ ចំពោះឥណទានផ្តល់ដោយធនាគារពិភពលោកក្នុងចន្លោះឆ្នាំ១៩៩២-២០០៥ មានចំនួន ៤៦៦,៦លានដុល្លារអាមេរិក ស្មើ នឹង ៧,៤%នៃជំនួយសរុប ។ ក្នុងឆ្នាំ២០០៥ ការប្រើប្រាស់ជំនួយរបស់ធនាគារពិភាពលោក មានចំនួន ៣៦,២លានដុល្លាអាមេរិក ។

៣៤- ពតិមានលំអិតស្តីពីការប្រើប្រាស់ជំនួយរបស់ដៃគូអភិវឌ្ឍន៍សំខាន់ៗ មានបង្ហាញក្នុងឧបសម្ព័ន្ធទី៣ ។

## ៣.៣ ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌនៃជំនួយ

៣៥- ក្នុងចន្លោះឆ្នាំ១៩៩២-២០០៥ ជំនួយឥតសំណងមានប្រមាណជា ៧៧,៣% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបដែលបានប្រើប្រាស់ ។ ទោះជាយ៉ាងណាក៏ដោយយើងសង្កេតឃើញថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សមាមាត្រនៃការប្រើប្រាស់ប្រាក់កម្ចីប្រៀបធៀបនឹងជំនួយអភិវឌ្ឍន៍ផ្លូវការសរុបមានការកើនឡើង ។

**តារាងទី ៦: ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌរបស់ជំនួយ**

(លានដុល្លារអាមេរិក)

| លក្ខខ័ណ្ឌរបស់ជំនួយ | ១៩៩៩ -២០០៣ | | ២០០៤ | | ២០០៥ | | សរុប ១៩៩២-២០០៥ | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % |
| ជំនួយឥតសំណង | ១.៧៦៩,៥ | ៧៣,៥ | ៣៦៧,២ | ៦៦,១ | ៣៧០,៧ | ៧០,៦ | ៤.៨៤៣ | ៧៧,៣ |
| កម្ចី | ៦៣៩,២ | ២៦,៥ | ១៨៨,២ | ៣៣,៩ | ១៥៤,២ | ២៩,៤ | ១.៤២៤ | ២២,៧ |
| សរុប | ២.៤០៨,៨ | ១០០,០ | ៥៥៥,៤ | ១០០,០ | ៥២៤,៩ | ១០០,០ | ៦.២៦៧ | ១០០,០ |

**ក្រាហ្វិកទី២ : ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌ ឆ្នាំ ១៩៩២-២០០៥**



# <u>តារាងទី ៧</u>: ការប្រើប្រាស់ជំនួយតាមលក្ខខ័ណ្ឌ និងតាមប្រភពអ្នកផ្តល់ជំនួយ: ឆ្នាំ ២០០១ - ២០០៥

(លានដុល្លារអាមេរិក)

| លក្ខខ័ណ្ឌរបស់ជំនួយ | ២០០១ ជាក់ស្តែង | | ២០០២ ជាក់ស្តែង | | ២០០៣ ជាក់ស្តែង | | ២០០៤ ជាក់ស្តែង | | ២០០៥ បណ្តោះអាសន្ន | | សរុប ២០០១-២០០៥ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារ អាមេរិក | ជា % | ដុល្លារ អាមេរិក | ជា % | ដុល្លារ អាមេរិក | ជា % | ដុល្លារ អាមេរិក | ជា % | ដុល្លារ អាមេរិក | ជា % | ដុល្លារ អាមេរិក | ជា % |
| **<u>ជំនួយឥតសំណង</u>**<br>ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៤០,៩ | ៨,៧% | ៣៩,២ | ៧,៤% | ៣៩,៩ | ៧,៤% | ៣១,៣ | ៥,៦% | ៣១,៥ | ៦,០% | ១៨២,៨ | ៧,០% |
| ស្ថាបន័ហិរញ្ញវត្ថុអន្តរជាតិ | ០,០ | ០,០% | ០,៩ | ០,២% | ០ ,៦ | ០ ,១% | ៣,៧ | ០,៧% | ២,១ | ០,៤% | ៧,៤ | ០,៣% |
| ប្រទេសជាសមាជិកសហគមន៍អឺរ៉ុបនិងគណៈកម្មការអឺរ៉ុប | ១០០,៦ | ២១,៣% | ១១១,៦ | ២១,០% | ១១៧,៤ | ២១,៨% | ១១០,៥ | ១៩,៩% | ១១៣,៧ | ២១,៧% | ៥៥៣.៩ | ២១,១% |
| អ្នកផ្តល់ជំនួយទ្វេភាគី ដោយពុំរាប់បញ្ចូលប្រទេសជាសមាជិកសហគមន៍អឺរ៉ុប | ១៦១,៩ | ៣៤,៣% | ១៥០,៤ | ២៨,៣% | ១៦៨,៣ | ៣១,២% | ១៧២,២ | ៣១,០% | ១៧៨,៦ | ៣៤,០% | ៨៣១,៣ | ៣១,៧% |
| អង្គការមិនមែនរដ្ឋាភិបាល | ៤៣,៦ | ៩,២% | ៤៥,៦ | ៨,៦% | ៤៧,២ | ៨,៨% | ៤៩,៤ | ៨,៩% | ៤៤,៧ | ៨,៥% | ២៣០,៥ | ៨,៨% |
| **សរុប** | **៣៤៧,០** | **៧៣,៥%** | **៣៤៧,៧** | **៦៥,៥%** | **៣៧៣,៤** | **៦៩,២%** | **៣៦៧,២** | **៦៦,១%** | **៣៧០,៧** | **៧០,៦%** | **១.៨០៥,៩** | **៦៨,៩%** |
| **<u>កម្ចី</u>**<br>ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៤,០ | ០,៩% | ៣.១ | ០,៦% | ៤,៣ | ០,៨% | ៥.០ | ០,៩% | ៤.១ | ០,៨% | ២០.៥ | ០,៨% |
| ស្ថាបន័ហិរញ្ញវត្ថុអន្តរជាតិ | ១១៤,៧ | ២៤,៣% | ១៤៨,៣ | ២៧,៩% | ១៤៨,៦ | ២៧,៦% | ១២៤,៧ | ២២,៥% | ១១៨,៦ | ២២,៦% | ៦៥៥,០ | ២៥,០% |
| ប្រទេសជាសមាជិកសហគមន៍អឺរ៉ុបនិងគណៈកម្មការអឺរ៉ុប | ០,០ | ០,០% | ០,០ | ០,០% | ០,០ | ០,០% | ០,០ | | | | ០,០ | ០,០% |
| អ្នកផ្តល់ជំនួយទ្វេភាគី ដោយពុំរាប់បញ្ចូលប្រទេសជាសមាជិកសហគមន៍អឺរ៉ុប | ៦,១ | ១,៣% | ៣១,៩ | ៦,០% | ១៣,២ | ២,៤% | ៥៨,៥ | ១០.៥% | ៣១,៥ | ៦,០% | ១៤១,១ | ៥,៤% |
| អង្គការមិនមែនរដ្ឋាភិបាល | ០,០ | ០,០% | ០,០ | ០,០% | ០,០ | ០,០% | ០,០ | | | | ០,០ | ០,០% |
| **សរុប** | **១២៤,៩** | **២៦,៥%** | **១៨៣,២** | **៣៤,៥%** | **១៦៦,១** | **៣០,៨%** | **១៨៨,២** | **៣៣,៩%** | **១៥៤,២** | **២៩,៤%** | **៨១៦,៦** | **៣១,១%** |
| **<u>សរុប</u>**<br>ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ៤៤,៩ | ៩,៥% | ៤២,២ | ៨,០% | ៤៤,២ | ៨,២% | ៣៦,៣ | ៦,៥% | ៣៥,៦ | ៦,៨% | ២០៣,៣ | ៧,៨% |
| ស្ថាបន័ហិរញ្ញវត្ថុអន្តរជាតិ | ១១៤,៧ | ២៤,៣% | ១៤៩,២ | ២៨,១% | ១៤៩,៣ | ២៧,៧% | ១២៨,៥ | ២៣,១% | ១២០,៨ | ២៣,០% | ៦៦២,៤ | ២៥,៣% |
| ប្រទេសជាសមាជិកសហគមន៍អឺរ៉ុបនិងគណៈកម្មការអឺរ៉ុប | ១០០,៦ | ២១,៣% | ១១១,៦ | ២១,០% | ១១៧,៤ | ២១,៨% | ១១០,៥ | ១៩,៩% | ១១៣,៧ | ២១,៧% | ៥៥៣,៩ | ២១,១% |
| អ្នកផ្តល់ជំនួយទ្វេភាគី ដោយពុំរាប់បញ្ចូលប្រទេសជាសមាជិកសហគមន៍អឺរ៉ុប | ១៦៨,០ | ៣៥,៦% | ១៨២,៣ | ៣៤,៣% | ១៨១,៤ | ៣៣,៦% | ២៣០,៧ | ៤១,៥% | ២១០,០ | ៤០,០% | ៩៧២,៥ | ៣៧,១% |
| អង្គការមិនមែនរដ្ឋាភិបាល | ៤៣,៦ | ៩,២% | ៤៥,៦ | ៨,៦% | ៤៧,២ | ៨,៨% | ៤៩,៤ | ៨,៩% | ៤៤,៧ | ៨,៥% | ២៣០,៥ | ៨,៨% |
| **សរុប** | **៤៧១,៨** | **១០០%** | **៥៣០,៩** | **១០០%** | **៥៣៩,៤** | **១០០%** | **៥៥៥,៤** | **១០០%** | **៥២៤,៩** | **១០០%** | **២.៦២២,៥** | **១០០%** |

## ក្រាហ្វិកទី៣ : ការប្រើប្រាស់ជំនួយតាមលក្ខខណ្ឌ និងតាមប្រភពនៃអ្នកផ្តល់ជំនួយ ឆ្នាំ ២០០១-២០០៥

### ជំនួយឥតសំណង




### កម្ចី




សមាសភាគនៃកម្ចីធៀបនឹងជំនួយអភិវឌ្ឍន៍ផ្លូវការសរុបមានចំនួន ២៦,៥% នៃការប្រើប្រាស់ជំនួយសរុប នៅក្នុងអាណត្តិទីពីរនៃរាជរដ្ឋាភិបាល ១៩៩៩-២០០៣ (តារាងទី៦) ។ សមាសភាគនៃកម្ចីបានកើនដល់ ៣៣,៩% នៃការប្រើប្រាស់ជំនួយសរុបឆ្នាំ ២០០៤ ហើយក៏បានធ្លាក់មកត្រឹម ២៩,៤% នៃការប្រើប្រាស់ជំនួយសរុប នាឆ្នាំ ២០០៥ ។

៣៦ - ជារួម ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក ១៩៩៩-២០០៣ យើងសង្កេតឃើញថាសមាសភាពនៃកម្ចី និងជំនួយឥតសំណងនៅក្នុងជំនួយអភិវឌ្ឍន៍សរុប មានការផ្លាស់ប្តូរគួរអោយកត់សំគាល់ ។ ភាគរយនៃកម្ចីធៀបនឹងជំនួយអភិវឌ្ឍន៍ផ្លូវការបានកើនឡើងពី ២៦,៥%ក្នុងឆ្នាំ២០០១ រហូតដល់ ៣៤,៥%ក្នុងឆ្នាំ២០០២ (តារាងទី៧) ។ ប៉ុន្តែ និន្នាការនេះបានផ្លាស់ប្តូរវិញនៅក្នុងឆ្នាំ២០០៣ ដោយសមាមាត្រនៃប្រាក់កម្ចីបានធ្លាក់មក ៣០,៤%នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។ បន្ទាប់មក បានកើនឡើងវិញ នាឆ្នាំ២០០៤ ដល់ ៣៣,៩% ហើយក៏បានថយចុះវិញដល់ ២៩,៤% នាឆ្នាំ២០០៥ ។ ការកើនឡើងនៃការប្រើប្រាស់ប្រាក់កម្ចីគឺជាសញ្ញានៃការប៉ះពាល់ដល់ថវិកាជាតិនាពេលអនាគត ពីព្រោះថាវានឹងជះឥទ្ធិពលដល់ការកើនឡើងនូវទំហំបំណុលជាតិ និងការបង់កំរៃសេវានានាសំរាប់ការសងបំណុលនោះ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងតាមដាននិងត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវការផ្តល់ហិរញ្ញប្បទានដល់កម្មវិធី និងគំរោងអភិវឌ្ឍន៍ទាំងឡាយដែលប្រើប្រាស់ប្រាក់កម្ចី ។ លើសពីនេះ ក្រសួងត្រូវត្រួតពិនិត្យឡើងវិញយ៉ាងល្អិតល្អន់នូវរាល់សំណើកម្មវិធី/គំរោងអភិវឌ្ឍន៍ណាដែលសុំហិរញ្ញប្បទានតាមរូបភាពកម្ចី ដោយចាត់ទុកថាការត្រួតពិនិត្យនេះគឺជាសមាសភាគមួយនៃការកំណត់អាទិភាព និងការសំរេចផ្តល់ហិរញ្ញប្បទាន ។ ក្នុងក៏រិតអភិវឌ្ឍន៍សព្វថ្ងៃ នេះរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពយ៉ាងខ្ពស់ ទៅលើការធានាឱ្យបាន នូវហិរញ្ញប្បទាននៃកម្មវិធី និងគំរោងអភិវឌ្ឍន៍នានា តាមរយៈការប្រើប្រាស់ជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ ។

## ៣.៤ ការប្រើប្រាស់ជំនួយតាមប្រភេទ និងតាមលក្ខខ័ណ្ឌនៃជំនួយ

៣៧ - ដៃគូអភិវឌ្ឍន៍ក្នុងកិច្ចសហប្រតិបត្តិការបានរាយការថាជំនួយដែលផ្តល់មកប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩៩២ រហូតមកដល់បច្ចុប្បន្នសរុបប្រមាណ ៦,៣ ពាន់លានដុល្លារអាមេរិក ។ ការបែងចែកការប្រើប្រាស់ជំនួយតាមប្រភេទ និងតាមលក្ខខ័ណ្ឌ មានដូចខាងក្រោម (សូមពិនិត្យតារាងទី៨) :

- កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធមានចំនួន ២,៤ ពាន់លានដុល្លារអាមេរិក ស្មើនឹង ៣៧,៧% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។ ស្ទើរតែទាំងអស់នៃជំនួយប្រភេទនេះគឺជាជំនួយឥតសំណង ។
- ជំនួយគំរោងវិនិយោគមានចំនួន ២,២ ពាន់លានដុល្លារអាមេរិក ស្មើនឹង ៣៥,៩% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ដែលក្នុងនោះជិត ៤៧ % នៃជំនួយប្រភេទនេះគឺជាកម្ចី ។
- ជំនួយម្ហូបអាហារនិងសង្គ្រោះបន្ទាន់មានចំនួន ៦៧០ លានដុល្លារអាមេរិក សមាមាត្រទៅនឹង ១០,៧ % នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។ ជំនួយនេះគឺសុទ្ធសឹងតែជាជំនួយឥតសំណង ។
- ជំនួយទ្រទ្រង់ថវិកានិងជញ្ជីងទូទាត់មានចំនួន ៤៩១,៦លានដុល្លារអាមេរិក សមាមាត្រទៅនឹង ៧,៨% នៃជំនួយ អភិវឌ្ឍន៍ផ្លូវការសរុប ។ ជាងពីរភាគបីនៃជំនួយប្រភេទគឺជាកម្ចី និងតិចជាងមួយភាគបីគឺជាជំនួយឥតសំណង ។

- កិច្ចសហប្រតិបត្តិការបច្ចេកទេសសំរាប់គំរោងវិនិយោគមានចំនួន ៤៨៤,៥លានដុល្លារអាមេរិក ស្មើនឹង ៧,៧% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។ មួយផ្នែកតូចនៃជំនួយប្រភេទនេះ គឺជាកម្ចី (៥,៣%) ចំណែកឯផ្នែកដែលសេសសល់គឺជាជំនួយឥតសំណង ។

៣៨- ក្នុងចន្លោះឆ្នាំ ១៩៩២-២០០៥ សមាសភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការតាមប្រភេទជំនួយមានការប្រែប្រួលគួរឱ្យកត់សំគាល់ ។ ប្រភេទជំនួយ «កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ» បានកើនជាលំដាប់ពី ២០,៥% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ក្នុងឆ្នាំ ១៩៩២ និង១៩៩៣ ដល់ ៤០,២% ក្នុងកំឡុងឆ្នាំ ១៩៩៤-១៩៩៨ និង ៤៤,១% ក្នុងកំឡុងឆ្នាំ១៩៩៩-២០០៣ ។ បើតាមរបាយការណ៍នៅក្នុងឆ្នាំ២០០៤ ការប្រើប្រាស់ជំនួយសរុបបានធ្លាក់ចុះដល់ ៣១,៩% និងកើនឡើងវិញម្តងទៀតទៅដល់ ៣៤,៧% ក្នុងឆ្នាំ ២០០៥ ។ ដោយឡែកប្រភេទ «ជំនួយគំរោងវិនិយោគ» មានការកើនឡើងជាលំដាប់ពី ១៧,៥% ក្នុងឆ្នាំ ១៩៩២ និង ១៩៩៣ដល់ ៣៤,២% ក្នុងឆ្នាំ១៩៩៤-១៩៩៨ និង ៣៦,២% ក្នុងឆ្នាំ១៩៩៩-២០០៣ ។ ប្រភេទនៃជំនួយនេះមានចំនួន ៤៦,៩% និង ៤៩,៨% នៃការប្រើប្រាស់សរុបក្នុងឆ្នាំ ២០០៤ និង២០០៥ ។ ទោះជាយ៉ាងណាក្តីក៏មួយផ្នែកធំនៃជំនួយសំរាប់គំរោងវិនិយោគ ត្រូវបានហិរញ្ញប្បទានដោយកម្ចី (៥៧,៩% នៃប្រភេទជំនួយនេះក្នុងឆ្នាំ ១៩៩៩-២០០៣ និង ៧២,២ % ក្នុងឆ្នាំ ២០០៤ និង ៥៩% ក្នុងឆ្នាំ ២០០៥) ។

៣៩- ក្នុងចន្លោះឆ្នាំ១៩៩២-២០០៥ កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ និងជំនួយសំរាប់គំរោងវិនិយោគបានស្រូបយកបរិមាណជំនួយច្រើនជាងគេ គឺប្រមាណ ៧៣,៦% នៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។ គួរកត់សំគាល់ឃើញដែរថា កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធភាគច្រើនជាជំនួយឥតសំណង ។ ចំណែកឯជំនួយសំរាប់គំរោងវិនិយោគវិញ មានប្រភពពីប្រាក់កម្ចីផង និងពីជំនួយឥតសំណងផង ។ សូមមើលតារាងលំអិតក្នុងឧបសម្ព័ន្ធទី៤ ស្តីអំពីទិន្នន័យនៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមប្រភេទ និងតាមលក្ខខ័ណ្ឌប្រចាំឆ្នាំ ក្នុងចន្លោះឆ្នាំ១៩៩២-២០០៥ ។

៤០- ក្នុងចន្លោះឆ្នាំ ២០០១ -២០០៥ ជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានប្រើប្រាស់ដូចខាងក្រោម :

- ជំនួយសំរាប់គំរោងវិនិយោគមានសមាមាត្រខ្ពស់ជាងគេស្មើនឹង ៤៣, ៣%នៃជំនួយអភិវឌ្ឍន៍ ផ្លូវការក្នុងចន្លោះឆ្នាំ២០០១-២០០៥ (តារាងទី៩) ។ ជំនួយសំរាប់គំរោងវិនិយោគរួមជាមួយ ជំនួយកិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធមានចំនួន ៨០%នៃជំនួយអភិវឌ្ឍន៍សរុប ក្នុងចន្លោះឆ្នាំ២០០១-២០០៥ ។ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ជំនួយសំរាប់គំរោងវិនិយោគមានការកើនឡើងជាបន្តបន្ទាប់ ពី ១៨៩,៨លានដុល្លារអាមេរិក ស្មើនឹង ៤០,២% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ក្នុងឆ្នាំ២០០១ ដល់ ២៦១,២លានដុល្លារអាមេរិក ស្មើនឹង៤៩,៨% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបក្នុងឆ្នាំ ២០០៥ ។ មួយភាគធំនៃជំនួយប្រភេទនេះកំពុងត្រូវបានហិរញ្ញប្បទានដោយកម្ចី ស្មើនឹង៥១,៣%ក្នុងឆ្នាំ ២០០១ និង ៧១,៨% ក្នុងឆ្នាំ២០០២ ហើយនឹង ៥៩,៣% ក្នុងឆ្នាំ២០០៣ និង ៧២,២% ក្នុងឆ្នាំ២០០៤ ព្រមទាំងង ៥៩% ក្នុងឆ្នាំ២០០៥ ។

## តារាងទី ៨: ការប្រើប្រាស់ជំនួយតាមប្រភេទ និងតាមលក្ខខណ្ឌ

(លានដុល្លារអាមេរិក)

| ប្រភេទរបស់ជំនួយ | លក្ខខណ្ឌរបស់ជំនួយ | ១៩៩៩ និង ២០០៣ | | ២០០៤ | | ២០០៥ | | សរុប ការប្រើប្រាស់ជំនួយ ១៩៩២-២០០៥ | |
|---|---|---|---|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ការបែងចែកជាភាគរយ | ដុល្លារអាមេរិក | ការបែងចែកជាភាគរយ | ដុល្លារអាមេរិក | ការបែងចែកជាភាគរយ | ដុល្លារអាមេរិក | ការបែងចែកជាភាគរយ |
| ជំនួយបច្ចេកទេសសុទ្ធសាធ | ជំនួយឥតសំណង | ៩៩៧,៨ | ៤៤,១ | ១៧៧,១ | ៣១,៩ | ១៨២,២ | ៣៤,៧ | ២. ៣៤៧,៧ | ៣៧,៥ |
| | កម្ចី | ០,០ | ០,០ | ០,០ | | ០,១ | ០,០ | ១៣,៨ | ០,២ |
| | សរុប | ៩៩៧,៨ | ៤៤,១ | ១៧៧,១ | ៣១,៩ | ១៨២,២ | ៣៤,៧ | ២. ៣៦១,៥ | ៣៧,៧ |
| ជំនួយបច្ចេកទេសសំរាប់វិនិយោគ | ជំនួយឥតសំណង | ១៥២,៤ | ៦,៣ | ៨៦,៤ | ១៥,៦ | ៥៦,៣ | ១០,៧ | ៤៥៨,៧ | ៧,៣ |
| | កម្ចី | ២៣,៨ | ១,០ | ០,០ | | | | ២៥,៨ | ០,៤ |
| | សរុប | ១៧៦,២ | ៧,៣ | ៨៦,៤ | ១៥,៦ | ៥៦,៣ | ១០,៧ | ៤៨៤,៥ | ៧,៧ |
| ជំនួយគំរោងវិនិយោគ | ជំនួយឥតសំណង | ៣៦៧,៤ | ១៥,៣ | ៧២,៦ | ១៣,១ | ១០៧,១ | ២០,៤ | ១.១៩០,៥ | ១៩,០ |
| | កម្ចី | ៥០៤,៩ | ២១,០ | ១៨៨,២ | ៣៣,៩ | ១៥៤,១ | ២៩,៤ | ១.០៥៨,៦ | ១៦,៩ |
| | សរុប | ៨៧២,២ | ៣៦,២ | ២៦០,៨ | ៤៦,៩ | ២៦១,២ | ៤៩,៨ | ២.២៤៩,០ | ៣៥,៩ |
| ជំនួយទ្រទ្រង់ថវិកា/តុល្យភាពជញ្ជីងទូទាត់ | ជំនួយឥតសំណង | ៨០,៨ | ៣,៤ | ៦,៤ | ១,១ | ២,៧ | ០,៥ | ១៦៥,៧ | ២,៦ |
| | កម្ចី | ១១០,៦ | ៤,៦ | ០,០ | | | | ៣២៥,៨ | ៥,២ |
| | សរុប | ១៩១,៤ | ៧,៩ | ៦,៤ | ១,១ | ២,៧ | ០,៥ | ៤៩១,៦ | ៧,៨ |
| ជំនួយម្ហូបអាហារ និងសង្គ្រោះបន្ទាន់ | ជំនួយឥតសំណង | ១៧១,១ | ៧,១ | ២០,២ | ៣,៦ | ១៧,១ | ៣,៣ | ៦៧០,៤ | ១០,៧ |
| | កម្ចី | ០,០ | ០,០ | ០,០ | | | | ០,០ | |
| | សរុប | ១៧១,១ | ៧,១ | ២០,២ | ៣,៦ | ១៧,១ | ៣,៣ | ៦៧០,៤ | ១០,៧ |
| មិនបានធ្វើរបាយការណ៍ | ជំនួយឥតសំណង | ០,០ | ០,០ | ៤,៦ | ០,៨ | ៥,៣ | ១,០ | ១០,០ | ០,២ |
| | កម្ចី | ០,០ | ០,០ | ០,០ | | | | ០,០ | |
| | សរុប | ០,០ | ០,០ | ៤,៦ | ០,៨ | ៥,៣ | ១,០ | ១០,០ | ០,២ |
| **ការប្រើប្រាស់ជំនួយសរុប** | ជំនួយឥតសំណង | **១.៧៦៩,៥** | **៧៣,៥** | **៣៦៧,២** | **៦៦,១** | **៣៧០,៧** | **៧០,៦** | **៤.៨៤៣,០** | **៧៧,៣** |
| | កម្ចី | **៦៣៩,២** | **២៦,៥** | **១៨៨,២** | **៣៣,៩** | **១៥៤,២** | **២៩,៤** | **១.៤២៤,០** | **២២,៧** |
| | សរុប | **២.៤០៨,៨** | **១០០,០** | **៥៥៥,៤** | **១០០,០** | **៥២៤,៩** | **១០០,០** | **៦.២៦៧,០** | **១០០,០** |

- ជំនួយកិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ មានសមាមាត្រខ្ពស់ទី២ គឺមានចំនួន ៣៦,២% នៃជំនួយអភិវឌ្ឍន៍សរុប និងស្មើរជាជំនួយឥតសំណងទាំងអស់ (តារាងទី៩) ។ តាមទិន្នន័យផ្តល់ដោយដៃគូអភិវឌ្ឍន៍ យើងសង្កេតឃើញថាសមាមាត្រនៃជំនួយកិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ មានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ។ ក្នុងឆ្នាំ ២០០១ ជំនួយប្រភេទនេះមានចំនួន ៣៧,៣%នៃជំនួយអភិវឌ្ឍន៍ទាំងអស់ ហើយសមាមាត្រនៃការប្រើប្រាស់ជំនួយនេះមានការធ្លាក់ចុះមកដល់៤២,៩% ក្នុងឆ្នាំ២០០២ មកត្រឹម ៣៤,៤% ក្នុងឆ្នាំ២០០៣ និង ៣១,៩% ក្នុងឆ្នាំ២០០៤ ។ និន្នាការនេះមានការផ្លាស់ប្តូរវិញ ក្នុងឆ្នាំ២០០៥ ដោយជំនួយនេះបានកើន

## ក្រាហ្វិកទី៤ : ការប្រើប្រាស់ជំនួយ តាមប្រភេទ និងតាមលក្ខខ័ណ្ឌ

### ១៩៩២ - ២០០៥




### ១៩៩៩ - ២០០៣




### ២០០៤




### ២០០៥



ឡើងវិញដល់៣៤,៧% នៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ។ គួរកត់សំគាល់ផងដែរថា ទំហំនៃប្រភេទជំនួយនេះមានការប្រែប្រួលបែបនេះ ដោយសារការធ្វើចំណាត់ថ្នាក់មិនបានត្រឹមត្រូវ ពេលដែលដៃគូអភិវឌ្ឍន៍រាយការណ៍អំពីប្រភេទជំនួយនេះ ។ ក្នុងឆ្នាំខាងមុខ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងពិនិត្យរបាយការណ៍នេះឡើងវិញ ដើម្បីមានពត៌មានប្រាកដប្រជានិងអាចទុកចិត្តបាន ។

- ជំនួយកិច្ចសហប្រតិបត្តិការបច្ចេកទេសសំរាប់គំរោងវិនិយោគ មានសមាមាត្រខ្ពស់ចំណាត់ថ្នាក់ ទី៣ គឺមានចំនួន ១០,៦% នៃជំនួយអភិវឌ្ឍន៍សរុប ។ ការប្រើប្រាស់ជំនួយប្រភេទនេះ បានកើនឡើងជាបន្តបន្ទាប់ពី ២៦,៣លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០១ រហូតដល់ ៨៦,៤លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៤ ។ ក្នុងឆ្នាំ២០០៥ ការប្រើប្រាស់ជំនួយប្រភេទនេះបានថយចុះមកត្រឹម ៥៦,៣លានដុល្លារអាមេរិក វិញ ។
- ជំនួយទ្រទ្រង់ថវិកានិងជញ្ជីងទូទាត់ បានថយចុះពី ៨៦លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០១ មក ត្រឹម ២,៧លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ ។
- ជំនួយអភិវឌ្ឍន៍ផ្លូវការជាជំនួយម្ហូបអាហារនិងសង្គ្រោះបន្ទាន់ មានប្រមាណ ៤,៧% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបដែលបានប្រើប្រាស់ក្នុងចន្លោះឆ្នាំ២០០១-២០០៥ ។ ក្នុងកំឡុងពេលដដែល ការប្រើប្រាស់ជំនួយប្រភេទនេះមានការប្រែប្រួលយ៉ាងខ្លាំង គឺមានបរិមាណតិចបំផុត ប្រមាណ ១៧,១លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៥ ។ ប៉ុន្តែ ជំនួយប្រភេទនេះមានទំហំច្រើន ចំនួន ៣៣,៦លានដុល្លារអាមេរិក នាឆ្នាំ២០០១ នៅនាឆ្នាំនោះ ប្រទេសកម្ពុជាបានជួបប្រទះគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរ ។

៤១- ជំនួយរបស់ដៃគូអភិវឌ្ឍន៍សំខាន់ៗទៅតាមប្រភេទនៃជំនួយផ្សេងៗគ្នា នៅក្នុងឆ្នាំ ២០០៤ និង ២០០៥ មានដូចខាងក្រោម :

- <u>កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ</u> : របាយការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការសរុបរបស់ដៃគូអភិវឌ្ឍន៍ បានបង្ហាញថា ការប្រើប្រាស់ជំនួយប្រភេទនេះចំនួន ១៧៧,១លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៤ និង ១៨២,២លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥ ។ ដៃគូអភិវឌ្ឍន៍ដែលបានផ្តល់ជំនួយប្រភេទនេះ នាឆ្នាំ២០០៤ មាន ÷ អង្គការមិនមែនរដ្ឋាភិបាល សហរដ្ឋអាមេរិក ភ្នាក់ងារនៃអង្គការសហប្រជាជាតិ អាល្លឺម៉ង់ សហគមន៍អឺរ៉ុប និងចក្រភពអង់គ្លេស ។ រីឯក្នុងឆ្នាំ ២០០៥ វិញដៃគូអភិវឌ្ឍន៍សំខាន់ៗមាន ÷ សហរដ្ឋអាមេរិក អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារសហប្រជាជាតិ សហគមន៍អឺរ៉ុប បារាំង និងចក្រភពអង់គ្លេស ។
- <u>កិច្ចសហប្រតិបត្តិការបច្ចេកទេសសំរាប់គំរោងវិនិយោគ</u> : ការប្រើប្រាស់ជំនួយប្រភេទនេះបានធ្លាក់ចុះយ៉ាងខ្លាំង ពី៨៦,៤លានដុល្លារអាមេរិក នាឆ្នាំ២០០៤ មកត្រឹម ៥៦,៣លានដុល្លារអាមេរិក នាឆ្នាំ ២០០៥ ។ ប្រទេសផ្តល់ជំនួយសំខាន់ៗក្នុងឆ្នាំ២០០៤ រួមមាន ÷ ប្រទេសជប៉ុន (៣៤,៨លានដុល្លារអាមេរិក) បារាំង (១៧,៥លានដុល្លារអាមេរិក) និងអូស្ត្រាលី (១០,៣លានដុល្លារអាមេរិក) ។ រីឯក្នុងឆ្នាំ ២០០៥ វិញ ប្រទេសផ្តល់ជំនួយប្រភេទនេះច្រើនជាងគេ

# <u>តារាងទី ៩</u>: ការប្រើប្រាស់ជំនួយតាមប្រភេទ និងតាមលក្ខខ័ណ្ឌ ឆ្នាំ ២០០១-២០០៥

(លានដុល្លារអាមេរិក)

| ប្រភេទរបស់ជំនួយ | លក្ខខ័ណ្ឌរបស់ជំនួយ | ២០០១ ជាក់ស្តែង | | ២០០២ ជាក់ស្តែង | | ២០០៣ ជាក់ស្តែង | | ២០០៤ ជាក់ស្តែង | | ២០០៥ បណ្តោះអាសន្ន | | សរុប ការប្រើប្រាស់ជំនួយ ២០០១-២០០៥ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ជា % | ដុល្លារអាមេរិក | ជា % | ដុល្លារអាមេរិក | ជា % | ដុល្លារអាមេរិក | ជា % | ដុល្លារអាមេរិក | ជា % | ដុល្លារអាមេរិក | ជា % |
| ជំនួយបច្ចេកទេសសុទ្ធសាធ | ជំនួយឥតសំណង | ១៧៦,១ | ៣៧,៣ | ២២៧,៦ | ៤២,៩ | ១៨៥,៤ | ៣៤,៤ | ១៧៧,១ | ៣១,៩ | ១៨២,២ | ៣៤,៧ | ៩៤៨,៣ | ៣៦,២ |
| | កម្ចី | ០ | ០ | ០ | ០ | ០ | | ០.០ | | ០.១ | ០,០ | ០,១ | ០,០ |
| | សរុប | ១៧៦,១ | ៣៧,៣ | ២២៧,៦ | ៤២,៩ | ១៨៥,៤ | ៣៤,៤ | ១៧៧,១ | ៣១,៩ | ១៨២,២ | ៣៤,៧ | ៩៤៨,៤ | ៣៦,២ |
| ជំនួយបច្ចេកទេសសំរាប់វិនិយោគ | ជំនួយឥតសំណង | ២៦,៣ | ៥,៦ | ២៤,០ | ៤,៥ | ៦១,៧ | ១១,៤ | ៨៦,៤ | ១៥,៦ | ៥៦,៣ | ១០,៧ | ២៥៤,៧ | ៩,៧ |
| | កម្ចី | ០ | ០ | ២៣,៨ | ៤,៥ | ០,០ | | ០,០ | | ០,០ | | ២៣,៨ | ០,៩ |
| | សរុប | ២៦,៣ | ៥,៦ | ៤៧,៨ | ៩,០ | ៦១,៧ | ១១,៤ | ៨៦,៤ | ១៥,៦ | ៥៦,៣ | ១០,៧ | ២៧៨,៥ | ១០,៦ |
| ជំនួយគំរោងវិនិយោគ | ជំនួយឥតសំណង | ៩២,៥ | ១៩,៦ | ៥៤,៣ | ១០,២ | ៩៤,៦ | ១៧,៥ | ៧២,៦ | ១៣,១ | ១០៧,១ | ២០,៤ | ៤២១,០ | ១៦,១ |
| | កម្ចី | ៩៧,៣ | ២០,៦ | ១៣៦,៨ | ២៥,៨ | ១៣៨,២ | ២៥,៦ | ១៨៨,២ | ៣៣,៩ | ១៥៤,១ | ២៩,៤ | ៧១៤,៧ | ២៧,៣ |
| | សរុប | ១៨៩,៨ | ៤០,២ | ១៩១,១ | ៣៦,០ | ២៣២,៩ | ៤៣,២ | ២៦០,៨ | ៤៦,៩ | ២៦១,២ | ៤៩,៨ | ១,១៣៥,៨ | ៤៣,៣ |
| ជំនួយទ្រទ្រង់ថវិកា/តុល្យភាពជញ្ជីងទូទាត់ | ជំនួយឥតសំណង | ១៨,៤ | ៣,៩ | ១៦,៨ | ៣,២ | ៤,២ | ០,៨ | ៦,៤ | ១,១ | ២,៧ | ០,៥ | ៤៨,៥ | ១,៩ |
| | កម្ចី | ២៧,៥ | ៥,៨ | ២២,៦ | ៤,៣ | ២៧,៩ | ៥,២ | ០,០ | | ០,០ | | ៧៨,០ | ៣,០ |
| | សរុប | ៤៦,០ | ៩,៧ | ៣៩,៤ | ៧,៤ | ៣២,១ | ៥,៩ | ៦,៤ | ១,១ | ២,៧ | ០,៥ | ១២៦,៥ | ៤,៨ |
| ជំនួយម្ហូបអាហារនិងសង្គ្រោះបន្ទាន់ | ជំនួយឥតសំណង | ៣៣,៦ | ៧,១ | ២៥,០ | ៤,៧ | ២៧,៥ | ៥,១ | ២០,២ | ៣,៦ | ១៧,១ | ៣,៣ | ១២៣,៤ | ៤,៧ |
| | កម្ចី | ០ | ០ | ០ | ០ | ០,០ | | ០,០ | | ០,០ | | ០,០ | |
| | សរុប | ៣៣,៦ | ៧,១ | ២៥,០ | ៤,៧ | ២៧,៥ | ៥,១ | ២០,២ | ៣,៦ | ១៧,១ | ៣,៣ | ១២៣,៤ | ៤,៧ |
| មិនបានធ្វើរបាយការណ៍ | ជំនួយឥតសំណង | ០ | ០ | ០ | ០ | ០,០ | ០,០ | ៤,៦ | ០,៨ | ៥,៣ | ១,០ | ១០,០ | ០,៤ |
| | កម្ចី | **០** | **០** | **០** | **០** | **០,០** | **០,០** | **០,០** | **០,០** | **០,០** | | **០,០** | **០,០** |
| | សរុប | **០** | **០** | **០** | **០** | **០,០** | **០,០** | **៤,៦** | **០,៨** | **៥,៣** | **១,០** | **១០,០** | **០,៤** |
| **ការប្រើប្រាស់ជំនួយសរុប** | **ជំនួយឥតសំណង** | **៣៤៧,០** | **៧៣,៥** | **៣៤៧,៧** | **៦៥,៥** | **៣៧៣,៤** | **៦៩,២** | **៣៦៧,២** | **៦៦,១** | **៣៧០,៧** | **៧០,៦** | **១.៨០៥,៩** | **៦៨,៩** |
| | **កម្ចី** | **១២៤,៩** | **២៦,៥** | **១៨៣,២** | **៣៤,៥** | **១៦៦,១** | **៣០,៨** | **១៨៨,២** | **៣៣,៩** | **១៥៤,២** | **២៩,៤** | **៨១៦,៦** | **៣១,១** |
| | **សរុប** | **៤៧១,៨** | **១០០,០** | **៥៣០,៩** | **១០០,០** | **៥៣៩,៥** | **១០០,០** | **៥៥៥,៤** | **១០០,០** | **៥២៤,៩** | **១០០,០** | **២.៦២២,៥** | **១០០,០** |

រួមមាន : ជប៉ុន (២០,៨លានដុល្លារអាមេរិក) អូស្ត្រាលី (១០,៨លានដុល្លារអាមេរិក) និង អង់គ្លេស (៧,៧លានដុល្លារអាមេរិក)។

- <u>ជំនួយគំរោងវិនិយោគ</u> : ការប្រើប្រាស់ជំនួយប្រភេទនេះមានចំនួន ២៦០,៨លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៤ និង ២៦១,២លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៥ ។ ក្នុងឆ្នាំ២០០៤ ប្រទេសផ្តល់ជំនួយគំរោងវិនិយោគ ធំជាងគេរួមមាន : ធនាគារអភិវឌ្ឍន៍អាស៊ី (៧៦,៧លានដុល្លារអាមេរិក) ប្រទេសជប៉ុន (៥២,៤លានដុល្លាអាមេរិក) ធនាគារពិភពលោក (៤៩,៥លានដុល្លាអាមេរិក) ប្រទេសចិន (៣១,៨លានដុល្លាអាមេរិក) និងសាធារណៈរដ្ឋកូរេ (២០,២លានដុល្លាអាមេរិក) ។

# ក្រាហ្វិកទី៥ : ការប្រើប្រាស់ជំនួយ តាមប្រភេទ តាមលក្ខខណ្ឌ និងតាមឆ្នាំ ១៩៩២-២០០៥



- ជំនួយទ្រទ្រង់ថវិកា/ជញ្ជីងទូទាត់ ៖ ការប្រើប្រាស់ជំនួយប្រភេទនេះបានថយចុះគួរឱ្យកត់សំគាល់ពី ៤៦លានដុល្លារអាមេរិក នាឆ្នាំ ២០០១ មកត្រឹម ២,៧លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥ ។ ប្រទេសជប៉ុនបានផ្តល់ ៤,៦លានដុល្លារអាមេរិក និងប្រទេសស៊ុយអែត ១,៨លានដុល្លារអាមេរិក ធៀបនឹងទំហំសរុបចំនួន ៦,៤លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៤ ។ នៅក្នុងឆ្នាំ ២០០៥ ជំនួយសរុបមានចំនួន២,៧លានដុល្លារអាមេរិក ក្នុងនោះសហគមន៍អឺរ៉ុបបានផ្តល់២លានដុល្លារអាមេរិក និងប្រទេសស៊ុយអែតបានផ្តល់ ០,៧លានដុល្លារអាមេរិក ។
- ជំនួយម្ហូបអាហារ មនុស្សធម៌ និងជំនួយសង្គ្រោះបន្ទាន់ ៖ ការប្រើប្រាស់ជំនួយប្រភេទនេះមានចំនួន ២០,២លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៤ និង ១៧,១លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥។ កម្មវិធីស្បៀងអាហារពិភពលោក (WFP) ដែលជាទីភ្នាក់ងារមួយរបស់អង្គការសហប្រជាជាតិ គឺជាអ្នកផ្តល់ជំនួយម្ហូបអាហារ សំរាប់ការស្តារនិងទប់ស្កាត់គ្រោះមហន្តរាយធំជាងគេទាំងពីរឆ្នាំ ៖ ១២,២លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៤ និង ១៤លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥ ។ ប្រទេសអូស្ត្រាលីបានផ្តល់ ៧,៦លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៤ និង ២,៩លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥ ។

## ៣.៥ ការប្រើប្រាស់ជំនួយតាមវិស័យ

៤២- ក្នុងកំឡុងឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៥ វិស័យសុខាភិបាលបានទទួលជំនួយបរទេសច្រើនជាងគេបើធៀបនឹងវិស័យផ្សេងៗទៀតប្រមាណ ១២,៧% នៃជំនួយអភិវឌ្ឍន៍សរុប ។ វិស័យជាបន្តបន្ទាប់ទៀតរួមមាន ៖ វិស័យដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ (១២,៤%) វិស័យអភិវឌ្ឍន៍ជនបទ (១២,២%) គ្រប់គ្រងរដ្ឋបាល (១០,១%) វិស័យអប់រំនិងអភិវឌ្ឍន៍ធនធានមនុស្ស (១០,៨%) និងការគ្រប់គ្រងសេដ្ឋកិច្ច (៨,៤%) ។ សេចក្តីលំអិតនៃការប្រើប្រាស់ជំនួយ តាមវិស័យមានសង្ខេបក្នុងតារាងទី១០ និងទិន្នន័យនៃការប្រើប្រាស់ជំនួយតាមវិស័យ និងតាមឆ្នាំនិមួយៗ ចាប់ពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០៥ មានបង្ហាញក្នុងឧបសម្ព័ន្ធ ៤ ។

៤៣- ទិន្នន័យដែលបានរាយការណ៍ដោយដៃគូអភិវឌ្ឍន៍សំរាប់រយៈពេលប្រាំឆ្នាំចុងក្រោយ ២០០១-២០០៥ បានបង្ហាញឱ្យឃើញពីការប្រែប្រួលយ៉ាងច្បាស់ពីមួយឆ្នាំទៅមួយឆ្នាំ តាមផ្នែកជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលបានប្រើប្រាស់នៅក្នុងវិស័យមួយចំនួន (តារាងទី១១) ។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅមានភាពមិនច្បាស់លាស់ អំពីការប្រែប្រួលដែលពាក់ព័ន្ធដល់ការផ្តល់ទិន្នន័យនៅតាមវិស័យរបស់ដៃគូអភិវឌ្ឍន៍ ឬក៏ជាការប្រែប្រួលពិតប្រាកដ ។ នៅឆ្នាំ២០០២ ១,៩% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបដែលបានរាយការណ៍មិនបានកំណត់វិស័យច្បាស់លាស់ឡើយ ។ ចំនួននេះបានកើនឡើងដល់ ៧ ,៩% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបដែលបានរាយការណ៍ នាឆ្នាំ ២០០៣ ។

៤៤- បើពិនិត្យមើលទិន្នន័យរបស់ដៃគូអភិវឌ្ឍន៍ ការប្រើប្រាស់ជំនួយមានការប្រែប្រួលពីវិស័យមួយទៅវិស័យមួយ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ២០០១-២០០៥ ដូចតទៅ (តារាងទី ១១) ÷

- វិស័យដែលមានការធ្លាក់ចុះ: វិស័យគ្រប់គ្រងសេដ្ឋកិច្ចបានធ្លាក់ចុះពី ៤៦,៦លានដុល្លារអាមេរិក ស្មើនឹង ៩,៨% នៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងឆ្នាំ២០០១ មកនៅត្រឹម ១០,៥ លានដុល្លារអាមេរិក ស្មើនឹង ១,៩% នៃការប្រើប្រាស់ជំនួយក្នុងឆ្នាំ២០០៤ និង ១៥,២លានដុល្លារអាមេរិក ស្មើនឹង ២,៩% នៃការប្រើប្រាស់ជំនួយក្នុងឆ្នាំ២០០៥ ។ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកើនពី ៣៥,៤លានដុល្លារអាមេរិក ស្មើនឹង ៧,៥% នៃជំនួយសរុបនាឆ្នាំ២០០១ ដល់ ៤៥,៣លានដុល្លារអាមេរិក ស្មើនឹង ៦,៤% នាឆ្នាំ២០០៤ ហើយក៏ធ្លាក់ចុះមកត្រឹម ៣៣,៥លានដុល្លារអាមេរិក ស្មើនឹង ៦,៤% នៃជំនួយសរុបនាឆ្នាំ២០០៥ ។ វិស័យអភិវឌ្ឍន៍ជនបទ បានធ្លាក់ចុះពីកំរិតខ្ពស់បំផុត ៦១,៩លានដុល្លារអាមេរិក ស្មើនឹង ១៣,១% នៃការប្រើប្រាស់ជំនួយសរុបក្នុងឆ្នាំ២០០១ មកនៅត្រឹម៤៥,៥លានដុល្លារអាមេរិក ស្មើនឹង៨,៧% ក្នុងឆ្នាំ២០០៥ ។ វិស័យអភិវឌ្ឍន៍សង្គមទទួលបាន ជំនួយច្រើនជាងមុនជាបន្ត បន្ទាប់រហូតដល់ឆ្នាំ ២០០១ ។ វិស័យនេះទទួលជំនួយបានប្រមាណ ៦៩,៦លានដុល្លារអាមេរិក ស្មើនឹង១៤,៨% នៃជំនួយសរុប ។ ដោយឡែកក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ជំនួយសំរាប់ វិស័យសង្គមកិច្ចនេះបានថយចុះពី ៤០,៣លានដុល្លារអាមេរិកនាឆ្នាំ២០០៣ មកនៅត្រឹម ៧,៧ លានដុល្លារអាមេរិក នាឆ្នាំ២០០៥ ។
- វិស័យដែលមានការកើនឡើង : វិស័យសុខាភិបាល និងវិស័យអប់រំ និងការអភិវឌ្ឍន៍ធនធានមនុស្សបានទទួលជំនួយអភិវឌ្ឍន៍ផ្លូវការច្រើនជាងគេ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ២០០១-២០០៥ ។ ជំនួយក្នុងវិស័យសុខាភិបាលបានកើនពី ៦៦,១លានដុល្លារអាមេរិក ស្មើនឹង ១៤% នាឆ្នាំ២០០១ ដល់ ១១៦,៥លានដុល្លារអាមេរិក ស្មើនឹង ២២% នាឆ្នាំ២០០៥ ។ ជំនួយសំរាប់វិស័យអប់រំ និងធនធានមនុស្ស ក៏បានកើនពី ៤៥លានដុល្លារអាមេរិក ស្មើនឹង ៩,៥% ដល់ ៧៤,៣លានដុល្លារអាមេរិក ស្មើនឹង ១៤,២% នាឆ្នាំ២០០៥ ។ ទន្ទឹមនេះ ជំនួយក៏បានកើនឡើងក្នុងវិស័យធនធានធម្មជាតិ និងថាមពលដែរ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ។ ជំនួយក្នុងវិស័យធនធានធម្មជាតិបានកើនពី ១លានដុល្លារអាមេរិក នាឆ្នាំ២០០១ ដល់ ១៩,៧លានដុល្លារអាមេរិក នាឆ្នាំ២០០៥ ។ រីឯជំនួយក្នុងវិស័យថាមពលបានកើនពី ៥,៧លានដុល្លារអាមេរិក នាឆ្នាំ២០០១ ដល់ ១៤,៥លានដុល្លារអាមេរិក នាឆ្នាំ២០០៥ ។

## តារាង ១០: ការប្រើប្រាស់ជំនួយតាមវិស័យ

(លានដុល្លារអាមេរិក)

| វិស័យ | ១៩៩៩ - ២០០៣ | | ២០០៤ | | ២០០៥ | | សរុបជំនួយ ១៩៩២-២០០៥ | |
|---|---|---|---|---|---|---|---|---|
| | ដុល្លា អាមេរិក | ការបែងចែក ជាភាគរយ | ដុល្លា អាមេរិក | ការបែងចែក ជាភាគរយ | ដុល្លា អាមេរិក | ការបែងចែក ជាភាគរយ | ដុល្លា អាមេរិក | ការបែងចែក ជាភាគរយ |
| ការគ្រប់គ្រងសេដ្ឋកិច្ច | ១៩៩,៤ | ៨,៣% | ១០,៥ | ១,៩% | ១៥,២ | ២,៩% | ៥២៧,០ | ៨,៤% |
| គ្រប់គ្រងរដ្ឋបាល | ១៧៧,៧ | ៧,៤% | ២៦,៤ | ៦,៥% | ៤៥,៣ | ៨,៦% | ៦៣៥,៨ | ១០,១% |
| ធនធានធម្មជាតិ | ៣៩,៤ | ១,៦% | ១៩,៦ | ៣,៥% | ១៩,៧ | ៣,៨% | ៩៥,៦ | ១,៥% |
| អប់រំ/ អភិវឌ្ឍន៍ ធនធានមនុស្ស | ២៦៩,៨ | ១១,២% | ៧៣,៤ | ១៣,២% | ៧៤,៣ | ១៤,២% | ៦៧៤,៣ | ១០,៨% |
| កសិកម្ម រុក្ខាប្រមាញ់ នេសាទ | ១៧៩,៩ | ៧,៥% | ៤៥,៣ | ៨,១% | ៣៣,៥ | ៦,៤% | ៤៥៨,៩ | ៧,៣% |
| អភិវឌ្ឍន៍តំបន់ / ជនបទ | ២៧៣,២ | ១១,៣% | ៦០,៥ | ១០,៩% | ៤៥,៥ | ៨,៧% | ៧៦៥,៨ | ១២,២% |
| ឧស្សាហកម្ម | ០,៧ | ០,០% | ២,៣ | ០,៤% | ៨,៤ | ១,៦% | ១២,១ | ០,២% |
| ថាមពល | ៨២,៥ | ៣,៤% | ១២,៩ | ២,៣% | ១៤,៥ | ២,៨% | ២៤៣,១ | ៣,៩% |
| ពាណិជ្ជកម្មក្រៅប្រទេស | ១,៧ | ០,១% | ២,៤ | ០,៤% | ១,៧ | ០,៣% | ៦,២ | ០,១% |
| ពាណិជ្ជកម្មក្នុងប្រទេស | ៣,៥ | ០,១% | ២,២ | ០,៤% | ១,១ | ០,២% | ២២,៥ | ០,៤% |
| ដឹកជញ្ជូន/ ហេដ្ឋារចនាសម្ព័ន្ធ | ២៨៤,៥ | ១១,៨% | ៨២,០ | ១៤,៨% | ៧៩,២ | ១៥,១% | ៧៨០,០ | ១២,៤% |
| ទូរគមនាគមន៍ | ១០,២ | ០,៤% | ១,២ | ០,២% | ០,៤ | ០,១% | ៧០,១ | ១,១% |
| អភិវឌ្ឍន៍សង្គម | ២៧៥,៩ | ១១,៥% | ៤៣,៧ | ៧,៩% | ៤០,៣ | ៧,៧% | ៥២២,៤ | ៨,៣% |
| សុខាភិបាល | ៣៥៥,៤ | ១៤,៨% | ៩៥,៩ | ១៧,៣% | ១១៦,៥ | ២២,២% | ៧៩៦,៤ | ១២,៧% |
| គ្រោះមហន្តរាយ | ៣៨,០ | ១,៦% | ៤,៩ | ០,៩% | ០,៤ | ០,១% | ៤៦,១ | ០,៧% |
| មនុស្សធម៌ | ១៨៤,៤ | ៧,៧% | ១៨,៤ | ៣,៣% | ១៥,៦ | ៣,០% | ៥២០,៧ | ៨,៣% |
| មិនបានធ្វើរបាយការណ៍ | ៣២,៨ | ១,៤% | ៤៣,៩ | ៧,៩% | ១៣,៣ | ២,៥% | ៨៩,៩ | ១,៤% |
| **ការប្រើប្រាស់ជំនួយ សរុប** | ***២៤០៨,៨*** | **១០០%** | ***៥៥៥,៤*** | **១០០%** | ***៥២៤,៩*** | **១០០%** | **៦២៦៧,០** | **១០០%** |

## តារាង ១១: ការប្រើប្រាស់ជំនួយតាមវិស័យ: ឆ្នាំ ២០០១-២០០៥

(លានដុល្លារអាមេរិក)

| វិស័យ | ២០០១ ជាក់ស្តែង | | ២០០២ ជាក់ស្តែង | | ២០០៣ ជាក់ស្តែង | | ២០០៤ ជាក់ស្តែង | | ២០០៥ បណ្តោះអាសន្ន | | សរុបការប្រើប្រាស់ជំនួយ ២០០១-២០០៥ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % | ដុល្លារ អាមេរិក | % |
| ការគ្រប់គ្រងសេដ្ឋកិច្ច | ៤៦,៤ | ៩,៨% | ៥៤,៧ | ១០,៣% | ៣២,៩ | ៦,១% | ១០,៥ | ១,៩% | ១៥,២ | ២,៩% | ១៥៩,៧ | *៦,១%* |
| គ្រប់គ្រងរដ្ឋបាល | ៣៨,៣ | ៨,១% | ៤៦,២ | ៨,៧% | ២៥,៥ | ៤,៧% | ៣៦,៤ | ៦,៥% | ៤៥,៣ | ៨,៦% | ១៩១,៧ | *៧,៣%* |
| ធនធានធម្មជាតិ | ១,០ | ០,២% | ១៥,៣ | ២,៩% | ១៨,២ | ៣,៤% | ១៩,៦ | ៣,៥% | ១៩,៧ | ៣,៨% | ៧៣,៨ | *២,៨%* |
| ការអប់រំ/ អភិវឌ្ឍន៍ ធនធានមនុស្ស | ៤៥,០ | ៩,៥% | ៦៨,៩ | ១៣,០% | ៧៥,០ | ១៣,៩% | ៧៣,៤ | ១៣,២% | ៧៤,៣០ | ១៤,២% | ៣៣៦,៦ | *១២,៨%* |
| កសិកម្ម រុក្ខាប្រមាញ់ នេសាទ | ៣៥,៤ | ៧,៥% | ៣៧,០ | ៧,០% | ៣៧,៨ | ៧,០% | ៤៥,៣ | ៨,១% | ៣៣,៥ | ៦,៤% | ១៨៨,៩ | *៧,២%* |
| អភិវឌ្ឍន៍តំបន់/ ជនបទ | ៦១,៩ | ១៣,១% | ៥០,០ | ៩,៤% | ៣៥,៩ | ៦,៧% | ៦០,៥ | ១០,៩% | ៤៥,៥ | ៨,៧% | ២៥៣,៧ | *៩,៧%* |
| ឧស្សាហកម្ម | ០ | ០% | ០,៧ | ០,១% | ០,០ | ០% | ២,៣ | ០,៤% | ៨,៤ | ១,៦% | ១១,៤ | *០,៤%* |
| ថាមពល | ៥,៧ | ១,២% | ៦,៣ | ១,២% | ២០,៣ | ៣,៨% | ១២,៩ | ២,៣% | ១៤,៥ | ២,៨% | ៥៩,៧ | *២,៣%* |
| ពាណិជ្ជកម្មក្រៅប្រទេស | ០ | ០% | ០,២ | ០% | ១,៥ | ០,៣% | ២,៤ | ០,៤% | ១,៧ | ០,៣% | ៥,៩ | *០,២%* |
| ពាណិជ្ជកម្មក្នុងប្រទេស | ១,៥ | ០,៣% | ០,៦ | ០,១% | ០,២ | ០,០% | ២,២ | ០,៤% | ១,១ | ០,២% | ៥,៧ | *០,២%* |
| ការដឹកជញ្ជូន/ ហេដ្ឋា រចនាសម្ព័ន្ធ | ៥៩,៧ | ១២,៧% | ៧៨,១ | ១៤,៧% | ៦៥,៦ | ១២,២% | ៨២,០ | ១៤,៨% | ៧៩,២ | ៥,១% | ៣៦៤,៦ | *១៣,៩%* |
| ទូរគមនាគមន៍ | ១,២ | ០,៣% | ១,៥ | ០,៣% | ១,២ | ០,២% | ១,២ | ០,២% | ០,៤ | ០,១% | ៥,៥ | *០,២%* |
| អភិវឌ្ឍន៍សង្គម | ៦៩,៦ | ១៤,៨% | ៦៤,១ | ១២,១% | ៨១,០ | ១៥,០% | ៤៣,៧ | ៧,៩% | ៤០,៣ | ៧,៧% | ២៩៨,៨ | *១១,៤%* |
| សុខាភិបាល | ៦៦,១ | ១៤,០% | ៦៧,៦ | ១២,៧% | ៨៣,១ | ១៥,៤% | ៩៥,៩ | ១៧,៣% | ១១៦,៥ | ២២,២% | ៤២៩,១ | *១៦,៤%* |
| គ្រោះមហន្តរាយ | ០ | ០% | ១៥,០ | ២,៨% | ២២,៩ | ៤,២% | ៤,៩ | ០,៩% | ០,៤ | ០,១% | ៤៣,២ | *១,៦%* |
| មនុស្សធម៌ | ៤០,១ | ៨,៥% | ១៤,២ | ២,៧% | ១៥,៩ | ៣,០% | ១៨,៤ | ៣,៣% | ១៥,៦ | ៣,០% | ១០៤,៣ | *៤,០%* |
| មិនបានធ្វើរបាយការណ៍ | ០ | ០% | ១០,៣ | ១,៩% | ២២,៤ | ៤,២% | ៤៣,៩ | ៧,៩% | ១៣,៣ | ២,៥% | ៨៩,៩ | *៣,៤%* |
| **ការប្រើប្រាស់ជំនួយសរុប** | ***៤៧១,៨*** | ***១០០%*** | ***៥៣០,៩*** | ***១០០%*** | ***៥៣៩,៥*** | ***១០០%*** | ***៥៥៥,៤*** | ***១០០%*** | ***៥២៤,៩*** | ***១០០%*** | **២ ៦២២,៥** | ***១០០%*** |

# ក្រាហ្វិកទី៦: ការប្រើប្រាស់ជំនួយតាមវិស័យ

## ១៩៩២ - ២០០៥




## ១៩៩២ - ២០០៥




## ២០០៣ - ២០០៤ - ២០០៥




**កំណត់សំគាល់**

1. ការគ្រប់គ្រងសេដ្ឋកិច្ច
2. ការគ្រប់គ្រងរដ្ឋបាល
3. ធនធានធម្មជាតិ
4. អប់រំ/ អភិវឌ្ឍន៍ធនធានមនុស្ស
5. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
6. អភិវឌ្ឍន៍តំបន់
7. ឧស្សាហកម្ម
8. ថាមពល
9. ពាណិជ្ជកម្មក្រៅប្រទេស
10. ពាណិជ្ជកម្មក្នុងប្រទេស
11. ដឹកជញ្ជូន
12. ទូរគមនាគមន៍
13. អភិវឌ្ឍន៍សង្គម
14. សុខាភិបាល
15. ជំនួយសង្គ្រោះបន្ទាន់
16. ជំនួយមនុស្សធម៌
17 មិនបានធ្វើរបាយការណ៍

## ៣.៦ ការប្រើប្រាស់ជំនួយតាមវិស័យ និងតាមប្រភពអ្នកផ្តល់ជំនួយ នាឆ្នាំ ២០០៤ និង ២០០៥

### សំរាប់ឆ្នាំ ២០០៤

៤៥ - នៅក្នុងឆ្នាំ២០០៤ សមាសភាពជំនួយអភិវឌ្ឍន៍ផ្លូវការសំរាប់វិស័យ ៧ ដែលបានទទួលជំនួយច្រើនជាងគេបង្អស់ រួមជាមួយដៃគូអភិវឌ្ឍន៍ធំជាងគេចំនួនប្រាំ មានដូចខាងក្រោម (តារាងទី១២) ៖

ក- វិស័យសុខាភិបាលទទួលជំនួយអភិវឌ្ឍន៍ផ្លូវការសរុបចំនួន៩៥,៩លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៤ ១៧,៣%នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំង៥ គឺ សហរដ្ឋអាមេរិកផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ចំនួន២៥,៤លានដុល្លារអាមេរិក ទីភ្នាក់ងារអង្គការសហប្រជាជាតិ ចំនួន១០,២លានដុល្លារអាមេរិក ចក្រភពអង់គ្លេស ចំនួន ១០,១ លានដុល្លារអាមេរិក ជប៉ុន ចំនួន ៨លានដុល្លារអាមេរិក និងគណៈកម្មការអឺរ៉ុប ចំនួន ៣,៦ លានដុល្លារអាមេរិក ។

ខ- វិស័យដឹកជញ្ជូន/ហេដ្ឋារចនាសម្ព័ន្ធទទួលជំនួយចំនួន ៨២,០ លានដុល្លារ អាមេរិកក្នុងឆ្នាំ២០០៤ ត្រូវជា ១៤,៨% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំង ៥គឺ ៖ សាធារណរដ្ឋប្រជាមានិតចិន ចំនួន ៣១,៨លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ១៩លានដុល្លារអាមេរិក ធនាគារពិភពលោក ចំនួន ១៦,១ លានដុល្លារអាមេរិក ជប៉ុន ចំនួន ១០,៣លានដុល្លារអាមេរិក សាធារណរដ្ឋកូរ៉េ ចំនួន ៣,៧លានដុល្លារអាមេរិក ។

គ- វិស័យអប់រំ/អភិវឌ្ឍន៍ធនធានមនុស្សទទួលជំនួយចំនួន ៧៣,៤លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៤ ត្រូវជា ១៣,២% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំង ៥ គឺ ៖ សាធារណរដ្ឋកូរ៉េ ចំនួន ១៣,៥លានដុល្លារអាមេរិក ជប៉ុន ចំនួន ១៣,៥លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ១២,១ លានដុល្លារអាមេរិក ស៊ុយអែត ចំនួន ៦,៧លានដុល្លារអាមេរិក និងអាល្លឺម៉ង់ ចំនួន ៦,៥លានដុល្លារអាមេរិក ។

ឃ- វិស័យអភិវឌ្ឍន៍តំបន់/ជនបទទទួលជំនួយសរុប ៦០,៥លានដុល្លារអាមេរិក ស្មើនឹង ១០,៩% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៤។ អ្នកផ្តល់ជំនួយសំខាន់ៗទាំងប្រាំគឺ ៖ ជប៉ុន ចំនួន ២៦,៧លានដុល្លារអាមេរិក ស៊ុយអែត ចំនួន ១០,៤លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ៥,៦លានដុល្លារអាមេរិក អូស្ត្រាលី ចំនួន ៣,៨លានដុល្លារអាមេរិក និងទីភ្នាក់ងារសហប្រជាជាតិចំនួន ៣លានដុល្លារអាមេរិក ។

ង- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលជំនួយចំនួន ៤៥,៣លានដុល្លាអាមេរិកក្នុងឆ្នាំ ២០០៤ ស្មើនឹង ៨,១% នៃជំនួយសរុបនាឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំងប្រាំគឺ ៖ ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ១៥,៧លានដុល្លារអាមេរិក ជប៉ុន ចំនួន ៥,៧លានដុល្លារអាមេរិក

និងប្រព័ន្ធសហប្រជាជាតិចំនួន ៥,១លានដុល្លារអាមេរិក អូស្រ្តាលី ចំនួន ៥,១លានដុល្លារអាមេរិក បារាំង ចំនួន ៤,២លានដុល្លារអាមេរិក ។

ច- វិស័យអភិវឌ្ឍន៍សង្គមទទួលជំនួយអភិវឌ្ឍន៍ផ្លូវការសរុបចំនួន ៤៣,៧លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៤ ស្មើនឹង ៧,៩% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំង៥ គឺ ÷ ធនាគារពិភពលោក ចំនួន ៧,៩លានដុល្លារអាមេរិក ជប៉ុន ចំនួន ៧លានដុល្លារអាមេរិក អូស្រ្តាលី ចំនួន ៦,៩លានដុល្លារអាមេរិក ប្រព័ន្ធសហប្រជាជាតិ ចំនួន ៤,៧លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ១,៥ លានដុល្លារអាមេរិក ។

ឆ- វិស័យគ្រប់គ្រងរដ្ឋបាលទទួលជំនួយសរុបចំនួន ៣៦,៤លានដុល្លារអាមេរិក ស្មើនឹង ៦,៥% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៤ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំងប្រាំគឺ ÷ សហរដ្ឋអាមេរិកផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៣,២លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ៤,៥លានដុល្លារអាមេរិក ស៊ុយអែត ចំនួន ៣,៣លានដុល្លារអាមេរិក ជប៉ុន ចំនួន ៣,២លានដុល្លារអាមេរិក និងប្រព័ន្ធសហប្រជាជាតិ ចំនួន៣លានដុល្លារអាមេរិក ។

ពតិមានស្តីពីសមាសភាគជំនួយអភិវឌ្ឍន៍ផ្លូវការសំរាប់វិស័យផ្សេងៗទៀត ដែលផ្តល់ដោយភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងពហុភាគីសំរាប់ឆ្នាំ២០០៤ មានបង្ហាញជូនក្នុងតារាងទី ១២ ។

៤៦ - ជំនួយអភិវឌ្ឍន៍ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលសំរាប់ឆ្នាំ២០០៤ បានផ្តោតជាសំខាន់ទៅលើវិស័យសុខាភិបាល អភិវឌ្ឍន៍សង្គម អប់រំ/អភិវឌ្ឍន៍ធនធានមនុស្ស អភិវឌ្ឍន៍តំបន់/ជនបទ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## <u>សំរាប់ឆ្នាំ ២០០៥</u>

៤៧ - ក្នុងឆ្នាំ២០០៥ ដៃគូអភិវឌ្ឍន៍ដែលបានច្រើនជាងគេចំនួន ៥ ក្នុងវិស័យ ៦ ហើយដែលមានទំហំស្មើនឹង ៨៣% នៃជំនួយសរុប រួមមានដូចខាងក្រោម (តារាងទី ១២) ÷

ក- វិស័យសុខាភិបាលទទួលជំនួយចំនួន ១១៦,៥លានដុល្លារអាមេរិក ស្មើនឹងត្រូវជា ២២,២% នៃជំនួយសរុបសំរាប់ឆ្នាំ ២០០៥ ។ អ្នកផ្តល់ជំនួយ សំខាន់ៗទាំងប្រាំគឺ ÷ សហរដ្ឋអាមេរិកផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ចំនួន២៧,១លានដុល្លារអាមេរិក ជប៉ុន ចំនួន២០,៥លានដុល្លារអាមេរិក ចក្រភពអង់គ្លេស ចំនួន១២,៨លានដុល្លារអាមេរិក ប្រព័ន្ធសហប្រជាជាតិ ចំនួន៩,៤លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន៤,៤លានដុល្លារអាមេរិក ។

ខ- វិស័យដឹកជញ្ជូន/ហេដ្ឋារចនាសម្ព័ន្ធទទួលជំនួយសរុបចំនួន ៧៩,២លានដុល្លារអាមេរិក ស្មើនឹង ១៥,១% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបសំរាប់ឆ្នាំ២០០៥ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗប្រាំគឺ ÷ សាធារណៈរដ្ឋប្រជាមានិតចិន ចំនួន២៥,៨លានដុល្លារអាមេរិក ជប៉ុន ចំនួន១៦,៨លានដុល្លារអាមេរិក ធនាគារ

អភិវឌ្ឍន៍អាស៊ី ចំនួន ១៦,៦លានដុល្លារអាមេរិក ធនាគារពិភពលោក ចំនួន ១៤លានដុល្លារអាមេរិក និងសាធារណៈរដ្ឋកូរ៉េ ចំនួន ៤,៣លានដុល្លារអាមេរិក ។

គ- វិស័យអប់រំ/អភិវឌ្ឍន៍ធនធានមនុស្សទទួលជំនួយចំនួន ៧៤,៣លានដុល្លារអាមេរិក ស្មើនឹង ១៤,២% នៃជំនួយសរុបសំរាប់ឆ្នាំ ២០០៥ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំងប្រាំគឺ ÷ ជប៉ុន ចំនួន ១៨,១លានដុល្លារ អាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ១២លានដុល្លារអាមេរិក សាធារណរដ្ឋកូរ៉េ ចំនួន ៧លាន ដុល្លារអាមេរិក គណៈកម្មការអឺរ៉ុប ចំនួន៦,៤លានដុល្លារអាមេរិក និងភ្នាក់ងារសហប្រជាជាតិ ចំនួន ៦,៤លានដុល្លារអាមេរិក ។

ឃ- វិស័យអភិវឌ្ឍន៍តំបន់/ជនបទទទួលជំនួយសរុប ៤៥,៥លានដុល្លារអាមេរិក ស្មើនឹង ៨,៧% នៃ ជំនួយសរុបសំរាប់ឆ្នាំ២០០៥ ។ អ្នកផ្តល់ជំនួយ សំខាន់ៗទាំងប្រាំគឺ ÷ ជប៉ុន ចំនួន ១៤,៣លានដុល្លារ អាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ៩,៧លានដុល្លារអាមេរិក ចក្រភពអង់គ្លេស ចំនួន ៧,៣លាន ដុល្លារ អាល្លឺម៉ង់ ចំនួន២,៣លានដុល្លារអាមេរិក និងអូស្ត្រាលី ចំនួន២,៣ លានដុល្លារអាមេរិក ។

ង- វិស័យអភិវឌ្ឍន៍រដ្ឋបាលទទួលជំនួយសរុបចំនួន ៤៥.៣លានដុល្លារអាមេរិក ស្មើនឹង ៨,៦% នៃ ជំនួយសរុបសំរាប់ឆ្នាំ ២០០៥ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗ ទាំងប្រាំគឺ ÷ សហរដ្ឋអាមេរិកផ្តល់ ជំនួយ តាមរយៈអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៦,៤លានដុល្លារអាមេរិក ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ៥,១លានដុល្លារអាមេរិក ប្រព័ន្ធសហប្រជាជាតិ ចំនួន ៤,១លានដុល្លារអាមេរិក ចក្រភពអង់គ្លេស ចំនួន ៣,៩លានដុល្លារអាមេរិក និងជប៉ុន ចំនួន ៣,៩លានដុល្លារអាមេរិក ។

ច- វិស័យអភិវឌ្ឍន៍សង្គមទទួលជំនួយចំនួន ៤០,៣ លានដុល្លាអាមេរិក ស្មើនឹង ៧,៧% នៃជំនួយ សរុបសម្រាប់ឆ្នាំ២០០៥ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗប្រាំគឺ ÷ បារាំង ចំនួន ៦,៣លានដុល្លារអាមេរិក អូស្ត្រាលី ចំនួន ៥,៥លានដុល្លារអាមេរិក ធនាគារពិភពលោក ចំនួន ៥,១ លានដុល្លារអាមេរិក ភ្នាក់ងារសហប្រជាជាតិ ចំនួន៥,១លានដុល្លារ និងធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ៤,៣លានដុល្លារ ។

ឆ- វិស័យកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ទទួលជំនួយចំនួន ៣៣,៥លានដុល្លាអាមេរិក ស្មើនឹង ៦,៤% នៃជំនួយសរុបសម្រាប់ឆ្នាំ ២០០៥ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗទាំងប្រាំគឺ ÷ ជប៉ុន ចំនួន ៩,៥លានដុល្លារអាមេរិក អូស្ត្រាលី ចំនួន ៥លានដុល្លារអាមេរិក ភ្នាក់ងារសហប្រជាជាតិ ចំនួន ៤,១លានដុល្លារអាមេរិក បារាំង ចំនួន ៤លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាស៊ី ចំនួន ៣,៦លានដុល្លារអាមេរិក ។

ពត៌មានបន្ថែមស្តីពីសមាសភាពជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាបវិស័យផ្សេងៗទៀត ដែលផ្តល់ដោយ ទីភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងពហុភាគីសម្រាប់ឆ្នាំ២០០៥ មានបង្ហាញជូនក្នុងតារាងទី ១៣ ។

៤៨ - ជំនួយអភិវឌ្ឍន៍ដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ឆ្នាំ២០០៥ បានផ្តោតជាសំខាន់ទៅលើ វិស័យសុខាភិបាល វិស័យអភិវឌ្ឍន៍សង្គម វិស័យអភិវឌ្ឍន៍តំបន់/ជនបទ វិស័យអប់រំ/អភិវឌ្ឍន៍ធនធាន មនុស្ស ។

# <u>តារាងទី ១២:</u> ការប្រើប្រាស់ជំនួយតាមប្រភេទអ្នកផ្តល់ជំនួយ និងតាមវិស័យ: ឆ្នាំ ២០០៤

(ពាន់ដុល្លារអាមេរិក)

| អ្នកផ្តល់ជំនួយសំខាន់ៗ | លក្ខខ័ណ្ឌ | គ្រប់គ្រងសេដ្ឋកិច្ច | គ្រប់គ្រងរដ្ឋបាល | ធនធានធម្មជាតិ | អភិវឌ្ឍន៍ធនធានមនុស្ស | កសិកម្ម | អភិវឌ្ឍន៍តំបន់ជនបទ | ឧស្សាហកម្ម | ថាមពល | ពាណិជ្ជកម្មអន្តរជាតិ | ពាណិជ្ជកម្មក្នុងប្រទេស | ការដឹកជញ្ជូន | ទូរគមនាគមន៍ | អភិវឌ្ឍន៍សង្គម | សុខាភិបាល | គ្រោះមហន្តរាយ | មនុស្សធម៌ | មិនបានធ្វើរបាយការណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ទីភ្នាក់ងារអង្គការសហប្រជាជាតិ** | | | | | | | | | | | | | | | | | | | |
| - ការបែងចែកតាមកម្មវិធី: សរុប | ជំនួយ | ៣៨២ | ៣.៥០១ | ២.៥២២ | ៩.៥៩០ | ៤៧៣ | ១៨.១០៣ | ៦១ | | ៧៣ | ១៩៤ | | | ១០.៨០២ | ១៨.២៣៧ | ៤.៦៣៧ | ២១១ | ៦៩ | ៦៨.៨១៤ |
| | កម្ចី | | | | | ៤.៩៨០ | | | | | | | | | | | | | ៤.៩៨០ |
| - ការប្រើប្រាស់ធនធានផ្ទាល់ | ជំនួយ | ១៩៥ | ៣.០១៨ | ១.១៥៩ | ៣.៧៤៥ | ១៥៣ | ២.៩៧៨ | | | ៥៤ | ១៩៤ | | | ៤.៦៦៦ | ១០.២៣៦ | ៤.៦៣៧ | ២១១ | ៦៩ | ៣១.៣១៤ |
| | កម្ចី | | | | | ៤.៩៨០ | | | | | | | | | | | | | ៤.៩៨០ |
| **ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ** | | | | | | | | | | | | | | | | | | | |
| - IBRD / ធនាគារពិភពលោក | ជំនួយ | | ១៧២ | | | | | | | | | | | ១៤៦ | ១.០៧១ | | | | ១.៣៩០ |
| | កម្ចី | | | ៤.៤១៤ | ៥៤៩ | ៣.៥១០ | ១៥៤ | | ២.៤៦៩ | | | ១៦.០៨០ | | ៧.៧៨៩ | ១.០០៩ | | ១២.០៩២ | | ៤៨.០៦៦ |
| - មូលនិធិរូបិយវត្ថុអន្តរជាតិ | ជំនួយ | ២.៣៥៩ | | | | | | | | | | | | | | | | | ២.៣៥៩ |
| - ធនាគារអភិវឌ្ឍន៍អាស៊ី | កម្ចី | ១.២៧០ | ៤.៤៩៤ | | ១២.១០១ | ១៥.៦៧១ | ៥.៥៨៤ | | ៤.៦៥៦ | | | ១៩.០២២ | | ១.៥៣៨ | ១.៩០៩ | | | ១០.៤១៧ | ៧៦.៦៦២ |
| **សរុប** | **ជំនួយ** | **២.៥៥៤** | **៣.១៩១** | **១.១៥៩** | **៣.៧៤៥** | **១៥៣** | **២.៩៧៨** | 0 | | **៥៤** | **១៩៤** | | | **៤.៨១២** | **១១.៣០៧** | **៤.៦៣៧** | **២១១** | **៦៩** | **៣៥.០៦៣** |
| | **កម្ចី** | **១.២៧០** | **៤.៤៩៤** | **៤.៤១៤** | **១២.៦៥០** | **២៤.១៦១** | **៥.៧៣៨** | | **៧.១២៥** | | | **៣៥.១០២** | | **៩.៣២៧** | **២.៩១៨** | | **១២.០៩២** | **១០.៤១៧** | **១២៩.៧០៨** |
| | **សរុប** | **៣.៨២៤** | **៧.៦៨៥** | **៥.៥៧២** | **១៦.៣៩៥** | **២៤.៣១៤** | **៨.៧១៦** | 0 | **៧.១២៥** | **៥៤** | **១៩៤** | **៣៥.១០២** | | **១៤.១៣៩** | **១៤.២២៥** | **៤.៦៣៧** | **១២.៣០៣** | **១០.៤៨៦** | **១៦៤.៧៧១** |
| **ប្រទេសជាសមាជិកសហគមន៍អឺរ៉ុប** | | | | | | | | | | | | | | | | | | | |
| គណៈកម្មការអឺរ៉ុប | ជំនួយ | | ១.៣៥៩ | ១.៣៨៣ | ២.២៧០ | ៧៨២ | ៥៥៧ | | | ៨៤៤ | | | | ១.៣២៥ | ៣.៦១៧ | ១១៦ | ២.០១១ | ២៣៧ | ១៥.០២០ |
| បែលហ្ស៊ិក | ជំនួយ | ១០៤ | ១៦ | ៣៨ | ១.៦៣៣ | ៥៨ | ២ | | ១៥៦ | | ៤៣ | ៣០១ | | ១.៣៨៧ | ១.៣២១ | ៥៥ | | | ៥.២០០ |
| ដាណឺម៉ាក | ជំនួយ | ៧៧៩ | | ៤.០១១ | ៣៧៥ | ៥៦៤ | ៦៥ | | | | | | | | | | | | ៥.៧៩៣ |
| ហ្វាំងឡង់ | ជំនួយ | | | | | | | | | | | | | | | | | ៣.២៩៨ | ៣.២៩៨ |
| បារាំង | ជំនួយ | ៣២៣ | | | | ៤.២០៥ | | | ១.០៥៦ | ១ | | ៣៩៥ | | ៨៨០ | | | | ១៦.១៨០ | ២៣.០៣៩ |
| អាល្លឺម៉ង់ | ជំនួយ | | ១.០៨៤ | ២៣១ | ៦.៥១៧ | ៤៣៤ | ២.៧៧៦ | | | ១៣៦ | | | | ៨៤៨ | ១.៣៨៣ | | | ៦៨៧ | ១៤.០៥៦ |
| អ៊ីតាលី | | | | | | | | | | | | | | | | | | | |

| អ្នកផ្តល់ជំនួយសំខាន់ៗ | លក្ខខ័ណ្ឌ | គ្រប់គ្រងសេដ្ឋកិច្ច | គ្រប់គ្រងរដ្ឋបាល | ធនធានធម្មជាតិ | អភិវឌ្ឍន៍ធនធានមនុស្ស | កសិកម្ម | អភិវឌ្ឍន៍តំបន់ជនបទ | ឧស្សាហកម្ម | ថាមពល | ពាណិជ្ជកម្មអន្តរជាតិ | ពាណិជ្ជកម្មក្នុងប្រទេស | ការដឹកជញ្ជូន | ទូរគមនាគមន៍ | អភិវឌ្ឍន៍សង្គម | សុខាភិបាល | គ្រោះមហន្តរាយ | មនុស្សធម៌ | មិនបានធ្វើរបាយការណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ហូឡង់ | ជំនួយ | | ៩00 | | | | | | | | | | | ៧១៣ | | | | | ១.៦១៣ |
| ន័រវេស | ជំនួយ | | | | ១.១១១ | | ៦0៩ | | | | | | | ១ .១៤៨ | ៤៩៩ | | | | ៣. ៣៦៧ |
| ស៊ុយអែត | ជំនួយ | | ៣. ២៦១ | | ៦. ៧៣២ | | ១0. ៤0៦ | | | | | | | | | | ១ .៦២៤ | | ២២. 0២៤ |
| អង់គ្លេស | ជំនួយ | | ៥២៨ | ៥. ៦៤៧ | ៩៨ | ៣៣៧ | | | | | | | | ៣៤៦ | ១0. 0៥៩ | | | | ១៧. 0១៥ |
| **សរុប** | **ជំនួយ** | **១. ២0៦** | **៧. ១៨៨** | **១១. ៣0៩** | **១៨ . ៧៣៨** | **៦. ៤២0** | **១៤. ៨៥៥** | **0** | **១. ២១២** | **៩៨១** | **៤៣** | **៦៩៦** | **0** | **៦. ៦៤៨** | **១៦. ៨៧៨** | **២១៥** | **៣. ៦៣៦** | **២0. ៤៤២** | **១១0. ៨៦៥** |
| | **សរុប** | **១. ២0៦** | **៧. ១៨៨** | **១១. ៣0៩** | **១៨ . ៧៣៨** | **៦. ៤២0** | **១៤. ៨៥៥** | **0** | **១. ២១២** | **៩៨១** | **៤៣** | **៦៩៦** | **0** | **៦. ៦៤៨** | **១៦. ៨៧៨** | **២១៥** | **៣. ៦៣៦** | **២0. ៤៤២** | **១១0. ៨៦៥** |
| **អ្នកផ្តល់ជំនួយទ្វេភាគីសំខាន់ៗ** | | | | | | | | | | | | | | | | | | | |
| អូស្ត្រាលី | ជំនួយ | ២0៦ | ២. 0៩១ | ២៥៤ | ១. ៩៩៦ | ៥. 0៤៩ | ៣. ៨១២ | | | | | ៣១៨ | | ៦. ៩២៧ | ១. ១៤0 | | ២. ៨៨៧ | | ២៤. ២៧៩ |
| កាណាដា | ជំនួយ | | ១៨៤ | | ៦១ | ៤៦ | | | | | | | | ២៣៣ | ៦១ | ៣១ | | ៨៥៧ | ១. ៤៧២ |
| ចិន | ជំនួយ | | ៤៣ | | ៥៥0 | | | | | | | ១. ៣៣៧ | | | ៥0 | | | | ១. ៩៨0 |
| | កម្ចី | | | | | | | | | | | ៣0. ៤៩0 | | | | | | | ៣0. ៤៩0 |
| ជប៉ុន | ជំនួយ | ៤. ៩៦៤ | ៣. ២១៧ | ១. ៧៨0 | ១៣. ៥២៣ | ៥. ៧២៨ | ២៦. ៧៣៣ | ២. ១៩៤ | ៤. ៥៣៨ | ៥២ | ១. ៩៥២ | ២. ៣0៦ | ៩៩១ | ៧. 0១៤ | ៧. ៩៥៩ | | | ១0. ៨0១ | ៩៣. ៧៤៧ |
| | កម្ចី | | | | | | | | | | | ៨. 0១៤ | | | | | | | ៨. 0១៤ |
| នូវែលហ្សេឡង់ | ជំនួយ | ២៥៤ | ១0 | ៣២ | ៩៥៤ | ៦៧ | ៧៥ | | | ៥0១ | ៤ | | | ៣៩៧ | ១៥0 | | | | ២. ៤៥៥ |
| សាធារណរដ្ឋកូរ៉េ | ជំនួយ | ២0 | | | ៧៣៧ | ៦៥៥ | ៦៥៤ | | | ៨៦0 | | | ៧៨ | | ៣៣៨ | | | ៨៣១ | ៤. ១៧២ |
| | កម្ចី | | ២. ៣៤៩ | | ១៣. ៩២២ | | | | | | | ៣. ៦៩៦ | | | | | | | ១៩. ៩៦៦ |
| សហព័ន្ធរុស្ស៊ី | ជំនួយ | | | | ៣៥0 | | | | | | | | | | | | | | ៣៥0 |
| ស្វ៊ីស | ជំនួយ | | | | ៩៤ | | ២៧៧ | ២២ | | | | | ១៣៨ | ៩៧ | ២. ៥៥៧ | | | | ៣. ១៨៥ |
| សហរដ្ឋអាមេរិក | ជំនួយ | | ១៣. ២៤0 | | ១. ៧៦៥ | | | | | | | | | ២៤0 | ២៥. ៣៦៣ | | | | ៤0. ៦0៧ |
| **សរុប** | **ជំនួយ** | **៩. ៤៤៤** | **១៨. ៧៨៤** | **២. 0៦៥** | **២0. 0៣0** | **១១. ៥៤៥** | **៣១. ៥៥១** | **២. ២១៥** | **៤. ៥៣៨** | **១. ៤១២** | **១. ៩៥៦** | **៣. ៩៦0** | **១. ២0៧** | **១៤. ៩0៧** | **៣៧. ៦១៩** | **៣១** | **២. ៨៨៧** | **១២. ៤៨៨** | **១៧២. ២៣៦** |
| | **កម្ចី** | | **២. ៣៤៩** | | **១៣. ៩២២** | | | | | | | **៤២. ២00** | | | | | | | **៥៨. ៤៧0** |
| | **សរុប** | **៩. ៤៤៤** | **២១. ១៣៣** | **២. 0៦៥** | **៣៣. ៩៥១** | **១១. ៥៤៥** | **៣១. ៥៥១** | **២. ២១៥** | **៤. ៥៣៨** | **១. ៤១២** | **១. ៩៥៦** | **៤៦. ១៦0** | **១. ២0៧** | **១៤. ៩0៧** | **៣៧. ៦១៩** | **៣១** | **២. ៨៨៧** | **១២. ៤៨៨** | **២៣0. ៧0៦** |
| **អង្គការមិនមែនរដ្ឋាភិបាល** (ធនធានផ្ទាល់) | **ជំនួយ** | | **៣៥៨** | **៦៤0** | **៤. ៣៣៧** | **២. ៩៨២** | **៥. ៣៦២** | **៩៨** | | | | | | **៨. 0៥៤** | **២៧. ១៤៥** | | | **៨៧៣** | **៤៩. ៨៤៩** |
| **ការប្រើប្រាស់ជំនួយសរុប** | **សរុប** | **១0. ៨៧៤** | **៣៦. ៣៦៤** | **១៩. ៩៨៦** | **៧៣. ៤២១** | **៤៩. ២៦១** | **៦0. ៨៨៤** | **២. ៣១៣** | **១២ . ៨៧១** | **២. ៤៤៧** | **២. ១៩៣** | **៨១. ៩៥៩** | **១. ២0៧** | **៤៣. ៧៨៨** | **៩៨. ៨៦៧** | **៤. ៨៨២** | **១៨. ៨២៥** | **៤៣. ៨៨៩** | **៥៥៥. ៣៩២** |

## តារាងទី ១៣: ការប្រើប្រាស់ជំនួយតាមប្រភពអ្នកផ្ដល់ជំនួយ និងតាមវិស័យ: ឆ្នាំ២០០៥

(ពាន់ដុល្លារអាមេរិក)

| អ្នកផ្ដល់ជំនួយសំខាន់ៗ | លក្ខខ័ណ្ឌ | គ្រប់គ្រងសេដ្ឋកិច្ច | គ្រប់គ្រងរដ្ឋបាល | ធនធានធម្មជាតិ | អភិវឌ្ឍន៍ធនធានមនុស្ស | កសិកម្ម | អភិវឌ្ឍន៍តំបន់ជនបទ | ឧស្សាហកម្ម | ថាមពល | ពាណិជ្ជកម្មអន្តរជាតិ | ពាណិជ្ជកម្មក្នុងប្រទេស | ការដឹកជញ្ជូន | ទូរគមនាគមន៍ | អភិវឌ្ឍន៍សង្គម | សុខាភិបាល | គ្រោះមហន្តរាយ | មនុស្សធម៌ | មិនបានធ្វើរបាយការណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ទីភ្នាក់ងារអង្គការសហប្រជាជាតិ** | | | | | | | | | | | | | | | | | | | |
| - ការបែងចែកតាមកម្មវិធី: សរុប | ជំនួយ | ៤៨ | ៤.៤៥៣ | ២.៦៣៩ | ១២.២៥២ | ៦៣៨ | ១៥.៦៨៩ | ១៥ | | ២៥៨ | ៥ | | | ១០.១៩៧ | ១៦.៤៤៥ | ២៤៤ | ៣.០៤៤ | ១០៤ | ៦៦.០២០ |
| | កម្ចី | | | ១.១១៣ | | ៤.៣២៧ | | | | | | | | | | | | ៦៤ | ៥.៥០៣ |
| - ការប្រើប្រាស់ធនធានផ្ទាល់ | ជំនួយ | ៥៥ | ៤.១៣៧ | ១.៦៣៦ | ៦.៣៥១ | ៤៣ | ១.៣០៨ | | | ២១៣ | ៥ | | | ៥.០៧៥ | ៩.៣៥៧ | ២៤៤ | ៣.០៤៤ | ៨១ | ៣១.៥៤៨ |
| | កម្ចី | | | | | ៤.០២៣ | | | | | | | | | | | | ៦៤ | ៤.០៨៧ |
| **ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ** | | | | | | | | | | | | | | | | | | | |
| - IBRD/ធនាគារពិភពលោក | ជំនួយ | ៨១ | ២០២ | | ៥៩៥ | | | | ១៦៣ | | | | | ១២៧ | ៩៨១ | | | | ២.១៤៨ |
| | កម្ចី | | | ៥.៥៩៩ | ៨៥៤ | ៣.១១៥ | | | ២.២៧៤ | | ១៦៩ | ១៤.០២៣ | | ៤.៩៦៤ | ១.១៦៤ | | ១.៨៥២ | | ៣៤.០៥៤ |
| - មូលនិធិរូបិយវត្ថុអន្តរជាតិ | ជំនួយ | | | | | | | | | | | | | | | | | | |
| | កម្ចី | | | | | | | | | | | | | | | | | | |
| - ធនាគារអភិវឌ្ឍន៍អាស៊ី | កម្ចី | ១១.៨០២ | ៥.១៣៤ | | ១២.០០៦ | ៣.៦២៤ | ៩.៧៣៩ | ៦.៨៣៥ | ៩.៤៧៦ | | | ១៦.៦១២ | | ៤.៣២០ | ៤.៣៨៦ | | | ៦២៥ | ៨៤.៥៧១ |
| **សរុប** | **ជំនួយ** | **១៣៦** | **៤.៣៣៨** | **១.៦៣៦** | **៦.៩៤៦** | **៤៣** | **១.៣០៨** | **០** | **១៦៣** | **២១៣** | **៥** | | | **៥.២០២** | **១០.៣៣៨** | **២៤៤** | **៣.០៤៤** | **៨១** | **៣៣.៦៩៦** |
| | **កម្ចី** | **១១.៨០២** | **៥.១៣៤** | **៥៥៩៩** | **១២.៨៦១** | **១០.៧៦២** | **៩.៧៣៩** | **៦.៨៣៥** | **១១.៧៥០** | | **១៦៩** | **៣០.៦៣៥** | | **៩.២៨៤** | **៥.៥៦០** | | **១.៨៥២** | **៦៨៩** | **១២២.៧១២** |
| | **សរុប** | **១១.៩៣៨** | **៩.៤៧៣** | **៧.២៣៥** | **១៩.៨០៧** | **១០.៨០៥** | **១១.០៤៧** | **៦.៨៣៥** | **១១.៩១៣** | **២១៣** | **១៧៤** | **៣០.៦៣៥** | | **១៤.៤៨៦** | **១៥.៨៩៨** | **២៤៤** | **៤.៩៣៦** | **៧៧០** | **១៥៦.៤០៧** |
| **ប្រទេសជាសមាជិកសហគមន៍អឺរ៉ុប** | | | | | | | | | | | | | | | | | | | |
| គណៈកម្មការអឺរ៉ុប | ជំនួយ | ៩៧ | ១.៨៨២ | ១.៧២៩ | ៦.៣៨៦ | ២.៣០៤ | ៨៨៨ | | ៤០ | ១.២៩២ | ១៧៦ | | | ២.១៩៧ | ១.៦៥០ | ១១៧ | ៥.១៨៩ | ៧១១ | ២៤.៦៤៧ |
| បែលហ្ស៊ិក | ជំនួយ | | ២៩៦ | | ៤.៦៥៧ | ៩៥ | ១៣៦ | | | | | ៦៧ | | ២៤៣ | ១.៧១៥ | | | | ៧.២០៧ |
| ដាណឺម៉ាក | ជំនួយ | ៧៣១ | | ៣.១៤១ | ៤០៥ | ៥០៣ | ២៥ | | | | | | | | ៣៣ | | | | ៤.៨៣៨ |
| ហ្វាំងឡង់ | ជំនួយ | | | | | | | | | | | | | | | | | ៣.២៤៤ | ៣.២៤៤ |

| អ្នកផ្ដល់ជំនួយសំខាន់ៗ | លក្ខខណ្ឌ | គ្រប់គ្រងសេដ្ឋកិច្ច | គ្រប់គ្រងរដ្ឋបាល | ធនធានធម្មជាតិ | អភិវឌ្ឍន៍ធនធានមនុស្ស | កសិកម្ម | អភិវឌ្ឍន៍តំបន់ជនបទ | ឧស្សាហកម្ម | ថាមពល | ពាណិជ្ជកម្មអន្តរជាតិ | ពាណិជ្ជកម្មក្នុងប្រទេស | ការដឹកជញ្ជូន | ទូរគមនាគមន៍ | អភិវឌ្ឍន៍សង្គម | សុខាភិបាល | គ្រោះមហន្តរាយ | មនុស្សធម៌ | មិនបានធ្វើរបាយការណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បារាំង | ជំនួយ | ៦៧១ | ៣.១៣៤ | | ២.៦៧៦ | ៤.០៤២ | ២៥ | ៥២៨ | ១.៥៦៤ | ២៤៤ | | ៩៨ | | ៦២៦៥ | ៥០០៤ | | | | ២៤២៤៩ |
| អាល្លឺម៉ង់ | ជំនួយ | ១.២០៣ | ១.២៦៦ | ២៣៦ | ៨៥៥ | ៩៤ | ២.២៨៧ | | | | | ១.៤៦៧ | | ១.៤០៧ | ៣.៦០៥ | | | ៦៦០ | ១៣.០៨១ |
| ហូឡង់ | ជំនួយ | | | | | | | | | | | | | | | | | | |
| ន័រវេស | ជំនួយ | | | | | | | | | | | | | | | | | | |
| ស៊ុយអែត | ជំនួយ | ៤១ | ១.៥៨០ | | ៤.១៤៤ | | ៧.៣២៣ | | | | | | | | | | ៥១៣ | | ១៣.៦០០ |
| អង់គ្លេស | ជំនួយ | | ៣.៩៤៤ | ៥.៧៩៩ | ៣០ | ២៩៨ | | | | | | | | | ១២.៧៦៣ | | | | ២២.៨៣៤ |
| **សរុប** | **ជំនួយ** | **២.៧៤២** | **១២.១០១** | **១០.៩០៥** | **១៩.១៥៣** | **៧.៣៣៦** | **១០.៦៨៤** | **៥២៨** | **១.៦០៣** | **១.៥៣៦** | **១៧៦** | **១.៦៣២** | ០ | **១០.១០២** | **២៤.៧៦៨** | **១១៧** | **៥.៧០២** | **៤.៦១៥** | **១១៣.៧០០** |
| | សរុប | **២.៧៤២** | **១២.១០១** | **១០.៩០៥** | **១៩.១៥៣** | **៧.៣៣៦** | **១០.៦៨៤** | **៥២៨** | **១.៦០៣** | **១.៥៣៦** | **១៧៦** | **១.៦៣២** | ០ | **១០.១០២** | **២៤.៧៦៨** | **១១៧** | **៥.៧០២** | **៤.៦១៥** | **១១៣.៧០០** |
| **អ្នកផ្ដល់ជំនួយទ្វេភាគីសំខាន់ៗ** | | | | | | | | | | | | | | | | | | | |
| អូស្ត្រាលី | ជំនួយ | ៤០៧ | ២.១៤០ | ៤៧៥ | ២.១០២ | ៤.៩៨៨ | ២.២៦០ | | | | | | ១៧៥ | ៥.៥១៩ | ៧៤២ | | ១.៣៨២ | | ២០.១៥០ |
| កាណាដា | ជំនួយ | | ៤៥០ | | | | | | | | | | | ១៤៣ | | | | ៤.៩១៤ | ៥.៥០៨ |
| ចិន | ជំនួយ | | ៥២៤ | ៤៩ | | | ១.៤៦៣ | ៩២៤ | ១.០១៥ | | | ១០.៥៨១ | | ៤៨៨ | | | | | ១៣.១០៤ |
| | កម្ចី | | | | | | | | | | | ១៥.២៤៥ | | | | | | | ១៥.២៤៥ |
| ជប៉ុន | ជំនួយ | ១០៣ | ៣.៩២៤ | ២៩៧ | ១៨.១៣៨ | ៩.៤៦០ | ១៤.៣២៨ | | | | | ១១.៨៧២ | ២៣៣ | ២.៤៩៥ | ២០.៤៨៤ | | ៣.៦១៩ | ២.៨៧១ | ៩០.៥៣២ |
| | កម្ចី | | | | | | | | | | | ៤. ៩៥៩ | | | | | | | ៤.៩៥៩ |
| នូវែលហ្សេឡង់ | ជំនួយ | | | | | | | | | | | | | | | | | | |
| សាធារណរដ្ឋកូរ៉េ | ជំនួយ | | | | | | | | | | | | | | | | | | |
| | កម្ចី | | | | ៦.៩៩៨ | | | | | | | ៤.២៨០ | | | | | | | ១១.២៧៨ |
| សហព័ន្ធរុស្ស៊ី | ជំនួយ | | | | | | | | | | | | | | | | | | |
| ស្វ៊ីស | ជំនួយ | | | | | | ១៤១ | | | | | | | ១ | ២.៣៧៦ | | | | ២.៥១៨ |
| សហរដ្ឋអាមេរិក | ជំនួយ | | ១៦.៣៧៨ | | ៣.២៧២ | | | | | | | | | | ២៧.០៩២ | | | | ៤៦.៧៤២ |
| **សរុប** | **ជំនួយ** | **៥១០** | **២៣.៤១៧** | **៨២១** | **២៣.៥១២** | **១៤.៤៤៩** | **១៨.១៩១** | **៩២៤** | **១.០១៥** | | **៧៦៨** | **២២.៤៥៣** | **៤០៨** | **៨.៦៤៦** | **៥០.៦៩៣** | | **៤.៩៦១** | **៧.៧៨៥** | **១៧៨.៥៥៣** |

| អ្នកផ្ដល់ជំនួយសំខាន់ៗ | លក្ខខ័ណ្ឌ | គ្រប់គ្រងសេដ្ឋកិច្ច | គ្រប់គ្រងរដ្ឋបាល | ធនធានធម្មជាតិ | អភិវឌ្ឍន៍ធនធានមនុស្ស | កសិកម្ម | អភិវឌ្ឍន៍តំបន់ជនបទ | ឧស្សាហកម្ម | ថាមពល | ពាណិជ្ជកម្មអន្តរជាតិ | ពាណិជ្ជកម្មក្នុងប្រទេស | ការដឹកជញ្ជូន | ទូរគមនាគមន៍ | អភិវឌ្ឍន៍សង្គម | សុខាភិបាល | គ្រោះមហន្តរាយ | មនុស្សធម៌ | មិនបានធ្វើរបាយការណ៍ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | កម្ចី | | | | ៦.៩៩៨ | | | | | | | ២៤.៤៨៤ | | | | | | | ៣១.៤៨២ |
| | សរុប | ៥១០ | ២៣.៤១៧ | ៨២១ | ៣០.៥១០ | ១៤.៤៤៩ | ១៨.១៩១ | ៩២៤ | ១ .០១៥ | | ៧៦៨ | ៤៦.៩៣៦ | ៤០៨ | ៨.៦៤៦ | ៥០.៦៩៣ | | ៤.៩៦១ | ៧.៧៨៥ | ២១០.០៣៦ |
| <u>អង្គការមិនមែនរដ្ឋាភិបាល</u> (ធនធានផ្ទាល់) | ជំនួយ | | ២៨៥ | ៧៧៦ | ៤.៨១២ | ៩០៦ | ៥.៥៣៤ | ៩៥ | | | | | | ៧.០៨៤ | ២៥.១៣០ | ១២ | | ៨៥ | ៤៤.៧១៩ |
| ការប្រើប្រាស់ជំនួយសរុប | សរុប | ១៥.១៩០ | ៤៥.២៧៦ | ១៩.៧៣៧ | ៧៤.២៨២ | ៣៣.៤៩៥ | ៤៣.៤៩៥ | ៨.៣៨២ | ១៤.៥៣១ | ១.៧៤៩ | ១.១១៩ | ៧៩.២០៣ | ៤០៨ | ៤០.៣១៨ | ១១៦.៤៩០ | ៣៧៣ | ១៥.៥៩៩ | ១៣.២៥៥ | ៥២៤.៨៦២ |

## ៣.៧ ការប្រើប្រាស់ជំនួយតាមបណ្តាខេត្ត/ក្រុងសម្រាប់ឆ្នាំ ២០០៤ និង២០០៥

៤៩- រាជរដ្ឋាភិបាលកម្ពុជាត្រូវការជាចាំបាច់នូវពត៌មានដែលអាចទទួលយកបាន ស្តីអំពីការបែងចែកជំនួយអភិវឌ្ឍន៍ផ្លូវការតាមតំបន់ ដើម្បីធានាឱ្យជំនួយទាំងអស់នោះបានប្រើប្រាស់ស្របនឹងអាទិភាពនៃការអភិវឌ្ឍន៍តាមតំបន់របស់រដ្ឋាភិបាល ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានខិតខំប្រមូលនូវពត៌មានជាលើកទី២ ស្តីពីទីតាំងភូមិសាស្ត្រនៃសកម្មភាពដែលគាំទ្រដោយជំនួយអភិវឌ្ឍន៍ផ្លូវការ នៅក្នុងការធ្វើអង្កេតប្រចាំឆ្នាំរបស់ខ្លួនស្តីពី «ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស» សំរាប់ឆ្នាំ២០០៥ ។ បើប្រៀបធៀបការធ្វើអង្កេតលើកមុន ដៃគូអភិវឌ្ឍន៍បានផ្តល់របាយការណ៍ពីពត៌មានស្តីពីទីតាំងភូមិសាស្ត្រនៃកម្មវិធីរបស់ខ្លួន សម្រាប់ឆ្នាំ ២០០៤ និង២០០៥ ។

**<u>តារាងទី ១៤:</u> ការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមបណ្តាខេត្ត/ក្រុង: ឆ្នាំ ២០០៤-២០០៥**

(ពាន់ដុល្លារអាមេរិក)

| ខេត្ត/ក្រុង | ការប្រើប្រាស់ជំនួយ | | | |
|---|---|---|---|---|
| | ២០០៤ | | ២០០៥ | |
| | ដុល្លាអាមេរិក | ភាគរយ | ដុល្លាអាមេរិក | ភាគរយ |
| បន្ទាយមានជ័យ | ៥.៩៣៥ | ១,១% | ១៦.៥២៣ | ៣,១% |
| បាត់ដំបង | ១៥.២២៧ | ២,៧% | ១១.២៧២ | ២,១% |
| កំពង់ចាម | ១១.៦១៥ | ២,១% | ១៤.៣៥១ | ២,៧% |
| កំពង់ឆ្នាំង | ៥.៩៥០ | ១,១% | ៤.៩៧១ | ០,៩% |
| កំពង់ស្ពឺ | ៧.៨៦៥ | ១,៤% | ៧.៥៤៦ | ១,៤% |
| កំពង់ធំ | ១៨.០៨៩ | ៣,៣% | ១៧.០៨៤ | ៣,៣% |
| កំពត | ១១.៧០១ | ២,១% | ១០.០២០ | ១,៩% |
| កណ្តាល | ៧.២៤៣ | ១,៣% | ២១.០០៥ | ៤,០% |
| កោះកុង | ២.៧៨១ | ០,៥% | ៣.២០៨ | ០,៦% |
| ក្រចេះ | ១៧.៦៧៦ | ៣,២% | ១០.០០៥ | ១,៩% |
| មណ្ឌលគីរី | ៥៥៣ | ០,១% | ១.៤០៩ | ០,៣% |
| ភ្នំពេញ | ៦៤.២០៦ | ១១,៦% | ៥៣.១៦២ | ១០,១% |
| ព្រះវិហារ | ៥.១៦៦ | ០,៩% | ៣.១១២ | ០,៦% |
| ព្រៃវែង | ១១.២០៩ | ២,០% | ១២.២៣៥ | ២,៣% |
| ពោធិសាត់ | ៦.៦១៨ | ១,២% | ៥.២៥៣ | ១,០% |
| រតនៈគីរី | ១.៩០២ | ០,៣% | ២.៩៣៦ | ០,៦% |
| សៀមរាប | ២៩.៤៣៦ | ៥,៣% | ៣៥.០២០ | ៦,៧% |
| ក្រុងព្រះសីហនុ | ១៦.៤៩០ | ៣,០% | ៩.៧១៣ | ១,៩% |

| ខេត្ត/ក្រុង | ការប្រើប្រាស់ជំនួយ | | | |
|---|---|---|---|---|
| | ២០០៤ | | ២០០៥ | |
| | ដុល្លាអាមេរិក | ភាគរយ | ដុល្លាអាមេរិក | ភាគរយ |
| ស្ទឹងត្រែង | ១៨.៩៩២ | ៣,៤% | ១២.០៦៨ | ២,៣% |
| ស្វាយរៀង | ៨.៨១៧ | ១,៦% | ៩.៨៩៤ | ១,៩% |
| តាកែវ | ៧.២៦៤ | ១,៣% | ៨.០០៩ | ១,៥% |
| ឧត្តរមានជ័យ | ៦.១៤៤ | ១,១% | ៧.៨៦២ | ១,៥% |
| ក្រុងកែប | ៨៥៧ | ០.២% | ៨៧៩ | ០,២% |
| ក្រុងប៉ៃលិន | ១.៣៤៥ | ០,២% | ១.៦៧៨ | ០,៣% |
| ទូទាំងខេត្ត/ក្រុង | ២៦០.៤១២ | ៤៦,៩% | ២៣២.៧៣៤ | ៤៤,៣% |
| មិនបានធ្វើរបាយការណ៍ | ១១.៩០១ | ២,១% | ១២.៩១៤ | ២,៥% |
| **សរុប** | **៥៥៥.៣៩២** | **១០០.០%** | **៥២៤.៨៦២** | **១០០.០%** |

៥០- ទិន្នន័យស្តីពីការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការតាមខេត្ត/ក្រុង ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍កម្ពុជា សំរាប់ឆ្នាំ២០០៤ និង២០០៥ បានសង្ខេបដូចតទៅ ÷

- ប្រមាណជាង ៦០% នៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានប្រើប្រាស់ក្នុងឆ្នាំ២០០៤ និង៥៧% ក្នុងឆ្នាំ ២០០៥ ត្រូវបានរាយការណ៍អំពីទីតាំងភូមិសាស្ត្រនៃគម្រោង/កម្មវិធី ដែលមានសកម្មភាពនៅទូទាំងប្រទេស នៅក្នុងក្រុងភ្នំពេញ ឬមិនបានធ្វើរបាយការណ៍ ។

| | ភាគរយនៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ផ្លូវការសរុប | |
|---|---|---|
| | ២០០៤ | ២០០៥ |
| ទូទាំងខេត្ត/ក្រុង | ៤៦,៩% | ៤៤,៣% |
| ក្រុងភ្នំពេញ | ១១,៦% | ១០,១% |
| មិនបានធ្វើរបាយការណ៍ | ២,១% | ២,៥% |
| សរុប | ៦០,៦ | ៥៦,៩% |

- ខេត្តសៀមរាបទទួលជំនួយច្រើនជាងគេបន្ទាប់ពីក្រុងភ្នំពេញនៅក្នុងឆ្នាំ២០០៤ និង ២០០៥ ពោលគឺ ៥,៣%នៃជំនួយសរុបសម្រាប់ឆ្នាំ២០០៤ និង ៦,៧% សម្រាប់ឆ្នាំ២០០៥ ។

## ក្រាហ្វិកទី៧ : ភាគរយនៃការប្រើប្រាស់ជំនួយតាមខេត្ត/ក្រុង - ២០០៥







* ផែនទីនេះមិនមែនជាផែនទីព្រំប្រទល់ផ្លូវការទេ គឺគ្រាន់តែជាផែនទីសំរាប់បង្ហាញពីការបែងចែកជំនួយផ្លូវការសំរាប់អភិវឌ្ឍន៍តាមតំបន់តែប៉ុណ្ណោះ

- ក្រៅពីក្រុងភ្នំពេញ និងខេត្តសៀមរាប ខេត្តចំនួន១០ផ្សេងទៀត ដែលបានទទួលជំនួយច្រើនជាងគេ ក្នុងឆ្នាំ២០០៤ និង២០០៥ មានបង្ហាញក្នុងតារាងខាងក្រោម ÷

| ២០០៤ | | ២០០៥ | |
|---|---|---|---|
| ខេត្ត/ក្រុង | % នៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ថ្លូវការក្នុងខេត្ត | ខេត្ត/ក្រុង | % នៃការប្រើប្រាស់ជំនួយអភិវឌ្ឍន៍ថ្លូវការក្នុងខេត្ត |
| ស្ទឹងត្រែង | ៣,៤% | កណ្តាល | ៤,០% |
| កំពង់ធំ | ៣,៣% | កំពង់ធំ | ៣,៣% |
| ក្រចេះ | ៣,២% | បន្ទាយមានជ័យ | ៣,១% |
| ក្រុងព្រះសីហនុ | ៣,០% | កំពង់ចាម | ២,៧% |
| បាត់ដំបង | ២,៧% | ព្រៃវែង | ២,៣% |
| កំពង់ចាម | ២,១% | ស្ទឹងត្រែង | ២,៣% |
| កំពត | ២,១% | បាត់ដំបង | ២,១% |
| ព្រៃវែង | ២,០% | កំពត | ១,៩% |
| ស្វាយរៀង | ១,៦% | ក្រចេះ | ១,៩% |
| កំពង់ស្ពឺ | ១,៤% | ស្វាយរៀង | ១,៩% |

៥១- ទិន្នន័យលំអិតស្តីពីបរិមាណជំនួយដែលផ្តល់តាមប្រភេទអ្នកផ្តល់ជំនួយ (ដូចជាទីភ្នាក់ងារអង្គការសហ-ប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ គណៈកម្មការអឺរ៉ុប) សម្រាប់ខេត្ត/ក្រុងនីមួយៗ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៦ ។

# ៤. សេចក្តីសន្និដ្ឋាន

៥២- រាជរដ្ឋាភិបាលកម្ពុជានៅតែប្រឈមបញ្ហាជាច្រើននៅក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស ។ ថ្វីត្បិតតែ មានវឌ្ឍនភាពគួរឱ្យកត់សំគាល់ក្នុងពេលកន្លងមក នៅមានកិច្ចការសំខាន់ៗជាច្រើនទៀត ដែលត្រូវបន្តអនុវត្ត ។ ដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានផ្តល់ការគាំទ្រដ៏មុតមាំ ក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ ។ រាជរដ្ឋាភិបាល សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ហើយសង្ឃឹមថាដៃគូអភិវឌ្ឍន៍បន្តគាំទ្រដល់កម្ពុជាបន្ថែមទៀត ដើម្បីឱ្យកម្ពុជាអាចសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៥៣- ចាប់តាំងពីឆ្នាំ ១៩៩២ ដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានរាយការណ៍ថា ជំនួយដែលមានទឹកប្រាក់៦,៣ពាន់លានដុល្លាអាមេរិក ត្រូវបានផ្តល់អោយកម្ពុជា ។ ភាគច្រើននៃជំនួយទាំងនេះត្រូវបានគ្រោង ចាត់ចែង

និងផ្តល់មកកម្ពុជា ដោយដៃគូអភិវឌ្ឍន៍ផ្ទាល់ កម្ពុជាបានអនុវត្តភាពជាម្ចាស់ក្នុងកំរិតតិចតួចបំផុត ក្នុងជំរើសសម្រាប់កិច្ចអភិវឌ្ឍន៍ និងបែបផែននៃការគ្រប់គ្រងជំនួយទាំងនោះ ។ នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាល បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ ដើម្បីអនុវត្តគោលនយោបាយចំបងៗ ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ដោយធ្វើការពិគ្រោះយោបល់ទូលំទូលាយ ជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ដោយរួមទាំងអង្គការសង្គមស៊ីវិល ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ គឺជាឯកសារតែមួយគត់ ដែលមានដាក់បញ្ចូលនូវបណ្តាគោលដៅនិងយុទ្ធសាស្ត្រអាទិភាពនានារបស់រាជរដ្ឋាភិបាល សំដៅកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច សំរាប់ជាប្រយោជន៍ដល់ប្រជាជនទាំងមូល ។ «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» គឺជាផែនការសម្រាប់អនុវត្ត «យុទ្ធសាស្ត្រចតុកោណ» សំដៅសំរេចឱ្យបាននូវបណ្តាគោលដៅនានាដែលបានកំណត់ ។ រីឯ «កម្មវិធីវិនិយោគសាធារណៈឆ្នាំ២០០៦-២០០៨» ត្រូវបានរៀបចំសម្រាប់គាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ឯកសារទាំង២នេះ បានអនុម័តដោយរាជរដ្ឋាភិបាល ក្នុងអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃ ទី២៧ ខែមករា ឆ្នាំ២០០៦ ។ ឯកសារទាំងនេះក៏មានគោលដៅឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ធ្វើការតម្រឹម និងធ្វើសុខដុមនីយកម្មកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ និងផ្ទេរធនធានពិតប្រាកដមកកម្ពុជាឱ្យបានច្រើនជាងមុន ។ រាជរដ្ឋាភិបាលសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទ្វេ-ពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាល តម្រឹមយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ខ្លួន ឱ្យស្របនឹងបណ្តាអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងតម្រឹមគម្រោងនិងកម្មវិធី ជាមួយនឹងកម្មវិធីវិនិយោគសាធារណៈដែលបានរៀបចំ ។

៥៤- ទោះបីជាមានកិច្ចប្តេជ្ញាចិត្តដែលបានធ្វើនៅក្នុងបណ្តាវេទិកាអន្តរជាតិជាច្រើនកន្លងមក ដូចជាក្នុងសេចក្តីប្រកាសក្រុងរ៉ូម (២០០៣) និងសេចក្តីប្រកាសក្រុងប៉ារីស (២០០៥) ទំលាប់ប្រតិបត្តិរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន ដែលមានឫសគល់តាំងពីទសវត្សរ៍ទី៩០ ដែលជាទសវត្សរ៍ដែលការសិក្សាជាច្រើនហៅថាទសវត្សរ៍នៃភាពជាអ្នកផ្តល់ជំនួយនៅតែបន្ត ។ បញ្ហាប្រឈមសម្រាប់ដៃគូអភិវឌ្ឍន៍របស់កម្ពុជា គឺត្រូវប្រែក្លាយសេចក្តីប្តេជ្ញាចិត្តទាំងនេះ ឱ្យទៅជាសកម្មភាពជាក់លាក់ សំរាប់ផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន ដើម្បីឱ្យរាជរដ្ឋាភិបាលអាចអនុវត្តភាពជាម្ចាស់បានកាន់តែមានភាពរឹងមាំ ក្នុងបរិយាកាសមួយដែលមានកិច្ចសហប្រតិបត្តិការ មានជំនឿទុកចិត្តគ្នា និងមានការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ដើម្បីបង្កើនប្រសិទ្ធភាពជំនួយ សម្រាប់ជាគុណប្រយោជន៍ដល់កម្ពុជា ។

